# កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា

## បញ្ជីសារពើភណ្ឌគោលនយោបាយ និងកម្មវិធីទាក់ទងនឹងសិស្សបោះបង់ការសិក្សានៅកម្ពុជា



កិច្ចសន្យាលេខ៖ EDH-I-00-05-00029-00
បេសកកម្មការងារ៖ AID-OAA-TO-10-00010

ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១

ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងសម្រាប់ពិនិត្យឡើងវិញដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ( USAID ) និងត្រូវបានរៀបចំដោយក្រុមហ៊ុន គ្រីអេធីវ អាសូស៊ីអេត អ៊ីនធើណេសិនណាល (Creative Associates International ) ។

# បញ្ជីសារពើភណ្ឌគោលនយោបាយ
# និងកម្មវិធីទាក់ទងនឹងសិស្សបោះបង់ការសិក្សានៅកម្ពុជា

**ដាក់ជូន៖**
**ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ**(USAID)
**ទីក្រុងវ៉ាស៊ីនតោន ឌីស៊ី**

**ធ្វើជូនដោយ៖**
Creative Associates International, Inc.
**ទីក្រុងវ៉ាស៊ីនតោន ឌីស៊ី**

**ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១**

របាយការណ៍នេះអាចចេញជារូបរាងបាន ដោយសារតែមានការឧបត្ថម្ភគាំទ្រពីពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ(USAID) ។ ខ្លឹមសារនៃរបាយការណ៍នេះត្រូវបានរៀបចំចងក្រងឡើងដោយ (Creative Associates International) និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។

## គម្រូទការដាក់ជូនទៅ DEC

| | | |
|---|---|---|
| ក | ការប្រគល់កិច្ចសន្យារបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ(USAID) | កិច្ចសន្យាលេខ:EDH-I-00-05-00029-00<br>បេសកកម្មការងារ: AID-OAA-TO-10-00010 |
| ខ | ចំណងជើងគោលដៅនិងលេខរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ(USAID) | ការវិនិយោគទៅលើប្រជាជន |
| គ | ចំណងជើងគម្រោង និងលេខរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ(USAID) | កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា (SDPP) នៅតំបន់អាស៊ី និងមជ្ឈឹមបូព៌ានៃទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) |
| ឃ | ផ្នែកនៃកម្មវិធី និងធាតុផ្សំនៃកម្មវិធីរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ(USAID) | ការអប់រំ (ផ្នែកនៃកម្មវិធី ៣.២)<br>ការអប់រំកម្រិតមូលដ្ឋាន (ធាតុផ្សំនៃកម្មវិធី ៣.២.១) |
| ង | ចំណងជើងសៀវភៅ | បញ្ជីសារពើភណ្ឌគោលនយោបាយ និងកម្មវិធីទាក់ទងទៅនឹងសិស្សបោះបង់ការសិក្សានៅក្នុងប្រទេសកម្ពុជា |
| ច | ឈ្មោះអ្នកនិពន្ធ | Lorie Brush, Jennifer Shin,Rajani Shrestha, Karen Tietjen |
| ឆ | ឈ្មោះអ្នកទទួលកិច្ចសន្យា | ក្រុមហ៊ុនគ្រីអេធីវអាសូស៊ីអេតអាំងធឺណេសិនណាល (Creative Associates International) ដែលមានអាស័យដ្ឋាននៅ៖<br>5301 Wisconsin Avenue, NW, Suite 700 Washington, DC 20015<br>ទូរស័ព្ទលេខ៖២០២៩៦៦-៥៨០៤<br>ទូរសារលេខ៖២០២៣៦៣-៤៧៧១<br>អ៊ីមែល: KarenT@creativeDC.com |
| ជ | ឧបត្ថម្ភដោយអង្គភាពប្រតិបត្តិការ នៃទីភ្នាក់ងារ | AME/ME/TS<br>Rebecca Adams, |

| | | |
|---|---|---|
| | សហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) និងអ្នកតំណាងបច្ចេកទេសរបស់អ្នកទទួលកិច្ចសន្យា(COTR) | អ្នកតំណាងបច្ចេកទេសរបស់អ្នកទទួលកិច្ចសន្យា(COTR) |
| ឈ | កាលបរិច្ឆេទបោះពុម្ពផ្សាយ | ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ |
| ញ | ភាសាប្រើប្រាស់ក្នុងឯកសារ | អង់គ្លេស និង ខ្មែរ |

# មាតិកា


បញ្ជីតារាង.......................................................................................................................ii

អក្សរកាត់ .......................................................................................................................iii

សេចក្តីសង្ខេបសំខាន់................................................................................................... ១

I. សេចក្តីផ្តើម.................................................................................................................៣

II. គោលនយោបាយ និងកម្មវិធី ...................................................................................... ៥

ក. បរិបទច្បាប់នៃការអប់រំ ............................................................................................... ៥

ខ. អាគារសិក្សា................................................................................................................ ១១

គ. ការជ្រើសរើស ការបណ្តុះបណ្តាល និងឥរិយាបថគ្រូបង្រៀននៅក្នុងថ្នាក់ រៀន . ១១

ឃ. សេវាទ្រទ្រង់សាលារៀន.............................................................................................. ១៤

ង. ទម្លាប់អនុវត្តតាមវប្បធម៌ ............................................................................................. ១៦

III. ជម្រើសសម្រាប់អន្តរាគមន៍នៃកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា (SDPP) .......................................................................................................................១៧

ឧបសម្ព័ន្ធ "ក"៖ តារាងគោលនយោបាយ និងកម្មវិធីសម្រាប់ប្រទេសកម្ពុជា ..............២០

ឯកសារយោង............................................................................................................ ១០១

# បញ្ជីតារាង

តារាងទី១៖ គោលនយោបាយស្តីពីភារកិច្ចនៃការទទួលខុសត្រូវលើការសិក្សានិងការអប់រំដោយឥតបង់ថ្លៃនៅកម្ពុជា
តារាងទី២៖ គោលនយោបាយស្តីពីការប្រឡង និងការឡើងថ្នាក់នៅកម្ពុជា
តារាងទី៣៖ គោលនយោបាយ និងកម្មវិធីគាំទ្រកុមារី និងសិស្សប្រឈមនឹងការបោះបង់ការសិក្សានៅកម្ពុជា
តារាងទី៤៖ គោលនយោបាយ និងកម្មវិធីស្តីពីបញ្ហានៃការទទួលបានការអប់រំ/អគ្រាគង់វង្សនៅកម្ពុជា
តារាងទី៥៖ គោលនយោបាយ និងកម្មវិធីស្តីពីអាគារសិក្សានៅកម្ពុជា
តារាងទី៦៖ គោលនយោបាយ និងកម្មវិធីស្តីពីការជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀននៅកម្ពុជា
តារាងទី៧៖ គោលនយោបាយ និងកម្មវិធីស្តីពីឥរិយាបថគ្រូបង្រៀននៅក្នុងថ្នាក់នៅកម្ពុជា
តារាងទី៨៖ គោលនយោបាយ និងកម្មវិធីស្តីពីកម្មវិធីសិក្សានៅកម្ពុជា
តារាងទី៩៖ គោលនយោបាយ និងកម្មវិធីស្តីពីសេវាទ្រទ្រង់សាលារៀននៅកម្ពុជា
តារាងទី១០៖ ទម្លាប់អនុវត្តតាមវប្បធម៌នៅកម្ពុជា

## អក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFESIP | អង្គការអាហ្វេស៊ីប |
| AME | ការិយាល័យអាស៊ី និងមជ្ឈឹមបូព៌ា |
| APE | សមាគមការពារបរិស្ថាន |
| ASK | ការលើកកម្ពស់ការសិក្សាភាសាខ្មែរ |
| BFD | អង្គការព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍ |
| BROK | សូមមើល *PROK* |
| BSDA | សមាគម អភិវឌ្ឍន៍ព្រះពុទ្ធសាសនា និងសង្គម |
| CCBO | អង្គការផ្អែកលើកុមារសហគមន៍ |
| CDRCP | មជ្ឈមណ្ឌលអភិវឌ្ឍ និងជំនួយសម្រាប់ប្រជាពលរដ្ឋក្រីក្រនៅកម្ពុជា |
| CEDAW | គណៈកម្មាធិការលុបបំបាត់ការរើសអើងលើស្ត្រី |
| CFS | សាលាកុមារមេត្រី |
| CFSI | គំនិតផ្តួចផ្តើមសាលាកុមារមេត្រី |
| CIDC | សហគមន៍អភិវឌ្ឍកម្ពុជា-ឥស្លាម |
| CNCW | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |
| COTR | អ្នកតំណាងបច្ចេកទេសរបស់មន្ត្រីចុះកិច្ចសន្យា (USAID) |
| CTB-BTC | កិច្ចសហប្រតិបត្តិការបច្ចេកទេសប៊ែលហ្ស៊ិក |
| DAC | ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| DEC | ការិយាល័យធនធានដើម្បីរៀបចំឯកសារបច្ចេកទេស និងកម្មវិធីតាមប្រព័ន្ធអ៊ិនធើនែត |
| DOE | ការិយាល័យអប់រំស្រុក |
| DTMT | ក្រុមត្រួតពិនិត្យការបណ្តុះបណ្តាលថ្នាក់ស្រុក |
| DTP | តំណក់ទឹកប៉ោយប៉ែត (ការការពារសិទ្ធិកុមារ) |
| EBEP | កម្មវិធីពង្រីកការអប់រំកម្រិតមូលដ្ឋាន |
| EEQP | គម្រោងលើកកម្ពស់គុណភាពអប់រំ |
| EFA | ការអប់រំសម្រាប់ទាំងអស់គ្នា |
| EMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ |
| ESP | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| ESSSUAP | កម្មវិធីសកម្មភាពពង្រីកការគាំទ្រវិស័យ អប់រំ |
| FTI | គំនិតផ្តួចផ្តើមពន្លឿនការអប់រំ |
| GCC | គណៈកម្មាធិការក្រុមប្រឹក្សាកុមារី |

| | |
|---|---|
| GCE | យុទ្ធនាការអប់រំជាសាកល |
| GYK | (អយក) អប់រំយុវជន និងកីឡា |
| HCEP | គម្រោងអប់រំសហគមន៍ខ្ពង់រាប |
| HEKS | អង្គការជំនួយអន្តរព្រះវិហារស្វ៊ីស |
| HIV/AIDS | ជម្ងឺអេដស៍/ កាមរោគ |
| IBEC | គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា |
| ICC | អង្គការសហការ |
| IIP | ការវិនិយោគនៅលើមនុស្ស |
| ILO | អង្គការពលកម្មអន្តរជាតិ |
| KAFDOC | សមាគមខ្មែរដើម្បីអភិវឌ្ឍជនបទ |
| KAPE | អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា |
| KCDI | វិទ្យាស្ថានអភិវឌ្ឍវប្បធម៌ខ្មែរ |
| KNKS | អង្គការកុមារនៃក្តីសង្ឃឹម |
| KPF | មូលនិធិកុមារពិការ |
| KRY | សមាគមគ្រួសារយើង |
| KT | អង្គការគ្រួសារថ្មី |
| KYA | សមាគមយុវជនខ្មែរ |
| LCDI | អង្គការវិទ្យាស្ថានអភិវឌ្ឍភាពជាអ្នកដឹកនាំ និងចរិតលក្ខណៈ |
| MJP | អង្គការម៉ាដុក ជូលី ភីត |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MORE | គម្រោងអប់រំផ្សព្វផ្សាយជនជាតិភាគតិច |
| MoSALVY | ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទា |
| NEP | ភាពដៃគូអប់រំអង្គការមិនមែនរដ្ឋាភិបាល |
| NFE | ការអប់រំក្រៅប្រព័ន្ធ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NH | មនុស្សលោកថ្មី |
| OEC | អង្គការប្រតិបត្តិការកុមារកម្ពុជា |
| OVC | កុមារកំព្រា និងកុមារងាយរងគ្រោះ |
| PED | នាយកដ្ឋានបឋមសិក្សា |
| PKO | អង្គការពុទ្ធិកុមារ |
| PNKS | ពន្លឺនៃក្តីសង្ឃឹម |
| POE | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត |

| | |
|---|---|
| PROK | ប្រកាស |
| PTA | សមាគមមាតាបិតាសិស្ស |
| PTEA | អង្គការផ្ទះទឹកដូង |
| PTTC | សាលាគរុកោសល្យ និងវិក្រឹតការខេត្ត |
| PVT | អង្គការព្រហ្មវិហារធម៌ |
| RDA | សមាគមអភិវឌ្ឍជនបទ |
| REDA | សមាគមអភិវឌ្ឍសេដ្ឋកិច្ចជនបទ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SC | អង្គការនិរន្តរភាព កម្ពុជា |
| SCA | អង្គការសង្គ្រោះកុមារ អូស្រ្តាលី |
| SCADP | កម្មវិធីជំនួយ និងអភិវឌ្ឍកុមារតាមដងផ្លូវ |
| SCD | អង្គការសង្គ្រោះកុមារកម្ពុជាដើម្បីការអភិវឌ្ឍន៍ |
| SCN | អង្គការសង្គ្រោះកុមារណ័រវេ |
| SDPP | កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា |
| SIDA | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត |
| SMC | គណៈកម្មាធិការគ្រប់គ្រងសាលា |
| SNN | សារាចរណែនាំ |
| TDMP | ផែនការមេអភិវឌ្ឍគ្រូបង្រៀន |
| THR | របបអាហារយកទៅផ្ទះ |
| US | សហរដ្ឋអាមេរិក |
| UN | អង្គការសហប្រជាជាតិ |
| UNCRC | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ |
| UNESCO | អង្គការអប់រំ វិទ្យាសាស្រ្ត និងវប្បធម៌នៃអង្គការសហប្រជាជាតិ (យូណេស្កូ) |
| UNICEF | អង្គការមូលនិធិកុមារនៃអង្គការសហប្រជាជាតិ |
| UNIFEM | មូលនិធិអភិវឌ្ឍន៍អង្គការសហប្រជាជាតិដើម្បីស្ត្រី |
| UPWD | ការអភិវឌ្ឍន៍ស្ត្រីក្រីក្រនៅជាយក្រុង |
| USAID | ទីភ្នាក់ងារសហប្រជាជាតិដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| VFC | វិសិនហ្វាន់ កម្ពុជា |
| VSO | អង្គការអ្នកស្ម័គ្រចិត្តបម្រើការងារនៅបរទេស |
| WFP | កម្មវិធីស្បៀងអាហារពិភពលោក |
| WP | អង្គការវឌ្ឍនភាព |

## សេចក្តីសង្ខេបសំខាន់

ប្រទេសនីមួយៗក្នុងប្រទេសទាំងបួនបានចូលរួមក្នុងកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា (SDPP) ដែលត្រូវបានផ្តល់មូលនិធិដោយទីភ្នាក់ងារសហរដ្ឋដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) មានជាអាទិ៍ ប្រទេសកម្ពុជា ឥណ្ឌា តាជីគីស្ថាន និង ទីម័រលែស បានកំណត់គោលនយោបាយអប់រំសម្រាប់កុមារ ដែលក្នុងនោះ គោលនយោបាយមួយចំនួនមានលក្ខណៈទូលំទូលាយជាងគេ។ ប្រទេសនីមួយៗមានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដែលក្នុងនោះអង្គការទាំងនេះជួយផ្តល់សេវាអប់រំ ទោះបីជាចំនួននៃអង្គការទាំងនេះមានលក្ខណៈខុសគ្នាពីតិចតួចនៅប្រទេសតាជីគីស្ថាន រហូតដល់ជាង៥០អង្គការនៅក្នុងប្រទេសកម្ពុជា។ កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា មានភារកិច្ចអនុវត្តគម្រោងនៅក្នុងប្រទេសនីមួយៗ ក្នុងគោលបំណងដើម្បីកាត់បន្ថយអត្រាសិស្សបោះបង់ការសិក្សា ហើយនៅក្នុងករណីនីមួយៗ អន្តរាគមន៍នេះត្រូវតែមានលក្ខណៈសមស្របនៅក្នុងបរិបទគោលនយោបាយ និងបន្តកិច្ចខិតខំប្រឹងប្រែងបច្ចុប្បន្នបន្ថែមទៀត ប៉ុន្តែមិនឲ្យជាន់កម្មវិធីគ្នា។ របាយការណ៍នេះផ្តោតទៅលើគោលនយោបាយ និងកម្មវិធីទាក់ទងនឹងសិស្សបោះបង់ការសិក្សានៅកម្ពុជា។

ដើម្បីបង្កើតបញ្ជីសារពើភណ្ឌគោលនយោបាយ និងកម្មវិធីនានា អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជាដែលជាដៃគូអនុវត្តក្នុងប្រទេស នៃកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលាបានបំពេញតារាងម៉ាទ្រីក ដែលរៀបរាប់អំពីប្រធានបទចំនួន៤០ ដែលបានបង្ហាញថាមានទំនាក់ទំនងទៅនឹងអត្រាសិស្សបោះបង់ការសិក្សា និងបរិយាយអំពីខ្លឹមសារនៃឯកសារ និងកម្មវិធីពាក់ព័ន្ធ ក្រុម គោលដៅ និងសច្ចភាពមូលដ្ឋាននៃការអនុវត្តគោលនយោបាយ ឬកម្មវិធី និង របាយការណ៍ស្តីពីអានុភាពទៅលើការបោះបង់ការសិក្សា។ ជាទូទៅ ប្រធានបទទាំងនេះក្តោបលើបរិបទច្បាប់នៃការអប់រំ ឧទាហរណ៍ដូចជា តម្រូវការឲ្យចូលរៀនដោយឥតបង់ថ្លៃ និងភារកិច្ចនៃការទទួលខុសត្រូវលើការសិក្សា សេវានានាសម្រាប់កុមារ និង កុមារី ដែលប្រឈមនឹងការបោះបង់ ប្រក្រតិទិនសាលា និងនិយាមថ្នាក់រៀន) អាគារសិក្សា (ឧ. លទ្ធភាពនៃការទទួលបានសាលាកុមារមេត្រីសម្រាប់កុមារី) ការជ្រើសរើស ការបណ្តុះបណ្តាល និងឥរិយាបថគ្រូបង្រៀននៅក្នុងបន្ទប់រៀន (ឧ.ការជ្រើសរើសយ៉ាងពិសេសនៃជនជាតិភាគតិច ឬស្ត្រី ការប្រើប្រាស់ភាសាកំណើត) ការផ្តល់សេវាគាំទ្រនៅតាមសាលារៀន បន្ថែមលើការអប់រំកម្រិតមូលដ្ឋាន (ឧ. មុខវិជ្ជាបំប៉នបន្ថែម សេវាសុខភាព ឬអាហារ) និងទម្លាប់អនុវត្តតាមវប្បធម៌ ដែលនាំឲ្យសិស្សបោះបង់ការសិក្សា (ឧ. ការឆាប់រៀបការ ឬការរៀបការមុនអាយុ)។ ការអនុវត្តតាមបទបង្ហាញគោលនយោបាយ និងកម្មវិធីនៅប្រទេសកម្ពុជាគឺជាជម្រើសមួយ ក្នុងចំណោមជម្រើសជាច្រើនសម្រាប់អន្តរាគមន៍ដែលកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា អាចយកមកប្រើនៅក្នុងប្រទេសដោយផ្តល់នូវបរិបទអប់រំដែលមានស្រាប់។ គួរកត់សម្គាល់ផងដែរថា ភាពប្រែប្រួលនៃសំណើរលើកដំបូង

នឹងត្រូវបានជូនដំណឹងតាមរយៈលទ្ធផលរកឃើញនៃការវិភាគ និងពិភាក្សាតាមស្ថានភាពក្នុងប្រទេសនៃកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សាជាមួយក្រសួងអប់រំ និងអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។

ប្រទេសកម្ពុជាមានគោលនយោបាយអប់រំដ៏ទូលំទូលាយ និងសម្បូរទៅដោយអង្គការមិនមែនរដ្ឋាភិបាល ដែលបានចូលរួមសកម្មនៅក្នុងការអប់រំ ដូចដែលមានបង្ហាញជាឧទាហរណ៍អំពីអង្គការមិនមែនរដ្ឋាភិបាលចំនួន៥៣ ដែលផ្តល់កម្មវិធីអាហារូបករណ៍ដល់សិស្ស។ សំណើសុំអន្តរាគមន៍កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សាមានការពាក់ព័ន្ធនឹង ការវាយតម្លៃអំពីថាតើគោលនយោបាយត្រូវបានអនុវត្តទៅតាមតម្រូវការ និងធ្វើការយ៉ាងសកម្មដើម្បីឲ្យកុមារនៅរៀនបន្ត និងទទួលបានជោគជ័យក្នុងការសិក្សារបស់ពួកគេ។ ជាពិសេស ពួកគេចូលរួមៈ

- វិភាគអានុភាពនៃតម្រូវការសម្រាប់ការប្រឡងឆមាសទៅលើអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ និងធ្វើការជាមួយគ្រូបង្រៀន ឬគណៈកម្មការរៀបចំការប្រឡងដើម្បីលើកកម្ពស់ដល់ការប្រើប្រាស់នៃការវាយតម្លៃ ជាឧបករណ៍មួយដើម្បីបង្កើនការរៀនសូត្ររបស់សិស្ស។
- វាយតម្លៃផលវិបាកនៃនិយាមថ្នាក់រៀនដែលមានកុមារចំនួន៥៩នាក់ ស្វែងរកជម្រើសសម្រាប់ជំនួយការគ្រូបង្រៀន និងផ្តល់ការបណ្តុះបណ្តាលពិសេសដល់គ្រូបង្រៀនក្នុងការដោះស្រាយនិយាមថ្នាក់រៀនធំ ដើម្បីបង្កើនកម្រិតនៃការរៀនសូត្ររបស់កុមារ និងកាត់បន្ថយអត្រាសិស្សបោះបង់ការសិក្សា។
- កែលម្អការអប់រំថ្នាក់បឋមសិក្សាពីរភាសា តាមរយៈ (ក)ការជួយបកប្រែសៀវភៅទៅជាភាសាជនជាតិភាគតិច (ខ)ឲ្យគ្រូបង្រៀន និងឪពុកម្តាយសិស្សបង្កើតសៀវភៅរឿងខ្លីៗសម្រាប់កុមារដោយមានអត្តចរិត ការកំណត់ និងបញ្ហាជនជាតិភាគតិចនានា និង(គ)ធ្វើជាមួយគ្រូបង្រៀនស្តីពីយុទ្ធសាស្ត្រ និងយុទ្ធវិធីដើម្បីឲ្យប្រើប្រាស់ពហុភាសានៅក្នុងបន្ទប់រៀន។

## I. សេចក្ដីផ្ដើម

ដើម្បីធ្វើការសម្រេចចិត្តអំពីកម្មវិធីនានា ដែលអាចកាត់បន្ថយអត្រាសិស្សបោះបង់នៅកម្ពុជា វាសំខាន់ក្នុងការឈ្វេងយល់ឲ្យបានស៊ីជម្រៅអំពីបរិបទគោលនយោបាយអប់រំនៅក្នុងប្រទេស និងប្រភេទនៃកម្មវិធីដែលកំពុងដំណើរការនាពេលបច្ចុប្បន្ន។ អន្តរាគមន៍ទាំងនេះត្រូវធ្វើឲ្យសមស្របទៅតាមគោលនយោបាយដែលមានស្រាប់ ជាជាងការអនុវត្តផ្ទុយពីគោលនយោបាយទាំងនេះ។ អន្តរាគមន៍ទាំងនេះមិនត្រូវធ្វើឲ្យជាន់គ្នាជាមួយនឹងកម្មវិធីដែលមានស្រាប់នោះទេ ហើយអន្តរាគមន៍ទាំងនេះត្រូវមានភស្តុតាងបង្ហាញពីភាពជោគជ័យនៅក្នុងបរិបទស្រដៀងគ្នា។ ការពិនិត្យឡើងវិញនូវឯកសារស្រាវជ្រាវ[៩] ស្ដីពីកម្មវិធីសិស្សបោះបង់ការសិក្សាដែលត្រូវបានធ្វើឡើងក្រោម *កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា (SDPP)* បានផ្ដល់យោបល់មួយចំនួនអំពីគោលវិធីចម្បងៗ ដើម្បីដោះស្រាយបញ្ហានៃសិស្សបោះបង់ការសិក្សា។ បញ្ជីសារពើភណ្ឌគោលនយោបាយ និងកម្មវិធីដដែលមានស្រាប់ ដែលត្រូវបានបញ្ចប់ នៅក្នុងកិច្ចសន្យាតែមួយធ្វើការជាជំហានបន្ទាប់ ដែលគេតម្រូវឲ្យមាននៅក្នុងទិសដៅនាំទៅរកការបង្កើតកម្មវិធីទប់ស្កាត់សិស្សបោះ បង់ការសិក្សាឲ្យទទួលបានជោគជ័យនៅក្នុងប្រទេសកម្ពុជា។ បញ្ជីសារពើភណ្ឌនេះត្រូវបែងចែកជាបីផ្នែក។ បន្ទាប់ពីសេចក្ដីផ្ដើមនេះ យើងបានរៀបរាប់អំពី*គោលនយោបាយ និងកម្មវិធីដែលមានស្រាប់* នៅក្នុងប្រទេសកម្ពុជា ដោយលើកឡើងជាង៤០ប្រធានបទ ឬផ្នែកដែលអាចមានឥទ្ធិពលលើសិស្សបោះបង់ការសិក្សា។ បន្ទាប់មក យើងបកប្រែគោលនយោបាយនិងកម្មវិធីទាំងនេះទៅជា*ជម្រើសដែលគេបានស្នើឡើង សម្រាប់អន្តរាគមន៍កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា* ដែលលើកឡើងនូវបរិបទគោលនយោបាយជាក់លាក់ និងកម្មវិធីដែលមានស្រាប់។ គួរកត់សម្គាល់ផងដែរថា ភាពប្រែប្រួលនៃសំណើលើកដំបូងទាំងនេះនឹងត្រូវបានជូនដំណឹងតាមរយៈលទ្ធផលរកឃើញអំពីការវិភាគ និងការពិភាក្សាតាមស្ថានភាពក្នុងប្រទេសនៃកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សាជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។

បញ្ជីដំបូងនៃប្រធានបទគោលនយោបាយចំនួន៤២ត្រូវបានផ្ដល់ជូនបុគ្គលិកកម្មវិធីសាកល្បងទប់ស្កាត់សិស្សក្នុងប្រទេសដើម្បីស្រាវជ្រាវ ហើយក៏ត្រូវបានកែតម្រូវមកនៅត្រឹមចំនួន៤១ប្រធានបទ ដោយបុគ្គលិកនៅកម្ពុជាបានបន្ថែមប្រធានបទមួយស្ដីពីប្រទេសកម្ពុជា។ រាល់ប្រធានបទទាំងអស់ត្រូវបានជ្រើសរើស ដោយសារតែគេបានបង្ហាញប្រធានបទទាំងនេះ ក្នុងគោលបំណងដើម្បីលើកទឹកចិត្តឲ្យឪពុកម្ដាយបញ្ជូនកូនទៅរៀន (ឧ. ការលុបបំបាត់រាល់ការបង់ថ្លៃនៅសាលារដ្ឋការហាមឃាត់ពលកម្មកុមារ) គាំទ្រដល់គ្រូបង្រៀន ក្នុងការផ្ដល់កម្មវិធីអប់រំដែលមានគុណភាព (ឧ.

---

[៩] ការពិនិត្យឡើងវិញនូវឯកសារស្រាវជ្រាវនៃកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា Creative Associates International, 2011។

ក្រមសីលធម៌គ្រូបង្រៀន ការប្រើប្រាស់ភាសាកំណើតនៅក្នុងថ្នាក់រៀន) ឬជួយឲ្យកុមារនៅ រៀនបន្ត (ឧ. សាលាកុមារមេត្រី ការផ្តល់ការថែទាំសុខភាពនៅក្នុងសាលា)។ ប្រធានបទទាំងនេះត្រូវបាន បែងចែកជា០៥ផ្នែក សម្រាប់ធ្វើរបាយការណ៍និងវិភាគ ៖

(១) *វិបទច្បាប់នៃការអប់រំ៖* ផ្នែកនេះថែងពីច្បាប់អប់រំនៃប្រទេស និងបទបញ្ញានៃការអនុវត្ត ការលើកឡើងនូវគំនិតស្តីពីភារកិច្ចនៃការទទួលខុសត្រូវ និងការអប់រំដោយឥតបង់ថ្លៃ និងសកម្មភាពនានាដែល តែងតែមានផលប៉ះពាល់លើកុមារក្នុងការទទួលបានការអប់រំ ដូចជា (ចំណាយលើឯកសណ្ឋានតាមតម្រូវការ ឬសម្ភារៈសិក្សា ការប្រឡងចូលរៀន ឬការប្រឡងបញ្ចប់ឆ្នាំ គោលនយោបាយយេនឌ័រ កង្វះសេវាសម្រាប់កុមារប្រឈមនឹង ការបោះបង់ ឬកុមារពិការ ប្រក្រតិទិនសាលាជំណាលគ្នានឹងរដូវធ្វើស្រែចម្ការ)។ នៅក្នុង ករណីភាគច្រើន ច្បាប់ចែងអំពីទស្សនវិជ្ជា ឬគោលវិធីនៃការអប់រំ ប៉ុន្តែសំណួរសួរថា តើច្បាប់នេះត្រូវបានអនុវត្តពេញលេញឬយ៉ាងណានោះបង្ហាញថា វាជាគោលដៅមួយ ច្រើនជាងអ្វីដែលមានពិតប្រាកដនាពេលបច្ចុប្បន្ន។ បញ្ហាសំខាន់ដែលត្រូវពិចារណានោះ គឺថា តើទស្សនវិជ្ជា និងកម្មវិធីសិក្សាដែលមានស្រាប់នេះផ្តល់នូវជម្រើសនានាទាក់ទងនឹង អ្វីសិស្សអាចសិក្សា ដូចជាជម្រើសសម្រាប់កម្មវិធីអប់រំតាមជម្រើស ឬតាមវិជ្ជាជីវៈ។

(២) *អគារសិក្សា។*
ប្រធានបទនៅក្នុងផ្នែកនេះរួមមានការផ្តល់អគារសិក្សាដែលសិស្សអាចចូលរៀនបាន និងអគារសាលាកុមារមេត្រី និងអន្តេវាសិកដ្ឋាន ឬកន្លែងស្នាក់នៅ។ នេះគឺជា "ឧប ករណ៍" នៃការអប់រំ ទិន្នន័យស្តីពីអគារសិក្សា ដែលអាច ឬមិនអាចទាក់ទាញចំណាប់អារម្មណ៍ របស់សិស្ស។

(៣) *ការជ្រើសរើស ការបណ្តុះបណ្តាល និងឥរិយាបថគ្រូបង្រៀននៅក្នុងថ្នាក់រៀន។* ផ្នែកនេះ ផ្តោតលើដំណើរការនៃការផ្តល់សេវាអប់រំ នៅក្នុងថ្នាក់រៀន ដោយផ្តើមឡើងនូវគុណវុឌ្ឍិ សម្រាប់គ្រូបង្រៀន និងការបណ្តុះបណ្តាលនៅក្នុងប្រទេសនីមួយៗ ដែលពួកគាត់ទទួល បាននិងបន្តនូវទិដ្ឋភាពសំខាន់ៗនៃឥរិយាបថរបស់ពួកគេនៅក្នុងបន្ទប់រៀន៖
តើពួកគាត់ប្រើភាសាកំណើតរបស់កុមារក្នុងពេលបង្រៀនដែរឬទេ? តើពួកគាត់ទម្លាប់ បង្រៀនក្នុងលក្ខណៈ "កុមារមេត្រី" ដែរឬទេ? តើពួកគាត់ដោះស្រាយយ៉ាងណាចំពោះ ឥរិយាបថមិនគប្បីរបស់សិស្ស?

(៤) *សេវាទ្រទ្រង់សាលារៀន៖* ក្រៅពីការបង្រៀននៅក្នុងថ្នាក់ តើសាលាជាច្រើនផ្តល់សេវា ទ្រទ្រង់ដែលអាចមានផលប៉ះពាល់ចម្បងទៅលើកុមារដែលចូលរៀនដែរឬទេ។ ផ្នែកនេះ

រួមមាន សេវានានាដូចជា មុខវិជ្ជាទាក់ទងសម្រាប់កុមារហួសអាយុចូលរៀន អាហារពេលរសៀល ការថែទាំសុខភាព ឬថ្នាក់ ឬក្លិបបំណិនជីវិត។

(៥) *ទម្លាប់អនុវត្តតាមវប្បធម៌៖* ផ្នែកចុងក្រោយនេះបង្ហាញពីទម្លាប់អនុវត្តតាមវប្បធម៌សំខាន់ៗ ដែលអាចមានផលប៉ះពាល់ទៅលើការបន្តនៅរៀនរបស់កុមារ ដូចជា កុមារដែលគ្រប់អាយុរៀបការ ការឆ្លើយតបទៅនឹងការមានគត៌ និងការរៀបចំពិធីតាមប្រពៃណីផ្សេងៗដែលកុមារត្រូវចូលរួម។

ការអនុវត្តតាមផ្នែកចម្បងនៃរបាយការណ៍នេះគឺ មាននៅឧបសម្ព័ន្ធ "ក" ដែលមានតារាងពន្យល់លម្អិតអំពីគោលនយោបាយ និងកម្មវិធីនានានៅក្នុងប្រទេសចូលរួមនីមួយៗ និងរៀបរាប់អំពីឯកសារ ធនធាន ក្រុមគោលដៅ ការបរិយាយអំពីការអនុវត្ត និងការវាយការណ៍អំពីផលប៉ះពាល់នៃគោលនយោបាយ និងកម្មវិធីទាំងនេះទៅលើអត្រាសិស្សបោះបង់។ នៅក្នុងករណីភាគច្រើន ការវាយតម្លៃជាផ្លូវការអំពីប្រសិទ្ធភាពនៃគោលនយោបាយ និងកម្មវិធីផ្សេងៗទាក់ទងនឹងសិស្សបោះបង់ការសិក្សាមិនទាន់មាននៅឡើយទេ។ ផ្ទុយទៅវិញ បុគ្គលិកក្នុងប្រទេសរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា បានជួបពិភាក្សាជាមួយមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អ្នកតំណាងទីភ្នាក់ងារផ្តល់មូលនិធិ ឬអនុវត្តការងារ និងអ្នកឯកទេសផ្នែកអប់រំក្នុងស្រុក ដើម្បីទទួលបានការចាប់អារម្មណ៍អំពីផលប៉ះពាល់ទៅលើសិស្សបោះបង់ការសិក្សា។

## II. *គោលនយោបាយ និងកម្មវិធី*

### ក. បរិបទច្បាប់នៃការអប់រំ

តារាងទី១បង្ហាញពីបរិបទគោលនយោបាយនៅក្នុងប្រទេសកម្ពុជា ទាក់ទងនឹងការផ្តល់ការអប់រំដោយឥតបង់ថ្លៃ និងការអប់រំជាភារកិច្ចទទួលខុសត្រូវលើការអប់រំ។ ៥ជួរដំបូងនិយាយអំពីបញ្ហានៃលក្ខណៈអប់រំ ដែលជា "ភារកិច្ចទទួលខុសត្រូវលើការអប់រំ" តាមរយៈការបរិយាយថាតើប្រទេសនេះគាំទ្រការអប់រំ ជាសិទ្ធិរបស់កុមារដែរឬយ៉ាងណានោះ បានអនុម័តច្បាប់ដែលតម្រូវឲ្យចូលរៀន បានហាមឃាត់ពលកម្មកុមារ (ដែលទំនងជាអាចបណ្តាលឲ្យកុមារនៅក្រៅសាលាឲ្យសាលា ទទួលខុសត្រូវក្នុងការឆ្លើយតបទៅនឹងបទដ្ឋានដែលរដ្ឋបានកំណត់ និងធានាថាកុមារគ្រប់រូបបានចូលរៀន។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ១៩៩៣ និងត្រូវបានធ្វើវិសោធនកម្មនៅក្នុងឆ្នាំ១៩៩៩ ការពារសិទ្ធិកុមារក្នុងទទួលបានការអប់រំ ហើយ ប្រទេសនេះបានទទួលស្គាល់អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិសិទ្ធិកុមារ ដែលរួមមាន សិទ្ធិកុមារក្នុងការទទួលបានការអប់រំ ប៉ុន្តែប្រទេសនេះមិនបានធ្វើឲ្យការអប់រំកម្រិតបឋមសិក្សា *ទៅជាភារកិច្ចទទួលខុសត្រូវលើការអប់រំនៅឡើយទេ។* ក្រសួងអប់រំ យុវជន និងកីឡា

កំពុងធ្វើការដើម្បីធានាឲ្យបាននូវការចូលរៀនអាយុ០៦ឆ្នាំ ភាគច្រើនតាមរយៈយុទ្ធនាការស្វែងរកមតិគាំទ្រ។ ប្រទេសកម្ពុជាកំណត់ពលកម្មសម្រាប់កុមារអាយុក្រោម ១៥ឆ្នាំ ប៉ុន្តែ បុគ្គលិកកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សាបានធ្វើអត្ថាធិប្បាយថា ការកំណត់ទាំងនេះមិនរាប់បញ្ចូលវិស័យអប់រំក្រៅប្រព័ន្ធ ដែលកុមារភាគច្រើនកំពុងធ្វើការ ភាគច្រើននៅក្នុងសហគ្រាសតាមគ្រួសារ ដូចជា កសិដ្ឋាននៅតំបន់ជនបទ។ ស្រដៀងគ្នានេះដែរ ប្រទេសនេះមានតម្រូវការថ្នាក់ជាតិដើម្បីត្រួតពិនិត្យសាលារៀន និងការធានាថា បទបញ្ញាទាំងនេះត្រូវបានអនុវត្ត ប៉ុន្តែមិនមានកម្មវិធីជាក់លាក់ណាមួយធានាថា សាលារៀនត្រូវមានការទទួលខុសត្រូវក្នុងការឆ្លើយតបទៅនឹងរាល់បទដ្ឋានដែលបញ្ជាក់ដោយរដ្ឋាភិបាលសម្រាប់ការអប់រំ និងមិនមានភាពសមមូលនៃ "មន្ត្រីតាមដានសិស្សគេចសាលា" ដើម្បីពិនិត្យមើលថា តើកុមារចុះឈ្មោះចូលរៀន ហើយនៅរៀនឬយ៉ាងណា។ ដូច្នេះ គេអាចនិយាយបានថា ប្រទេសកម្ពុជា *លើកទឹកចិត្ត*ឲ្យចូលរៀន ប៉ុន្តែមិនចាំបាច់ត្រូវតែរៀននោះទេ ដែលនេះជាការអនុវត្តមួយដែលអាចបង្កើតបានជាបញ្ហាចូលរៀនដែលក្នុងនោះកុមារមួយចំនួនមិនដែលចូលរៀន និងបង្កើតជាបញ្ហានៃភាពគង់វង្ស នៅពេលដែលកុមារអាចត្រូវសាលាបញ្ឈប់ពីការសិក្សាដោយមិនមានផលវិបាកដល់គ្រួសារ។

### តារាងទី១៖ គោលនយោបាយស្តីពីភារកិច្ចនៃការទទួលខុសត្រូវលើការអប់រំ និងការអប់រំដោយឥតបង់ថ្លៃនៅកម្ពុជា

| ប្រធានបទគោលនយោបាយ | ប្រទេសកម្ពុជា |
|---|---|
| ១. សិទ្ធិកុមារ | • រាប់បញ្ចូលសិទ្ធិទទួលបានការអប់រំនៅក្នុងស្ថាប័នរបស់ខ្លួន<br>• ទទួលស្គាល់អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ<br>• បានអនុម័តគោលនយោបាយសាលាកុមារមេត្រី ដែលធានាថា កុមារគ្រប់រូបទទួលបានការអប់រំ<br>• គាំទ្រគំនិតផ្តួចផ្តើមក្នុងការស្វែងរកការគាំទ្រនៅតាមសហគមន៍តាមរយៈអង្គការ យូនីសេហ្វ និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ ដើម្បីបញ្ជូនកុមារ ទៅសាលារៀន |
| ២. ភារកិច្ចនៃការទទួលខុសត្រូវ | គាំទ្រឲ្យមានការចុះឈ្មោះចូលរៀនកុមារអាយុ០៦ឆ្នាំគ្រប់រូបនៅថ្នាក់ទី១ ប៉ុន្តែការអប់រំមិនមែនជាភារកិច្ចទទួលខុសត្រូវលើការអប់រំនោះទេ |
| ៣. ច្បាប់ស្តីពីពលកម្មកុមារ | ហាមឃាត់កុមារក្រោមអាយុ១៥ឆ្នាំមិនឲ្យធ្វើការនៅកន្លែងឡូតដ្ឋនៃសាទគ្រី រោងចក្រ វិស័យផលិតស្បែកជើង និងសហគ្រាសដែលបង្កគ្រោះថ្នាក់។ អនុញ្ញាតឲ្យកុមារអាយុ១២ឆ្នាំ "ធ្វើការងារស្រាលៗ" |
| ៤. ភាពទទួលខុសត្រូវនៅសាលារៀន | • កំណត់បទដ្ឋានជាតិសម្រាប់ការអប់រំ និងតម្រូវឲ្យមានការត្រួតពិនិត្យ<br>• ប្រើប្រាស់មូលនិធិពីម្ចាស់ជំនួយដើម្បីពង្រឹងប្រព័ន្ធព័ត៌មានគ្រប់ |

| ប្រធានបទគោលនយោបាយ | ប្រទេសកម្ពុជា |
|---|---|
| | គ្រង |
| ៥. ការតាមដានសិស្សអវត្តមាន | តម្រូវឲ្យមានឯកសារស្តីពីអវត្តមានរបស់សិស្ស |
| ៦. ការបង់ថ្លៃសាលា | ហាមមិនឲ្យបង់ថ្លៃសម្រាប់ការអប់រំរយៈ៩ឆ្នាំដំបូង |
| ៧. ការឧបត្ថម្ភថ្លៃសិក្សា/អាហារូបករណ៍ | តាមរយៈគំនិតផ្តួចផ្តើមឲ្យសម្រេចបានការអប់រំឆាប់រហ័ស និងអង្គការមិនមែនរដ្ឋាភិបាលចំនួន៥៣ ផ្តល់អាហារូបករណ៍សម្រាប់កុមារក្រីក្រ |
| ៨. តម្រូវការឯកសណ្ឋាន | តម្រូវឯកសណ្ឋាន ហើយកម្មវិធីអង្គការមិនមែនរដ្ឋាភិបាលជាច្រើនបានឧបត្ថម្ភឯកសណ្ឋានជាផ្នែកមួយនៃកម្មវិធីអាហារូបករណ៍។ |
| ៩. ការផ្តល់សម្ភារៈសាលារៀន សៀវភៅសិក្សា, ជាដើម។ | ផ្តល់សម្ភារៈ និងឧបករណ៍ ជារឿយៗតាមរយៈកម្មវិធីអង្គការមិនមែនរដ្ឋាភិបាល |

តារាងទី២ ដល់តារាងទី៥បន្តការពិនិត្យឡើងវិញនូវបរិបទច្បាប់ នៅក្នុងប្រទេសកម្ពុជា ដោយបង្ហាញនូវបញ្ជីនៃកត្តានានាដែលគេស្គាល់ថា បង្អាក់កុមារមិនឲ្យ*ទទួលបានការអប់រំ* និង*រៀនបានគង់វង្សតទៅមុខ*។ កត្តាទាំងនេះរួមមានគោលនយោបាយ និងការអនុវត្តរបស់ប្រទេសទាក់ទងនឹង៖

- *ការប្រឡង*ដែលគេអាចតម្រូវឲ្យកុមារចូលរៀនថ្នាក់ថ្មី ឬបញ្ចប់ការសិក្សាពីថ្នាក់មួយទៅថ្នាក់មួយ ឬពីវដ្តមួយទៅវដ្តមួយទៀត។
- *ការឡើងថ្នាក់*សាលារៀនមានកូតាសិស្សដែលគេតម្រូវឲ្យប្រឡងជាប់ ឬគោលនយោបាយស្តីពីការឡើងថ្នាក់ដោយស្វ័យប្រវត្តិ។
- *ការកំណត់ វដ្តនៃការសិក្សា* ដូច្នេះ កុមារអាច "ហួសអាយុ"ចូលរៀន ទោះបីជាពួកគេមិនទាន់បានបញ្ចប់ការសិក្សាដែលគេតម្រូវក៏ដោយ។
- *យេនឌ័រ*អាចលើកទឹកចិត្តកុមារីឲ្យចូលរៀន និងបន្តការសិក្សារបស់ខ្លួន ឬបង្កើតជារនាំងសម្រាប់ពួកគេ។
- *សេវាសម្រាប់កុមារប្រឈមនឹងការបោះបង់ការសិក្សា* និងកុមារពិការ ដែលអាចត្រូវគេផាត់ចេញ ដោយសារតែវណ្ណៈ កុលសម្ព័ន្ធ ភាសា ឬបញ្ហាផ្លូវកាយ/ផ្លូវចិត្ត។
- *ប្រក្រតិទិនសាលារៀន* ដែលអាច ឬមិនអាចស្របទៅតាមកាលវិភាគធ្វើស្រែចម្ការ ឬនេសាទត្រី របស់គ្រួសារនីមួយៗ
- *និយាមថ្នាក់រៀន* ដែលមានសិស្សច្រើនអាចបណ្តាលឲ្យ "បាត់"កុមារមួយចំនួន។
- *ចម្ងាយពីផ្ទះទៅសាលារៀន* ដែលឆ្ងាយអាចបណ្តាលឲ្យឪពុកម្តាយសិស្សមានអារម្មណ៍ថាគ្មានសុវត្ថិភាព ឬមិនសមឲ្យកុមារធ្វើដំណើរទៅសាលារៀននោះទេ។
- *ការផ្តល់ការដឹកជញ្ជូន* ដើម្បីឲ្យកុមារដែលរស់នៅឆ្ងាយពីសាលាអាចធ្វើដំណើរទៅរៀនបានដោយងាយស្រួល។

- *តម្រូវការផ្ទេរសាលា* ដែលអាចសម្រួលដល់កុមារដែលគ្រួសាររបស់កុមារនោះផ្លាស់លំនៅពីកន្លែងមួយទៅកន្លែងមួយ។

## តារាងទី២៖ គោលនយោបាយស្តីពីការប្រឡង និងការឡើងថ្នាក់នៅកម្ពុជា

| ប្រធានបទគោលនយោបាយ | ប្រទេសកម្ពុជា |
|---|---|
| ១០.ការប្រឡងចូលរៀន | គ្មាន |
| ១១.កូតាឡើងថ្នាក់ | គ្មាន |
| ១២.ការឡើងថ្នាក់ដោយស្វ័យប្រវត្តិ | តម្រូវឲ្យសិស្សប្រឡងជាប់ នៅដំណាច់ឆមាសនីមួយៗដើម្បីឡើងថ្នាក់ |
| ១៣.ការកំណត់វដ្តនៃការសិក្សា | គ្មាន |
| ១៤.ការប្រឡងបញ្ចប់ការសិក្សា | តម្រូវឲ្យប្រឡងនៅពេលបញ្ចប់ថ្នាក់ទី១២ |

ចំពោះតម្រូវការប្រឡង និងឡើងថ្នាក់ ដូចមានបង្ហាញនៅក្នុងតារាងទី២ ប្រទេសកម្ពុជាមិនមានការប្រឡងចូលរៀនសម្រាប់សាលាបឋមសិក្សា ឬមធ្យមសិក្សា មិនមានការកំណត់វដ្តនៃការសិក្សា ឬវដ្តនៃការអប់រំ និងមិនមានកូតាឡើងថ្នាក់នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជាតម្រូវឲ្យសិស្ស ប្រឡងជាប់នៅដំណាច់ឆមាសនីមួយៗ ដើម្បីឡើងថ្នាក់ ហើយប្រទេសនេះបានអនុវត្តការប្រឡងបញ្ចប់វដ្តអប់រំសម្រាប់សាលាមធ្យមសិក្សា ដើម្បីធានាថាសិស្សគ្រប់រូបបានសិក្សានូវឯកសារចាំបាច់។ ការលើកហេតុផលអំពីការប្រឡងបែបនេះគឺថាក្រសួងអប់រំចង់ធានាថា កុមារទទួលបានការអប់រំដ៏មានគុណភាព និងការសិក្សានូវឯកសារដែលគេបានបង្ហាញ។ ទោះបីជានេះគឺជាគោលដៅដ៏គួរឲ្យកោតសរសើរក៏ដោយ ក៏តម្រូវការបែបនេះអាចនាំឲ្យសិស្សបោះបង់ការសិក្សា នៅពេលដែលការពិនិត្យឡើងវិញនូវឯកសារស្រាវជ្រាវលើកដំបូងរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សាបង្ហាញថា កុមារដែលហួសអាយុចូលរៀន (ជារឿយៗ ដោយសារពួកគេរៀនត្រួតថ្នាក់) សម្រេចចិត្ត ឈប់រៀន។

តារាងទី៣សង្ខេបព័ត៌មានស្តីពីគោលនយោបាយសម្រាប់ការទទួលការអប់រំស្មើភាពគ្នា និងការរៀនបន្ត ដោយមិនគិតពីភេទ ស្ថានភាពសិស្សប្រឈមនឹងការបោះបង់ការសិក្សា (ឧ. កុមារកំព្រា ជនជាតិភាគតិច) ចំណូលគ្រួសារ ឬពិការភាព។ ប្រទេសកម្ពុជាមានកម្មវិធីជាច្រើនដែលគាំទ្រដល់កុមារី ក្នុងនោះកម្មវិធីមួយចំនួនធ្វើប្រតិបត្តិការជាមួយរដ្ឋាភិបាល និងមួយចំនួនទៀតធ្វើប្រតិបត្តិការតាមរយៈអង្គការមិនមែនរដ្ឋាភិបាល៖ អ្នកប្រឹក្សាយោបល់សម្រាប់កុមារី ការបណ្តុះបណ្តាលការយល់ដឹងអំពីយេនឌ័រ អាហារូបករណ៍ និងគណៈកម្មាធិការក្រុមប្រឹក្សាកុមារីនៅក្នុងតំបន់ដាច់ស្រយាល។ ការគាំទ្រដល់សិស្សប្រឈមនឹងការបោះបង់ការសិក្សាក៏ជាផ្នែក

ចម្បងមួយនៃគោលនយោបាយអប់រំនេះផងដែរ ហើយការគាំទ្រនេះផ្តល់នូវកម្មវិធីជាច្រើនភាគច្រើនតាម រយៈអង្គការមិនមែនរដ្ឋាភិបាល។ គម្រោងអប់រំបញ្ចូលគ្នាបានពង្រីកសេវាសម្រាប់កុមារពិការរហូតដល់១៥ខេត្ត ក្នុងនោះ១២ខេត្តផ្តល់ថ្នាក់បញ្ចូលគ្នា សម្រាប់កុមារថ្លង់ និងពិការភ្នែក។ គោលនយោបាយថៃទាំតាមជម្រើស ដែលត្រូវបានអនុវត្តនៅក្នុងឆ្នាំ២០០៦ តម្រូវឲ្យមានការវាយតម្លៃលើតម្រូវការជាប្រចាំរបស់កុមារកំព្រា និងកុមារងាយរងគ្រោះ និងបង្កើនសេវាឲ្យបានច្រើនថែមទៀតដើម្បីឲ្យកុមារទាំងនេះទទួលបានការអប់រំ។ អង្គការមិនមែនរដ្ឋាភិបាលកំពុងធ្វើការដោះស្រាយលទ្ធភាពទទួលបានការអប់រំ និងការបញ្ចប់ការសិក្សាតាមរយៈការប្រឹក្សាយោបល់អំពីអ្នកដែលអវត្តមាន។ ការបណ្តុះបណ្តាលដើម្បីបង្កើនភាពរំញោចផ្នែកវប្បធម៌ ការបណ្តុះបណ្តាលពិសេសដល់គ្រូបង្រៀន និងការផ្តល់សេវាអប់រំដល់កុមារពិការ។ វាជាការសំខាន់ក្នុងការពិនិត្យមើលកម្រិតនៃភាពជោគជ័យដោយការខិតខំប្រឹងប្រែងទាំងនេះ ពីព្រោះកម្រិតនៃភាពជោគជ័យមួយចំនួនតូចមិនទាន់ត្រូវបានវាយតម្លៃនៅឡើយទេ។ អង្គការមិនមែនរដ្ឋាភិបាលមួយ[២] គឺអង្គការ VSO បានវាយតម្លៃលើផលប៉ះពាល់នានា ដោយរាយការណ៍ថាជាទូទៅអត្រាសិស្សបោះបង់បានធ្លាក់ចុះ នៅកន្លែងដែលមានសេវាទាំងនេះ។

### តារាងទី៣៖ គោលនយោបាយ និងកម្មវិធីគាំទ្រកុមារី និងសិស្សប្រឈមនឹងការបោះបង់ការសិក្សានៅកម្ពុជា

| ប្រធានបទគោលនយោបាយ | ប្រទេសកម្ពុជា |
|---|---|
| ១៥.គោលនយោបាយទាក់ទងនឹងយេនឌ័រ | ផ្តល់អ្នកប្រឹក្សាយោបល់សម្រាប់កុមារី ការបណ្តុះបណ្តាលការយល់ដឹងអំពីយេនឌ័រ ដល់មន្ត្រី និងគ្រូបង្រៀន ការទទួលបានស្មើគ្នានូវកម្មវិធីសិក្សា អាហារូបករណ៍ និងកីឡា និង តម្រូវឲ្យមានគណៈកម្មាធិការក្រុមប្រឹក្សាកុមារីនៅតំបន់ដាច់ស្រយាល ជាពិសេស នៅកន្លែងដែលមានអន្តេវាសិកដ្ឋានសម្រាប់កុមារី ដើម្បីតាមដានអវត្តមាន និងពិនិត្យមើល គុណភាពនៃការរៀនសូត្រ។ |
| ១៦.ការគាំទ្រដល់សិស្សប្រឈមនឹងការបោះបង់ការសិក្សា | តម្រូវឲ្យមានសិទ្ធិស្មើគ្នាក្នុងការទទួលបានការអប់រំដែលមានគុណភាពសម្រាប់កុមារពិការ និងកុមារប្រឈមនឹងការបោះបង់ការសិក្សា បណ្តុះបណ្តាលគ្រូបង្រៀន កុមារពិការ និងមាន កម្មវិធីអង្គការមិនមែនរដ្ឋាភិបាលដែលប្រឹក្សាយោបល់ដល់កុមារីបោះបង់ការសិក្សា បង្កើនរំញោចដល់ជនជាតិភាគតិច និងគាំទ្រកុមារប្រឈមនឹងការបោះបង់ការសិក្សាជាមួយនឹងសេវាអប់រំ។ |

[២] វាអាចជាករណីមួយដែលក្រុមផ្សេងទៀតបានវាយតម្លៃលើកម្មវិធីទាំងនេះ។ ទោះបីជាយ៉ាងនោះក្តី របាយការណ៍នេះអាចរកបានតែនៅពេលបង្ហាញអំពីលទ្ធផលទាំងនេះប៉ុណ្ណោះ ដូច្នេះ វាលំបាកក្នុងការរកវា ណាស់។

តារាងទី៤ សង្ខេបអំពីគោលជំហររបស់កម្ពុជានៅលើបញ្ហាផ្សេងៗ ដែលមានទំនាក់ទំនងនៅក្នុងឯកសារស្រាវជ្រាវស្តីពីការទទួលបានការអប់រំ និងភាពគង់វង្ស។ ទីមួយនិយាយអំពីប្រក្រតិ ទិនសាលា។ ដោយសារតែកុមារភាគច្រើនត្រូវគ្រួសាររបស់ខ្លួនតម្រូវឲ្យធ្វើស្រែចម្ការ ឬនេសាទត្រីទៅតាមរដូវនៅពេលដែលមានតម្រូវការឲ្យជួយធ្វើការបន្ថែម បានជាពួកគេអាចអវត្តមានច្រើន សប្តាហ៍ក្នុងអំឡុងពេលសិក្សា។ ពួកគេអវត្តមានអាចដោយសារតែពួកគេរៀនមិនទាន់គេ ដែលជាហេតុនាំឲ្យពួកគេត្រូវរៀនត្រួតថ្នាក់។ ប្រទេសកម្ពុជាមានប្រក្រតិទិនសាលាតឹងរឹង ទោះបីជាខ្លួនបានអនុញ្ញាតឲ្យអង្គការមិនមែនរដ្ឋាភិបាលមួយ (អង្គការណ៍រវើសង្គ្រោះកុមារ) សាកល្បងប្រើប្រាស់កាលវិភាគដែលអាចផ្លាស់ប្តូរបាន។ អង្គការណ៍រវើសង្គ្រោះកុមារបានរាយការណ៍ថា ភាពអាចផ្លាស់ប្តូរនេះបានកាត់បន្ថយចំនួនកុមារដែលត្រូវរៀនត្រួតថ្នាក់។

## តារាងទី៤៖ គោលនយោបាយ
## និងកម្មវិធីស្តីពីបញ្ហានៃការទទួលបានការអប់រំ/បញ្ហានៃភាពគង់វង្សនៅកម្ពុជា

| ប្រធានបទគោលនយោបាយ | ប្រទេសកម្ពុជា |
|---|---|
| ១៧.ប្រក្រតិទិនសាលា | មានគោលនយោបាយរក្សាប្រក្រតិទិនសាលាឲ្យបានតឹងរឹង ហើយកម្មវិធីអង្គការ មិនមែនរដ្ឋាភិបាលមួយបានសាកល្បងប្រើកាលវិភាគដែលអាចផ្លាស់ប្តូរបាន។ |
| ១៨.និយាមថ្នាក់រៀន | កំណត់និយាមថ្នាក់រៀនត្រឹម៥៥នាក់នៅសាលាបឋមសិក្សា។ |
| ១៩. លទ្ធភាពនៃការទៅដល់សាលារៀន/ចម្ងាយទៅកាន់សាលា | គ្មានការកំណត់ |
| ២០. ការដឹកជញ្ជូន | មានកម្មវិធីអង្គការមិនមែនរដ្ឋាភិបាលជាច្រើនឧបត្ថម្ភកង់ ឬរទេះរុញដល់កុមារដែលរស់នៅតំបន់ឆ្ងាយ។ |
| ២១.ការផ្ទេរសាលា | អនុញ្ញាតឲ្យផ្ទេរសាលាមធ្យមសិក្សាជាផ្លូវការតែនៅក្នុងខែកញ្ញា និងមីនាប៉ុណ្ណោះ |

៥ចំណុចផ្សេងទៀតនៅក្នុងតារាងទី៤បង្ហាញថា ប្រទេសកម្ពុជាមានបទបញ្ញាជាច្រើន ដែលក្នុងនោះមួយចំនួនក្នុងចំណោមបទបញ្ញាទាំងនោះបង្កើនលទ្ធភាពនៃការទទួលបាន មួយចំនួនពង្រឹងគុណភាព និងមួយចំនួនទៀតមិនមានអ្វីគួរឲ្យកត់សម្គាល់នោះទេ។ ដើម្បីបង្កើនលទ្ធភាពនៃការទទួលបាននេះ ប្រទេសកម្ពុជាបានពង្រីកនិយាមថ្នាក់រៀនរបស់ខ្លួនរហូតដល់៥៥នាក់ដោយមានការព្រមព្រៀងគ្នាបើប្រៀបធៀបទៅ វាជាចំនួនដ៏ច្រើនមួយក្នុងចំណោមសមភាគីរបស់ខ្លួននៅអាស៊ីខាងកើត។និយាមថ្នាក់រៀនដែលមានសិស្សច្រើនមានន័យថា កុមារអាច "បាត់បង់" ដោយមិនបានឆ្លើយតបទៅនឹងតម្រូវការនោះទេ ដូច្នេះ និយាមនេះអាចបណ្តាលកុមារមួយចំនួនបោះបង់ការសិក្សា។ ទោះបីជាពួកគេកំពុងធ្វើការដើម្បី "បង្កើតសាលារៀននៅក្បែរកន្លែងដែលប្រជាពលរដ្ឋ

រស់នៅ"ក៏ដោយ ក៏បច្ចុប្បន្ននេះមិនមានការលំបាកណាមួយចំពោះចម្ងាយផ្លូវ ដែលកុមារត្រូវធ្វើដំណើរទៅសាលារៀននោះទេ។ ដូច្នេះ ការធ្វើដំណើរទៅមកប្រចាំថ្ងៃអាចជាការបំបាក់ទឹកចិត្តកុមារ ហើយឪពុកម្តាយអាចយល់ឃើញថាចម្ងាយនោះមិនមានសុវត្ថិភាពសម្រាប់កុមារ (ជាពិសេសកុមារី) ក្នុងការធ្វើដំណើរទៅមករាល់ថ្ងៃ ដែលជាហេតុនាំឲ្យកុមារបោះបង់ការសិក្សា។ អង្គការមិនមែនរដ្ឋាភិបាលកំពុងធ្វើការកាត់បន្ថយបញ្ហានេះ តាមរយៈការផ្តល់កង់ឲ្យកុមារដែលរស់នៅឆ្ងាយ ជាទូទៅ ជាផ្នែកមួយនៃកម្មវិធីអាហារូបករណ៍របស់ពួកគេ។ ជាចុងក្រោយនេះ ប្រទេសកម្ពុជាមានគោលនយោបាយផ្ទេរសាលាដ៏តឹងរឹងមួយ ពោលគឺ ការផ្ទេរសាលាអាចធ្វើទៅបានតែនៅពេលចាប់ផ្តើមចូលរៀនប៉ុណ្ណោះ ដូច្នេះកុមារដែលមានគ្រួសារផ្លាស់ប្តូរទីលំនៅអាចត្រូវរង់ចាំអស់រយៈពេលជិតមួយឆ្នាំដើម្បីចុះឈ្មោះចូលរៀនជាថ្មីបន្ទាប់ពីការផ្លាស់ប្តូរនេះ។ គោលនយោបាយនេះក៏អាចនាំឲ្យសិស្សបោះបង់ការសិក្សាផងដែរ។

## ខ. អគារសិក្សា

តារាងទី៥ ពិភាក្សាអំពីគោលនយោបាយសំខាន់ៗពីរទាក់ទងនឹងអគារសិក្សា។ ដូចដែលមាននៅក្នុងតារាងខាងក្រោមនេះ ប្រទេសកម្ពុជាបានចូលរួមកសាងសាលា និងការកែលម្អអគារសិក្សាជាច្រើនដើម្បីព្យាយាមកាត់បន្ថយចម្ងាយ ដែលកុមារត្រូវធ្វើដំណើរទៅកាន់សាលាឲ្យកាន់តែនៅជិតផ្ទះបំផុត និងធ្វើឲ្យអគារសិក្សាទាំងនោះកាន់តែមានលក្ខណៈកុមារមេត្រីថែមទៀត។ ពួកគេក៏បានចូលរួមក្នុងការកសាងអន្តេវាសិកដ្ឋានសម្រាប់កុមារីដើម្បីជួយបង្កើនអត្រាបញ្ចប់ការអប់រំកម្រិតមូលដ្ឋានសម្រាប់កុមារី។

**តារាងទី៥៖ គោលនយោបាយ និងកម្មវិធីទាក់ទងនឹងអគារសិក្សានៅកម្ពុជា**

| ប្រធានបទគោលនយោបាយ | ប្រទេសកម្ពុជា |
|---|---|
| ២២.លទ្ធភាពនៃការទទួលបានការអប់រំ និងអគារសិក្សាកុមារីមេត្រី | • ចូលរួមកសាងសាលារៀន និងបន្ទប់រៀនជាច្រើន។<br>• ផ្តល់មូលនិធិតាមរយៈអង្គការយូនីសេហ្វដល់ផ្នែកកែលម្អសាលារៀនដោយលើកកម្ពស់អនាម័យ និងទឹកស្អាត។ |
| ២៣.អន្តេវាសិកដ្ឋាន/កន្លែងស្នាក់នៅសម្រាប់កុមារី | កសាងអន្តេវាសិកដ្ឋានសម្រាប់កុមារី ដើម្បីពួកគេអាចបញ្ចប់ការអប់រំកម្រិតមូលដ្ឋានថ្នាក់ទី៩។ |

## គ. ការជ្រើសរើស ការបណ្តុះបណ្តាល និងឥរិយាបថគ្រូបង្រៀននៅថ្នាក់រៀន

ក្រៅពីក្តីកង្វល់អំពីការបង្កើនចំនួនសិស្សចុះឈ្មោះចូលរៀន ប្រទេសកម្ពុជាក៏កំពុងជ្រើសរើសគ្រូបង្រៀនយ៉ាងសកម្មពីតំបន់ដែលខ្វះគ្រូ និងក្រុមប្រជាពលរដ្ឋដែលខ្វះអ្នកតំណាង (សូម

មើលតារាងទី៦)។ តំបន់ និងក្រុមទាំងនេះបានកាត់បន្ថយចំនួននៃឆ្នាំសិក្សាពោលគឺ ពីថ្នាក់ទី១២ មកនៅត្រឹមថ្នាក់ទី៩ ដែលតម្រូវឲ្យមានបេក្ខជនគ្រូបង្រៀននៅតំបន់ជនបទ និងដាច់ស្រយាល និងបានព្រមព្រៀងលើការជ្រើសរើសដ៏ពិសេសមួយក្នុងចំណោមជនជាតិចាម និងផ្តល់អាហារូបករណ៍ ដើម្បីរកសិក្ខាកាមមកពីតំបន់ដាច់ស្រយាល និងជួយគ្រូបង្រៀនសហគមន៍ក្នុងការកែលម្អជំនាញរបស់ពួកគាត់ ដើម្បីឲ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្នុងក្រុមគ្រូបង្រៀនជាប្រចាំ។ ក្រសួងអប់រំ យុវជន និងកីឡាមានក្តីរំពឹងខ្ពស់ចំពោះគ្រូបង្រៀន ប៉ុន្តែមានកម្មវិធីបណ្តុះបណ្តាលពិសេសតិចតួចនៅក្នុងការផ្តល់សេវាជាមុនឲ្យបានទៀងទាត់។

## តារាងទី៦៖ គោលនយោបាយ និងកម្មវិធីជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀន នៅកម្ពុជា

| ប្រធានបទគោលនយោបាយ | ប្រទេសកម្ពុជា |
|---|---|
| ២៨. ការជ្រើសរើសគ្រូបង្រៀន | • បេក្ខជនទាំងពីរភេទមកពីតំបន់ជនបទ និងដាច់ស្រយាលត្រូវប្រឡងចូលសាលាគរុកោសល្យ និងវិក្រឹតការដើម្បីធ្វើជាគ្រូបង្រៀន។ បេក្ខនារីត្រូវបានលើកទឹកចិត្តឲ្យចូលរួម ហើយក្នុងចំណោមនោះបេក្ខនារីប្រហែល៦០%ទទួលបានជោគជ័យ។<br>• តាមរយៈអង្គការ ខេប ជ្រើសរើសសិក្ខាកាម ជាពិសេសជនជាតិចាម។<br>• តាមរយៈអង្គការអប់រំពិភពលោក ប្រើប្រាស់អាហារូបករណ៍ដើម្បីជ្រើសរើសសិក្ខាកាមពីតំបន់ដាច់ស្រយាល និងជួយគ្រូបង្រៀនសហគមន៍ឲ្យក្លាយជាគ្រូបង្រៀនសាលារដ្ឋ។ |
| ២៩. ការអភិវឌ្ឍន៍ វិជ្ជាជីវៈគ្រូបង្រៀន | ធ្វើការកែលម្អគុណភាព និងប្រសិទ្ធភាពនៃការអប់រំតាមរយៈការផ្តល់ឲ្យគ្រូបង្រៀននូវបច្ចេកទេសទំនើបក្នុងការបង្រៀន និងការរៀនសូត្រ។ |

ចំណុចលម្អិតមួយនៅក្នុងច្បាប់ស្តីពីការអប់រំ គឺក្រមសីលធម៌គ្រូបង្រៀន ដែលមាន០៦ជំពូក និង៣០មាត្រា ដោយមានរៀបរាប់អំពីការទទួលខុសត្រូវទាំងស្រុងរបស់គ្រូបង្រៀន (សូមមើលតារាងទី៧)។ ការធ្វើទណ្ឌកម្មរាងកាយត្រូវបានហាមឃាត់ និងមានវគ្គពិសេសសម្រាប់គ្រូបង្រៀនថ្នាក់បឋមសិក្សានៅក្នុងសាលាមួយក្នុងចំណោមសាលាគរុកោសល្យជាច្រើន ដែលផ្តល់ឲ្យគ្រូបង្រៀននូវជំនាញ ក្នុងការទប់ស្កាត់រាល់អំពើសម្លុត ឬបំភិតបំភ័យកុមារពិការ ឬកុមារផ្សេងទៀតមកពីក្រុមជនជាតិភាគតិច។ គោលដៅច្បាស់លាស់ទាំងនេះត្រូវបានកំណត់នៅក្នុងឯកសារគោលនយោបាយរបស់ពួកគេ ដើម្បីធ្វើឲ្យសាលារៀនមានលក្ខណៈកុមារមេត្រី ហើយអង្គការមិនមែនរដ្ឋាភិបាលជាច្រើនកំពុងអនុវត្តកម្មវិធីនានា ដើម្បីធានាថា កត្តាទាំងនេះជាការប្រើប្រាស់នូវការអប់រំបញ្ចូលគ្នា បរិស្ថានមានសុខភាព និងសុវត្ថិភាព និងរំញោចយេនឌ័រ។

ដោយកុមារមកពីក្រុមជនជាតិភាគតិចមានការលំបាកយល់ភាសានៅពេលរៀន ប្រទេសកម្ពុជាក៏បានកំណត់គោលការណ៍ណែនាំអំពីការប្រើប្រាស់ភាសាកំណើតនៅថ្នាក់បឋមសិក្សា។ ខណៈពេលដែលពួកគេបានកំណត់ភាសាខ្មែរជាភាសាផ្លូវការសម្រាប់ការអប់រំ បង្រៀន (ជាពិសេសគ្រូបង្រៀននៅសាលាសហគមន៍) ត្រូវបានលើកទឹកចិត្តឲ្យប្រើប្រាស់កម្មវិធីសិក្សាពីរភាសា។ ធាតុផ្សំទាំងអស់នេះគួរតែដាក់បញ្ចូលគ្នាដើម្បីណែនាំកុមារភាគច្រើនឲ្យស្គាល់បរិយាកាស សាលារៀនដែលមានការលើកទឹកចិត្ត។ អ្វីដែលសំខាន់នាពេលឥឡូវនេះគឺត្រូវពិនិត្យមើលថា តើបទបញ្ញាទាំងនេះកំពុងត្រូវបានអនុវត្តយ៉ាងពិតប្រាកដ ហើយបទបញ្ញាទាំងនេះកំពុងតែមានអានុភាពយ៉ាងខ្លាំងទៅលើអត្រាចុះឈ្មោះចូលរៀន និងអត្រាសិស្សបោះបង់ឬយ៉ាងណា?

### តារាងទី៧៖ គោលនយោបាយ និងកម្មវិធីស្តីពីឥរិយាបថគ្រូបង្រៀននៅថ្នាក់រៀននៅកម្ពុជា

| ប្រធានបទគោលនយោបាយ | ប្រទេសកម្ពុជា |
|---|---|
| ២៦.ក្រមសីលធម៌គ្រូបង្រៀន | កំណត់ភារកិច្ចទទួលខុសត្រូវលើការអប់រំគ្រូបង្រៀន តួនាទី និងការទទួលខុសត្រូវរបស់ឪពុកម្តាយ និងសិស្ស ទំនាក់ទំនងរវាងគ្រូបង្រៀន និងសិស្ស, ការងារវិជ្ជាជីវៈគ្រូបង្រៀន និងទណ្ឌកម្មគ្រូបង្រៀនក្នុងករណីមានសិស្សណាម្នាក់បំពាន។ |
| ២៧.ការទប់ស្កាត់អំពើសម្លុត/បៀតបៀន | មានកម្មវិធីសម្រាប់គ្រូបង្រៀនសាលាបឋមសិក្សានៅសាលាគរុកោសល្យ និងវិក្រឹតការដើម្បីជួយពួកគេក្នុងការទប់ស្កាត់អំពើសម្លុត ឬបំភិតបំភ័យសិស្ស ដោយសារតែពួកគេពិការ ឬមកពីក្រុមជនជាតិផ្សេងៗ។ |
| ២៨.ទណ្ឌកម្មរាងកាយ | ទប់ស្កាត់ទណ្ឌកម្មរាងកាយ |
| ២៩. សាលាកុមារមេត្រី | អនុវត្តកម្មវិធីសាលាកុមារមេត្រីនៅកម្រិតបឋមសិក្សាតាមរយៈអង្គការមិនមែន រដ្ឋាភិបាលចំនួន០៦ និងនៅថ្នាក់មធ្យមសិក្សាតាមរយៈអង្គការមិនមែនរដ្ឋាភិបាលចំនួន០៤។ |
| ៣០.ភាសាអប់រំ | • កំណត់ភាសាខ្មែរជាភាសាអប់រំផ្លូវការ។<br>• បានបង្កើតគោលការណ៍ណែនាំអំពីការអប់រំពីរភាសាសម្រាប់ជនជាតិភាគតិច។<br>• លើកទឹកចិត្តឲ្យមានការរៀបចំសាលាសហគមន៍ជាមួយនឹងកម្មវិធីសិក្សាពីរភាសា។<br>• តាមរយៈ ICC/CARE, ផ្តល់កម្មវិធីជួយដល់ជនជាតិដើមភាគតិចឲ្យចេះអាន និងសរសេរភាសារខ្មែរ និងភាសារបស់ខ្លួន។ |

**តារាងទី៨** បង្ហាញនូវបញ្ជីរាយនាមទាក់ទងនឹងសកម្មភាពនានានៅក្នុងថ្នាក់រៀន ដោយលើកឡើងនូវរចនាសម្ព័ន្ធសម្ភារៈដែលត្រូវបង្ហាញដល់សិស្ស។ ក្រៅពីវគ្គសិក្សាជាប្រចាំផែនការយុទ្ធ សាស្ត្រសម្រាប់កម្មវិធីសិក្សាថ្នាក់បឋមសិក្សា មិនរាប់បញ្ចូលគោលការណ៍អំពី

ការអនុវត្តកម្មវិធីបង្កើនការសិក្សាសម្រាប់ក្រុមពិសេសនៃកុមារ។ ស្ថាប័នអប់រំក៏ត្រូវបានលើកទឹកចិត្តឲ្យផ្តល់ការអប់រំវិជ្ជាជីវៈ ហើយស្ថាប័នជាច្រើនធ្វើការលើកទឹកចិត្តតាមរយៈកម្មវិធីក្រៅប្រព័ន្ធ ដើម្បីលើកកម្ពស់ការអាន ការសរសេរ និងជំនាញវិជ្ជាជីវៈដល់មនុស្សពេញវ័យ និងកុមារហួសអាយុចូលរៀន និងផ្តល់ឲ្យពួកគេនូវជំនាញ វិជ្ជាជីវៈ និងកុំព្យូទ័រ។ ការវាស់វែងលទ្ធផលនៃកម្មវិធីទាំងនេះគឺថា កុមារតូចៗជាច្រើនដែលបានចូលរៀនកម្មវិធីអក្ខរកម្មត្រូវបានដាក់បញ្ចូលជាថ្មីទៅក្នុងសាលារដ្ឋ។

### តារាងទី៨៖ គោលនយោបាយ និងកម្មវិធីស្តីពីកម្មវិធីសិក្សានៅកម្ពុជា

| ប្រធានបទគោលនយោបាយ | ប្រទេសកម្ពុជា |
|---|---|
| ៣១.កម្មវិធីសាលាបឋមសិក្សា និងមធ្យមសិក្សា | ផ្តល់កម្មវិធីបង្កើនការសិក្សាសម្រាប់ក្រុមពិសេសៗនៅសាលាបឋមសិក្សា |
| ៣២.ការអភិវឌ្ឍជំនាញអប់រំវិជ្ជាជីវៈ | • ផ្តល់ការបណ្តុះបណ្តាលដែលមានបញ្ចូលនូវរាល់ "វិជ្ជាជីវៈ និងជំនាញទាំងអស់។<br>• អនុវត្តសកម្មភាពនៅក្នុងការអប់រំក្រៅប្រព័ន្ធដូចជា ជំនាញវិជ្ជាជីវៈ និងកុំព្យូទ័រ និងមានបញ្ចូលថ្នាក់អក្ខរកម្មតាមរយៈអង្គការមិនមែនរដ្ឋាភិបាលយ៉ាងតិច៨៣។ |

## ឃ. សេវាទ្រទ្រង់សាលារៀន

តារាងទី៩សង្ខេបសេវាបន្ថែមដែលត្រូវបានផ្តល់ដោយសាលារៀន ឬវិទ្យាស្ថានសហគមន៍ដែលអាចផ្តល់ជំនួយដល់សិស្ស និងឲ្យពួកគេនៅរៀនបន្ត។ ជាពិសេស ក្រៅពីកម្មវិធីវិជ្ជាជីវៈ និងអក្ខរកម្មដែលបានពិភាក្សាខាងលើ។ ប្រទេសកម្ពុជាមានកម្មវិធីបំប៉នបន្ថែមជាច្រើនទៀតសម្រាប់កុមារប្រឈមនឹងការបោះបង់ការសិក្សា និងផែនការចុះឈ្មោះចូលរៀនជាថ្មី ដើម្បីពង្រីកអគារសិក្សានៅសហគមន៍ ដូចជាបណ្ណាល័យ និងជំនាញរបស់បុគ្គលិកអប់រំក្រៅប្រព័ន្ធ ដើម្បីឲ្យសិស្សប្រឈមនឹងការបោះបង់ការសិក្សា ឬសិស្សដែលបានបោះបង់ការសិក្សាអាចមានភាពងាយស្រួលនៅសាលារៀន។

កម្មវិធីផ្សេងៗអាចរកបាននៅប្រទេសកម្ពុជា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស៖

- កម្មវិធីអាហារូបត្ថម្ភត្រូវបានផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាលចំនួន១៥ ដែលផ្តល់អាហារ ដល់កុមារថ្នាក់ទី១ដល់ទី៦ ឬផ្តល់របបអាហារយកទៅផ្ទះដល់កុមារថ្នាក់ទី៤ដល់ថ្នាក់ទី៦។

- ការថែទាំសុខភាព និងភាពជាដៃគូសុវត្ថិភាពសាលារៀនក្នុងចំណោមក្រសួង និងអង្គការមិនមែនរដ្ឋាភិបាល រួមមាន សេវាពិនិត្យសុខភាព ចាក់ថ្នាំវ៉ាក់សាំង និងអន្តរគមន៍ នៅពេលដែលជំងឺឆ្លងវាយលុក, ក្លឹបសុខភាព ការប្រឹក្សាយោបល់ ការអប់រំសុខភាព និងសុវត្ថិភាព។
- កម្មវិធីបំណិនជីវិត ដែលត្រូវបានផ្តល់នៅក្នុងថ្នាក់ដោយអង្គការមិនមែនរដ្ឋាភិបាលស្តីពីប្រធានបទផ្សេងៗ ដូចជាការជួសជុលកង់ ជំនាញកសិកម្ម ការដេរប៉ាក់ ការចម្អិនអាហារ ការដាំផ្សិត និងការរៀនកុំព្យូទ័រ និង
- ក្លឹបយុវជន ដែលអ្នកចូលរួមអាចទទួលបានការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ ធ្វើការស្ម័គ្រ ចិត្ត ឬចូលរៀនថ្នាក់អក្ខរកម្ម។

លើសពីនេះទៅទៀត ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តឲ្យមានការបង្កើត និងសកម្មភាពពីសមាគមមាតាបិតាសិស្ស ដើម្បីទ្រទ្រង់សាលារៀន ដោយបំពេញភារកិច្ចដូចជាការលើកកម្ពស់ការយល់ដឹងនៅសហគមន៍អំពីសារៈសំខាន់នៃការអប់រំ ការគាំទ្រដល់ការកសាងសាលារៀន ការផ្តល់មូលនិធិដល់គ្រូបង្រៀនក្រីក្រ និងការតាមដានការសិក្សារបស់កុមារ។

### តារាងទី៩៖ គោលនយោបាយ និងកម្មវិធីស្តីពីសេវាទ្រទ្រង់សាលារៀននៅកម្ពុជា

| ប្រធានបទគោលនយោបាយ | ប្រទេសកម្ពុជា |
|---|---|
| ៣៣.ការបង្រៀនគួរបន្ថែម/កម្មវិធីសិក្សាទាក់ទង | • ផ្តល់កម្មវិធីបំប៉នបន្ថែមដល់កុមារប្រឈមនឹងការបោះបង់ការសិក្សាតាមរយៈអង្គការមិនមែនរដ្ឋាភិបាលយ៉ាងតិច៥។<br>• មានផែនការសម្រាប់កម្មវិធីចុះឈ្មោះចូលរៀនជាថ្មី ដែលនឹងពង្រឹង និងពង្រីកមជ្ឈមណ្ឌលសិក្សានៅសហគមន៍ បណ្ណាល័យ និងមជ្ឈមណ្ឌលអានសៀវភៅ និងលើកកម្ពស់សមត្ថភាពរបស់បុគ្គលិកអប់រំក្រៅប្រព័ន្ធ។ |
| ៣៤.ការផ្តល់អាហារ | ផ្តល់អាហារពេលព្រឹកដល់សិស្សថ្នាក់ទី១-6នៅសាលាគោលដៅ និងផ្តល់របបអាហារយកទៅផ្ទះដល់សិស្សថ្នាក់ទី៤-6។ |
| ៣៥.ការគាំពារសុខភាពកុមារ | • ផ្តល់ "សិទ្ធិ"ទទួលបានការពិនិត្យសុខភាព។<br>• តម្រូវឲ្យមានកិច្ចសហប្រតិបត្តិការជាមួយសេវាសុខភាពសាធារណៈ ដូចជាការផ្តល់ថ្នាំវ៉ាក់សាំង អន្តរាគមន៍ទាន់ពេល ក្នុងការគ្រប់គ្រងមានជម្ងឺឆ្លង និងជំនួយសង្គ្រោះបន្ទាន់ លើកទឹកចិត្តដល់ក្លឹបសុខភាព ផ្តល់ការប្រឹក្សាយោបល់ លើកកម្ពស់អាហារូបត្ថម្ភ និងលើកកម្ពស់សុខភាពមាត់ធ្មេញ។<br>• ផ្តល់ឲ្យនាយកដ្ឋានក្រសួងនានានូវកម្មវិធីកម្ចាត់ដង្កូវព្រូន និងថ្នាំមានជាតិដែក សម្រាប់កុមារីអាយុលើស១៥ឆ្នាំ សុខភាពមាត់ធ្មេញ សុវត្ថិភាពផ្លូវថ្នល់ និងសុវត្ថិភាពអាហារ។<br>• ធានាឲ្យបាននូវល័ក្ខខ័ណ្ឌសុវត្ថិភាព និងអនាម័យនៅសាលារៀន និងការ |

| ប្រធានបទគោលនយោបាយ | ប្រទេសកម្ពុជា |
|---|---|
| | គាំពារសុខភាពកុមារ។ |
| ៣៦.រោងជាង/ថ្នាក់បំណិនជីវិត | អំពាវនាវឲ្យមានភាពជាដៃគូក្នុងស្រុកដើម្បីផ្ដល់កម្មវិធីបំណិនជីវិត ហើយអង្គការមិនមែនរដ្ឋាភិបាលបានអនុវត្តបែបនេះ។ |
| ៣៧.សកម្មភាពកម្មវិធីសិក្សាបន្ថែម | បង្កើតក្លឹបយុវជនតាមរយៈអង្គការមិនមែនរដ្ឋាភិបាល |
| ៣៨.ការចូលរួមពីសហគមន៍ | លើកទឹកចិត្តឲ្យមានការបង្កើតសមាគមមាតាបិតាសិស្ស និងការចូលរួមពីគ្រួសារក្នុងការគ្រប់គ្រងសាលារៀនមូលដ្ឋានរបស់ខ្លួន។ |
| ៣៩.ជំនាញប្រកបរបរចិញ្ចឹមជីវិតសម្រាប់ឪពុកម្ដាយ | គាំទ្រគម្រោងប្រកបរបរចិញ្ចឹមជីវិតសម្រាប់ឪពុកម្ដាយសិស្សដើម្បីរកចំណូលបន្ថែម។ |

## ង. ទម្លាប់អនុវត្តតាមវប្បធម៌

ទោះបីវាមិនមែនជាផ្នែកមួយនៃបទបញ្ញារបស់ក្រសួងសម្រាប់ការអប់រំក៏ដោយ ក៏ទម្លាប់អនុវត្តតាម វប្បធម៌មួយចំនួនអាចមានផលប៉ះពាល់ដល់លទ្ធភាពនៃការទទួលបានការអប់រំរបស់កុមារ និងសមត្ថភាពនៅរៀនបន្ត។ ទម្លាប់អនុវត្តបែបនេះរួមមាន អាយុរៀបការតាមប្រពៃណី ទំនៀមទម្លាប់រៀបពិធីតាមប្រពៃណីដែលអាចជ្រៀតជ្រែកដល់កាលវិភាគសាលារៀន និងក្ដីរំពឹងទុក ប្រសិនបើកុមារីមានផ្ទៃពោះ។ ដូចមានបង្ហាញនៅក្នុងតារាងទី១០ ប្រទេសកម្ពុជាមាន "ច្បាប់" ស្ត្រីតាមប្រពៃណី ដែលយើងហៅថា ច្បាប់ស្រី។ ច្បាប់នេះត្រូវបានបង្រៀននៅតាមគ្រួសារនៅទូទាំងប្រទេស និងកំណត់តួនាទី យេនឌ័រ និងបទបញ្ញាសម្រាប់ស្ត្រី។ ទោះបីជាច្បាប់នៅប្រទេសនេះចែងថា អាយុរៀបការស្របច្បាប់សម្រាប់បុរសគឺ២០ឆ្នាំ ហើយសម្រាប់ស្ត្រីគឺ១៨ឆ្នាំក៏ដោយ ក៏ច្បាប់ស្រីអនុញ្ញាតឲ្យកុមាររៀបការ នៅពេលដែលកុមារីនោះឈានដល់ភាពពេញវ័យ ជាទូទៅនៅថ្នាក់ទី៨ ឬទី៩។ ទោះបីជាសាលារៀនមិនមានគោលនយោបាយទប់ស្កាត់កុមារីដែលមានកូនមិនឲ្យវិលចូលរៀនវិញក៏ដោយ ក៏ច្បាប់ស្រីចែងថា កុមារនោះគួរនៅផ្ទះមើលកូន។ ជាចុងក្រោយនេះ ថ្វីបើការអប់រំត្រូវបានផ្ដល់ទៅឲ្យកុមារគ្រប់រូបរហូតដល់ថ្នាក់ទី១២ក៏ដោយ ក៏ឪពុកម្ដាយភាគច្រើនមិនឲ្យកូនរបស់ខ្លួនទៅរៀន និងទុកឲ្យពួកគេនៅធ្វើការផ្ទះរយៈពេលវែងមុនពេលបញ្ចប់សាលាមធ្យមសិក្សា។

### តារាងទី១០៖ ទម្លាប់អនុវត្តតាមវប្បធម៌នៅកម្ពុជា

| ប្រធានបទគោលនយោបាយ | ប្រទេសកម្ពុជា |
|---|---|
| ៤០. អាយុរៀបការ | កំណត់អាយុ២០ឆ្នាំសម្រាប់បុរស និង១៨ឆ្នាំសម្រាប់កុមារី ហើយអាយុនេះអាចត្រូវបានកាត់បន្ថយក្នុងករណីមានគភ៌ ដោយមានការព្រមព្រៀងពីឪពុកម្តាយ/អាណាព្យាបាល។ |
| ៤១. ការមានគភ៌ | មិនមានគោលនយោបាយទប់ស្កាត់កុមារីមិនឲ្យចុះឈ្មោះចូលរៀនជាថ្មីនោះទេ បន្ទាប់ពីសម្រាលកូនរួច ប៉ុន្តែមិនមានការអនុវត្តជាក់ស្តែងនោះទេ។ |
| ៤២. ទំនៀមទម្លាប់ផ្សេងៗ | ជាទូទៅ គ្រួសារក្រីក្រឲ្យកូនរបស់ខ្លួនឈប់រៀនដើម្បីរកប្រាក់ (ជាទូទៅកុមារី) |

## III. ជម្រើសសម្រាប់អន្តរាគមន៍នៃកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា (SDPP)

ប្រទេសកម្ពុជាមានគោលនយោបាយអប់រំដ៏ទូលំទូលាយមួយ ហើយប្រទេសនេះសម្បូរទៅដោយអង្គការមិនមែនរដ្ឋាភិបាល ដែលបានចូលយ៉ាងសកម្មនៅក្នុងវិស័យអប់រំ ដូចដែលបានលើកឡើងនូវអង្គការមិនមែនរដ្ឋាភិបាលចំនួន៥៣ ដែលបានផ្តល់កម្មវិធីអាហារូបករណ៍ជាច្រើន។ ចំណែកឯ នៅប្រទេសមួយចំនួន ការលើកយោបល់អំពីការងារជាមួយក្រសួងអប់រំ ដើម្បីបង្កើតគោលនយោបាយ គឺគោលវិធីដ៏ប្រសើរមួយក្នុងករណីដែលប្រទេសកម្ពុជាមានគោលនយោបាយអនុវត្តស្រាប់។ វាកាន់តែមានការពាក់ព័ន្ធក្នុងការជួយក្រសួងអប់រំកំណត់ថា តើគោលនយោបាយទាំងនេះត្រូវបានអនុវត្តយ៉ាងពេញលេញ និងធ្វើការយ៉ាងសកម្មដើម្បីឲ្យកុមារនៅរៀនបន្ត និងរៀនបានពូកែដែរឬយ៉ាងណា។ កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា (SDPP) អាចធ្វើអន្តរាគមន៍ដោយមានប្រសិទ្ធភាពតាមវិធីដូចខាងក្រោម៖

(១) វិភាគអានុភាពនៃតម្រូវការសម្រាប់ការបប្រឡងឆមាសស្តីពីអត្រាសិស្សបោះបង់ និងអត្រាត្រួតថ្នាក់ និងធ្វើការជាមួយគ្រូបង្រៀន ឬគណៈមេប្រយោគ ដើម្បីលើកកម្ពស់ឲ្យមានការវាយតម្លៃជាឧបករណ៍មួយដើម្បីបង្កើនការរៀនសូត្ររបស់សិស្ស។

ការប្រឡងបញ្ចប់ឆមាសភាគច្រើនទំនងជាតម្រូវឲ្យធានាថា សិស្សកំពុងសិក្សាឯកសារនៅក្នុងកម្មវិធីសិក្សា និងពិនិត្យមើលថាគ្រូបង្រៀននឹងផ្តល់គុណភាពអប់រំ ដែលពួកគាត់គួរផ្តល់។ ទោះជាយ៉ាងនោះក្តី ការប្រឡងអាចធ្វើឲ្យសិស្សបាក់ទឹកចិត្ត ជាពិសេស ប្រសិនបើពួកគេប្រឡងធ្លាក់។ អ្នកព្យាករណ៍ម្នាក់ក្នុងចំណោមអ្នកព្យាករណ៍ដ៏ខ្លាំងបំផុតជាច្រើននាក់អំពីសិស្សបោះបង់ការសិក្សា

ដែលត្រូវបានលើកឡើង នៅក្នុងការពិនិត្យឡើងវិញនូវឯកសារស្រាវជ្រាវលើកដំបូងរបស់ SDPP បានរៀនត្រួតថ្នាក់ ឬហួសអាយុចូលរៀន។ ប្រសិនបើការប្រឡងឆមាសទាំងនេះត្រូវបានរៀបចំដោយ គ្រូបង្រៀន បុគ្គលិក SDPP អាចស្វែងរកខ្លឹមសារនៃការប្រឡងនៅតាមសាលាបឋមសិក្សាផ្សេងៗ និងផលវិបាកសម្រាប់កុមារ បន្ទាប់មកចូលរួមក្នុងការបណ្តុះបណ្តាល និងផ្តល់យោបល់អំពីការវាយតម្លៃលើកុមារ ដើម្បីជួយគ្រូបង្រៀនក្នុងការប្រើប្រាស់ដំណើរការវាយតម្លៃជាបន្តបន្ទាប់ ដើម្បីវាស់វែងមិនត្រឹមតែការទទួលបានសច្ចភាពសម្រាប់កុមារប៉ុណ្ណោះទេ ប៉ុន្តែថែមទៀតការយល់ដឹងអំពីគំនិតនានា និងសមត្ថភាពក្នុងការប្រើប្រាស់ចំណេះដឹង។ ប្រសិនបើការប្រឡងទាំងនេះត្រូវបានកំណត់តាមបទដ្ឋាន និងត្រូវបានអនុវត្តទូទាំងពិភពលោក SDPP អាចធ្វើការជាមួយក្រុមប្រឹក្សា ឬគណៈត្រួតពិនិត្យដើម្បីបង្កើនសំណួរ និងចម្លើយ ដែលគេបានចោទសួរ ដោយកំណត់ពីទម្រង់ចម្លើយដែលត្រឹមត្រូវ។

(២)វាយតម្លៃលើផលវិបាកនៃនិយាមថ្នាក់រៀនដែលអាចដាក់សិស្សបាន៥៩នាក់ ស្វែករកជម្រើសសម្រាប់ជំនួយការគ្រូបង្រៀន និងផ្តល់ការបណ្តុះបណ្តាលពិសេសដល់គ្រូបង្រៀន ក្នុងការដោះស្រាយនិយាមថ្នាក់រៀនដែលមានសិស្សច្រើន ដើម្បីបង្កើនកម្រិតនៃការរៀនសូត្ររបស់សិស្ស និងកាត់បន្ថយអត្រាសិស្សបោះបង់ការសិក្សា។

ការកំណត់និយាមថ្នាក់រៀននៅកម្ពុជាខ្ពស់ជាងបណ្តាប្រទេសកំពុងអភិវឌ្ឍផ្សេងទៀត និងមានន័យថា កុមារដែលស្ងាត់ស្ងៀមបាត់បង់ ហើយជាយថាហេតុកុមារនោះអាចបោះបង់ការសិក្សាទៀតផង។ កុមារមួយចំនួនតូចទទួលបានការយកចិត្តទុកពិសេស ដែលពួកគេត្រូវការដើម្បីធានាថាពួកគេមាន ការយល់ដឹងអំពីឯកសារទាំងនោះ។ SDPP អាចត្រួតពិនិត្យនិយាមថ្នាក់រៀនបច្ចុប្បន្ននៅសាលាបឋមសិក្សា (និយាមថ្នាក់រៀនមួយចំនួនអាចមានចំនួនសិស្សតិច ដោយសារតែប្រជាពលរដ្ឋក្នុងមូលដ្ឋានតិច) ពិភាក្សាជាមួយក្រសួងអប់រំអំពីអន្តរាគមន៍ដែលអាចកើតមាន និងអនុវត្តការងារ។ ក្រសួងអប់រំអាចនឹងជួលជំនួយការគ្រូបង្រៀន ដែលអាចធ្វើការនៅក្រោមគ្រូបង្រៀនដែលមានសមត្ថភាពពេញលេញដើម្បីជួយដល់ក្រុមតូចៗ ឬកុមារម្នាក់ៗ ប៉ុន្តែយ៉ាងហោចណាស់ SDPP អាចផ្តល់កម្មវិធីបណ្តុះបណ្តាលដល់គ្រូបង្រៀនអំពីការធ្វើការជាមួយថ្នាក់រៀនដែលមានចំនួនសិស្សច្រើន ដើម្បីបង្ហាញគោលការណ៍ណែនាំសម្រាប់ការងារជាក្រុម ការប្រើកុមារធំៗឲ្យបង្រៀនកុមារតូចៗ ជាដើម។

(៣) លើកកម្ពស់ការអប់រំថ្នាក់ពីភាសានៅបឋមសិក្សាតាមរយៈ:

(ក)ការជួយបកប្រែសៀវភៅសិក្សាទៅជាភាសាជនជាតិភាគតិច (ខ)ការឲ្យគ្រូបង្រៀន និងឪពុកម្តាយបង្កើតសៀវភៅរឿងខ្លីៗសម្រាប់សិស្សដែលមានអាកប្បកិរិយានៃជនជាតិភាគតិច

ការកំណត់បញ្ហានានា និង/ឬ (គ)ធ្វើការជាមួយគ្រូបង្រៀនអំពីយុទ្ធសាស្ត្រ និងយុទ្ធវិធីដើម្បីប្រើប្រាស់ពហុភាសានៅក្នុងបន្ទប់រៀន។

គោលនយោបាយអប់រំនៅកម្ពុជាបង្ហាញនូវក្ដីកង្វល់ដ៏ធំមួយដែលថា កុមារនៅក្នុងក្រុមជនជាតិភាគតិចមានលទ្ធភាពទទួលបានការអប់រំតាមរយៈកម្មវិធីពីរភាសា ដែលគោរពតាមភាសាកំណើតរបស់ខ្លួន និងណែនាំភាសាខ្មែរ។ ទោះជាយ៉ាងនោះក្ដី កម្មវិធីនេះត្រូវបានបង្កើតឡើងដោយសារតែគេមិនទាន់បានបង្កើតសៀវភៅ និងកម្មវិធីសិក្សាពីរភាសា ហើយគ្រូបង្រៀនមិនទាន់មានជំនាញខាងបច្ចេកទេសអប់រំពីរភាសា។ SDPP អាចជួយដល់ដំណើរការនៃការផលិតសៀវភៅពីរភាសា និងណែនាំការប្រើប្រាស់សៀវភៅទាំងនោះដល់គ្រូបង្រៀននៅក្នុងមេរៀនបណ្ដុះបណ្ដាលទាក់ទងនឹងគរុកោសល្យ និងគាំទ្រគ្រូបង្រៀននៅឆ្នាំដំបូងនៃការប្រើប្រាស់សៀវភៅទាំងនេះ។ ជាជម្រើស SDPP អាចចូលរួមក្នុងគម្រោង សៀវភៅកុមារ ដោយអនុវត្តតាមគំរូនៃគម្រោងនានានៅបប្រទេសតាន់ហ្សានៀ ជាទីកន្លែងដែលអង្គការមិនមែនរដ្ឋាភិបាលមួយបាននាំមកនូវសមាជិកសហគមន៍អប់រំ ភាគច្រើន គ្រូបង្រៀនសាលាបឋមសិក្សា នៅក្នុងសិក្ខាសាលា ដែលសិក្ខាកាមទទួលបានការគាំទ្រ និងការលើកទឹកចិត្តឲ្យសរសេរ និងបកស្រាយរឿងរបស់កុមារ។ រឿងទាំងនេះអាចនិយាយអំពីប្រវត្តិនៃក្រុមជនជាតិភាគតិចរបស់ពួកគេ រឿងប្រឌិតដែលរៀបរាប់អំពីកុមារ និងគ្រួសារដូចពួកគេ ជីវប្រវត្តិនៃសមាជិកកុលសម្ព័ន្ធសំខាន់ៗ អត្ថបទរៀបរាប់អំពីរុក្ខជាតិ និងសត្វក្នុងស្រុក ឬរឿងផ្ទាល់ខ្លួន។ SDPP អាច "បោះពុម្ពផ្សាយ" រឿងល្អៗទាំងនេះ ដើម្បីផលិតឯកសារចម្លងឲ្យបានច្រើន ចែកចាយរឿងទាំងនេះដល់សាលាបឋមសិក្សាដែលពាក់ព័ន្ធ និងធ្វើការជាមួយគ្រូបង្រៀន ដើម្បីដាក់បញ្ចូលសៀវភៅទាំងនេះទៅក្នុងកម្មវិធីសិក្សា។

# ឧបសម្ព័ន្ធ "ក"៖
# តារាងគោលនយោបាយ
# និងកម្មវិធីសម្រាប់ប្រទេសកម្ពុជា

## *គោលនយោបាយ និងកម្មវិធីដែលអាចមានផលប៉ះពាល់លើសិស្សបោះបង់ការសិក្សានៅកម្ពុជា*

| *ប្រធានបទគោលនយោបាយឬកម្មវិធី* | *ឯកសារ* | *ក្រុមគោលដៅ* | *ការបរិយាយ/សេចក្តីអត្ថាធិប្បាយ* | *របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា* |
|---|---|---|---|---|
| *បរិបទច្បាប់នៃការអប់រំ* | | | | |
| ១. សិទ្ធិកុមារ | **រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៩[៣] មាត្រា៤៨៖** រដ្ឋត្រូវ ការពារសិទ្ធិកុមារ ដូចមានចែងនៅក្នុងអនុសញ្ញាស្តីពីកុមារជាពិសេស សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលការអប់រំ និងសិទ្ធិទទួលបានការការពារ ក្នុងអំឡុងពេលមានសង្គ្រាម និងរួចផុតពីការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច ឬការកេងប្រវ័ញ្ចផ្លូវភេទ។ រដ្ឋត្រូវការពារកុមារពីអំពើដែលបង្កការរងគ្រោះដល់ឱកាសអប់រំ សុខភាព និងសុខុមាលភាពរបស់ពួកគេ។ | កុមារ | ក្តីកង្វល់សំខាន់គឺថា ច្បាប់ការងារឆ្នាំ១៩៩៧ មិនរ៉ាប់រងលើវិស័យក្រៅប្រព័ន្ធ ដែលក្នុងនោះ "កុមារ ធ្វើការ" ជាង៩០% ត្រូវបានជួលឲ្យធ្វើការ។[៤] | |
| | **អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារដែលត្រូវបានផ្តល់សច្ចានុម័តដោយរាជរដ្ឋា** | កុមារ | រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលបានខិតខំប្រឹងប្រែងអនុវត្តតាមអង្គការ UNCRC និង | |

[៣] បានអនុម័តនៅឆ្នាំ១៩៩៣ និងធ្វើវិសោធនកម្មនៅឆ្នាំ១៩៩៩

[៤] អង្គការពលកម្មអន្តរជាតិ (ILO), អង្គការយូនីសេហ្វ និងធនាគារពិភពលោក ឆ្នាំ២០០៦។*ការងារកុមារនៅកម្ពុជា៖ បញ្ហាប្រឈមចំពោះការរីកលូតលាស់ និងការកាត់បន្ថយភាពក្រីក្រ*, p. ii and v។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | **ភិបាលកម្ពុជាឆ្នាំ១៩៩២ មាត្រា២៣, ២៨-៣២** ទទួលស្គាល់សិទ្ធិកុមារទទួលបានការអប់រំ... ជាបន្តបន្ទាប់ និងឈរលើមូលដ្ឋាននៃឪកាសស្មើគ្នា និង (ក)ធានាថា កុមារពិការទទួលបានការអប់រំប្រកបដោយប្រសិទ្ធភាព (ខ) ផ្តល់ការអប់រំបឋមសិក្សាដោយឥតបង់ថ្លៃ និងភារកិច្ចនៃការទទួលខុសត្រូវលើការអប់រំ (គ)លើកទឹកចិត្តឲ្យមានការអភិវឌ្ឍន៍ទម្រង់នៃការអប់រំផ្សេងៗគ្នា រួមមានការអប់រំទូទៅ និងវិជ្ជាជីវៈ ដែលកុមារគ្រប់រូបអាចទទួលបាន (ឃ)ចាត់បទបញ្ញា ការសមស្រប ដូចជាការណែនាំអំពីការចូលរៀនដោយឥតបង់ថ្លៃ និងផ្តល់ជំនួយហិរញ្ញវត្ថុ ក្នុងករណីចាំបាច់ (ង)ធ្វើឲ្យព័ត៌មាន និងគោលការណ៍ណែនាំអប់រំ និងវិជ្ជាជីវៈអាចបានទៅដល់កុមារគ្រប់រូប (ច)ចាត់បទបញ្ញាការដើម្បីលើកទឹកចិត្តឲ្យមានការចូលរៀនទៀងទាត់នៅសាលារៀន និងការ | | ធានាថាគោលនយោបាយ និងកម្មវិធីទាំងនេះនឹងគាំទ្រដល់សិទ្ធិដែលត្រូវបានគេទទួលស្គាល់ (ឧទាហរណ៍ ច្បាប់ស្តីពីពិការភាព ដែលគាំទ្រកុមារពិការឲ្យទទួលបានការអប់រំ ការលុបបំបាត់ថ្លៃចុះឈ្មោះចូលរៀនចាប់តាំងពីឆ្នាំ២០០០ ការផ្តល់ការអប់រំវិជ្ជាជីវៈ ការផ្តល់អាហារូបករណ៍ គោលនយោបាយស្តីពីពលកម្មកុមារ)។ | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | កាត់បន្ថយអត្រាសិស្សបោះបង់ការសិក្សា (ឆ) លើកស្ទួយឲ្យមានការអភិវឌ្ឍសមត្ថភាពកុមារឲ្យបានពេញលេញបំផុត (ជ)លើកកម្ពស់សិទ្ធិកុមារមកពីក្រុមសាសនា និងជនជាតិភាគតិចឲ្យរីករាយវប្បធម៌ សាសនា និងភាសាផ្ទាល់ខ្លួន (ឈ)ធានាឲ្យបាននូវឪកាសស្មើគ្នាក្នុងការចូលរួមសកម្មភាពវប្បធម៌ សិល្បៈ និងសកម្មភាពផ្សេងៗ និង(ញ)ការពារកុមារពីការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច និងធ្វើការដែលងាយរងគ្រោះថ្នាក់ឬជ្រៀតជ្រែកក្នុងការសិក្សារបស់កុមារ។ | | | |
| | **គោលនយោបាយសាលាកុមារមេត្រី ឆ្នាំ២០០៧ វិសាលភាពទី១៖** ធានា និងគាំទ្រកុមារគ្រប់រូប ជាពិសេសកុមារជួបការលំបាក (កុមារមកពីគ្រួសារ ក្រីក្រ កុមារី កុមារកំព្រា កុមាររងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ កុមារពិការ កុមារជនជាតិភាគតិច កុមាររងគ្រោះដោយសារគ្រឿងញៀន កុមារ រងគ្រោះដោយមេរោគ | កុមារគ្រប់រូប | | ការវិភាគដោយប្រៀបធៀបអំពីអង្គការយូនីសេហ្វបានគាំទ្រសាលាកុមារមេត្រីធៀបនឹងសាលាមិនមែនកុមារមេត្រីនៅឆ្នាំ២០០៨មិនបានវាស់វែងផលប៉ះពាល់លើការបោះបង់ការសិក្សា ប៉ុន្តែគូសបញ្ជាក់ពីការផ្លាស់ប្តូរជាវិជ្ជមានមួយចំនួន ពោលគឺសាលា |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | អេដស៍/ជម្ងឺអេដស៍ និង ជម្ងឺផ្សេងទៀត) ទទួលបានការអប់រំដោយសមធម៌។ | | | រៀននានាស្វាគមន៍កុមារពិការ និងឆ្លើយតបទៅនឹងតម្រូវការយេនឌ័រកាន់តែច្រើនឡើងថែមទៀត[៥]។ |
| | **កម្មវិធីសិទ្ធិកុមាររបស់អង្គការយូនីសេហ្វ** ការពារសិទ្ធិកុមារ និងស្ត្រី និងកែលម្អជីវិតរស់នៅរបស់ពួកគេតាមរយៈគំនិតផ្តួចផ្តើមពីសហគមន៍ដើម្បីលើកកម្ពស់សុខភាព អាហារូបត្ថម្ភ ការអប់រំ សេវាទឹក និងអនាម័យ ខណៈពេលបើកឱកាសសេដ្ឋកិច្ចថ្មីសម្រាប់គ្រួសារ និងសហគមន៍ងាយរងគ្រោះ ក៏ដូចជាការផ្តល់ការគាំពារផ្លូវចិត្ត។ | ភាគច្រើនកុមារអាយុក្រោម០៥ឆ្នាំ | កម្មវិធីនេះផ្តល់:<br>• ការគាំទ្រដល់ការអភិវឌ្ឍផែនការសកម្មភាពភូមិ ផ្តោតលើបញ្ហាប្រឈមចំពោះស្ត្រី និងកុមារ និងការកំណត់សកម្មភាពដ៏ល្អបំផុតដើម្បីដោះស្រាយបញ្ហាទាំងនេះ។<br>• សកម្មភាពអប់រំសុខភាព អនាម័យ និងអាហារូបត្ថម្ភគួបផ្សំនឹងថ្នាក់អក្ខរកម្មតាមមុខងារសំដៅចំពោះកុមារនៅក្រៅសាលា យុវជន និងស្ត្រី និង<br>• ការលើកកម្ពស់ការយល់ដឹងក្នុងសហគមន៍អំពីអំពើហិង្សាក្នុងគ្រួសារ ការផ្លាស់ឥរិយាបថចំពោះកុមារ និងការថែទាំកុមារ។ មកទល់ពេលនេះ | |

[៥] កម្មវិធីពង្រីកការអប់រំកម្រិតមូលដ្ឋាន(EBEP)ដំណាក់កាលទី២៖ ឆ្នាំ២០០៦-២០០៩ របាយការណ៍ពិនិត្យឡើងវិញឆ្នាំ២០០៩ បេសកកម្មប្រចាំនៅកម្ពុជា ថ្ងៃទី១២-២៦ មីនា ២០១០ ក្រុមពិគ្រោះយោបល់ SIDA ។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | | | អង្គការយូនីសេហ្វបាន<br>• បង្កើតម៉ូឌុលបណ្តុះបណ្តាលអំពីសិទ្ធិកុមារ សុខភាព ការអប់រំ និងការការពារដែលផ្តល់ប្រយោជន៍ដល់សមាជិកក្រុមប្រឹក្សាឃុំ នៅក្នុង ១៣០ឃុំ<br>• ទៅជួបប្រជាពលរដ្ឋ៥២០០០នាក់ តាមរយៈកិច្ចខិតខំប្រឹងប្រែងតស៊ូមតិក្នុងការលើកកម្ពស់សុខភាព សិទ្ធិស្ត្រី និងកុមារ និង<br>• គាំទ្រថ្នាក់ត្រៀមចូលរៀននៅសហគមន៍ចំនួន ៥៩៨ ដែលមានកុមារចុះឈ្មោះចូលរៀនជាង ១២០០០នាក់។[៦] | |
| | អង្គការមិនមែនរដ្ឋាភិបាលជាច្រើនផ្តល់កម្មវិធីគាំទ្រដល់សិទ្ធិកុមារ។ | សហគមន៍ និងអាជ្ញាធរ | ដូចខាងលើ | |
| ២. ភារកិច្ចនៃ | **ច្បាប់អប់រំ ឆ្នាំ២០០៧ មាត្រា៣២៖** | កុមារអាយុ | ភារកិច្ចនៃការទទួលខុសត្រូវមិនត្រូវបានថែងតែ | កង្វះការដាក់ទណ្ឌកម្មអាចមាន |

[៦] អង្គការសហប្រជាជាតិ "សិទ្ធិកុមារ" ការរស់រានមានជីវិត និងការអភិវឌ្ឍកុមារនៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា(ឆ្នាំ២០០៧)។ អាចរកបាននៅលើគេហទំព័រhttp://ochaonline.un.org/TrustFund/ProjectProfiles/SethKomaChildrightsinCambodia/tabid/2119/language/en-US/Default.aspx

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| ការទទួលខុសត្រូវលើការអប់រំ | ការចុះឈ្មោះចូលរៀនកុមារថ្នាក់ទី១ត្រូវកំណត់នៅអាយុ០៦ឆ្នាំ ឬយ៉ាងហោច៧០ខែតាមកាលបរិច្ឆេទនៃការចាប់ផ្តើមឆ្នាំសិក្សា។ | ០៦ឆ្នាំ ឬយ៉ាងហោច៧០ខែ | អំពីសិទ្ធិទទួលបានការអប់រំនោះទេ ហើយក៏មិនមានបទបញ្ញាការដាក់ទណ្ឌកម្មណាមួយ ប្រសិនបើកុមារនោះមិនបានចុះឈ្មោះចូលរៀន។ ដូច្នេះ មិនមានការដាក់សម្ពាធណាមួយទៅលើឪពុកម្តាយដើម្បីឲ្យធានាថាកុមារទៅរៀន។ | ផលប៉ះពាល់ទៅលើការទទួលបានការអប់រំ និងការបោះបង់ការសិក្សា។ កុមារដែលមករៀនទាន់ពេលមានអត្រាបោះបង់ទាបជាង។[៧] |
| | **សារាចរណែនាំរបស់ក្រសួងអប់រំ លេខ២៤ អយក/សណន ៖ ដំណើរការនៃការបង្កើតសាលាបឋមសិក្សា និងមត្តេយ្យសិក្សារដ្ឋ ឆ្នាំ២០១០** លើកទឹកចិត្តឲ្យឪពុកម្តាយ/អាណាព្យាបាលនាំកុមារគ្រប់អាយុចូលរៀនមកចុះឈ្មោះចូលរៀនឲ្យបានទាន់ពេលវេលា និងអនុញ្ញាតឲ្យកុមារបន្ត | កុមារអាយុ ០៦ឆ្នាំ ឬយ៉ាងហោច៧០ខែ | ការអនុវត្តសារាចរណែនាំនេះរួមមាន យុទ្ធនាការចុះឈ្មោះចូលរៀន ការថតឈុតតាមទូរទស្សន៍មុនពេលចាប់ផ្តើមឆ្នាំសិក្សាថ្មី, ការចងបដា និងផ្ទាំងរូបភាព និងការផ្សព្វផ្សាយតាមវិទ្យុអំពីការចុះឈ្មោះចូលរៀន។ | យុទ្ធនាការទាំងនេះបានកាត់បន្ថយការចុះឈ្មោះចូលរៀនយឺត និងកាត់បន្ថយអត្រាបោះបង់ការសិក្សា (ដូចបានរាយការណ៍នៅក្នុងរបាយការណ៍ជាតិឆ្នាំ២០០៦-២០១០)។[៨] |

[៧] បទសម្ភាសន៍ជាមួយលោក ពេជ្រ ប៊ុណ្ណា ប្រធាននាយកដ្ឋានអប់រំបឋមនៃក្រសួងអប់រំ រាជធានីភ្នំពេញ ថ្ងៃទី១១ កុម្ភៈ ២០១១។

| *ប្រធានបទគោលនយោបាយឬកម្មវិធី* | *ឯកសារ* | *ក្រុមគោលដៅ* | *ការបរិយាយ/សេចក្តីអត្ថាធិប្បាយ* | *របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា* |
|---|---|---|---|---|
| | ការសិក្សា (ផ្អែកលើការទទួលយក ជីវភាពរស់នៅរបស់គ្រួសារ ឬឆន្ទៈរបស់កុមារ)។[៨] | | | |
| | **ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៩-១៣, គោលនយោបាយទី១៖** ធានាថា កុមារអាយុ០៦ឆ្នាំគ្រប់រូបបានចូលរៀននៅសាលាបឋមសិក្សា រួមមាន ក្រុមងាយរងគ្រោះ[១០] ដូចជាកុមារពិការ ជនជាតិ ភាគតិច ។ល។ **សកម្មភាពគោលនយោបាយឆ្នាំ២០១១៖** នាយកដ្ឋានអប់រំបឋមសបានបង្កើតសារាចរណែនាំស្តីពីការធ្វើជំរឿនកុមារនៅតាមភូមិ និងការធ្វើផែនទីខ្នងផ្ទះ។ | កុមារអាយុ០៦ឆ្នាំ | | មិនទាន់បានវាស់វែង។ |

[៨] បទសម្ភាសន៍ជាមួយលោក ពេជ្រ ប៊ុណ្ណា ប្រធាននាយកដ្ឋានអប់រំបឋមនៃក្រសួងអប់រំ រាជធានីភ្នំពេញ ថ្ងៃទី១១ កុម្ភៈ ២០១១។

[៩] បទសម្ភាសន៍ជាមួយលោក អ៊ុង ង៉ូហុក ប្រធាននាយកដ្ឋានមធ្យមសិក្សានៃក្រសួងអប់រំ រាជធានីភ្នំពេញ ថ្ងៃទី០៤ កុម្ភៈ ២០១១ ផ្តល់ព័ត៌មានដោយគម្រោងរបស់ក្រសួងអប់រំដែលត្រូវបានផ្តល់មូលនិធិដោយអង្គការយូនីសេហ្វ។

[១០] ក្រុមងាយរងគ្រោះរួមមាន៖ កុមារមកពីគ្រួសារក្រីក្រ ពលកម្មកុមារ កុមារនៅក្នុងតំបន់ងាយរងគ្រោះ កុមារពិការ កុមាររងគ្រោះដោយមេរោគអេដស៍/ជម្ងឺអេដស៍ និងជំងឺឆ្លងផ្សេងទៀត។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| ៣. ច្បាប់ពលកម្មកុមារ | **ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា (MoSALVY)**[១១] **ប្រកាសស្តីពីល័ក្ខខ័ណ្ឌការងារ និងការរស់នៅតាមសហគ្រាសផលិតឥដ្ឋ,**<br>**ចំណុចទី៦៖**<br>មិនត្រូវជួលកុមារអាយុក្រោម១៥ឆ្នាំឲ្យធ្វើការនៅកន្លែងផលិតឥដ្ឋនោះទេ ទោះបីជាពួកគេទៅជួយការងារឪពុកម្តាយរបស់ខ្លួននៅទីនោះក៏ដោយ និង<br>**ចំណុចទី៨៖** អ្នកដែលល្មើសនឹងបទប្បញ្ញត្តិនៃ *ប្រកាស* ដូចមានចែងនៅក្នុងជំពូកទី XVI នៃច្បាប់ការងារ នឹងត្រូវពិន័យ ឬដាក់ពន្ធនាគារ។ | កុមារអាយុក្រោម១៥ឆ្នាំ | | |
| | **ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា (MoSALVY) ប្រកាសស្តីពី** | កុមារអាយុក្រោម១៥ | | |

[១១] ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា(MoSALVY)ត្រូវបានបែងចែកជាពីរក្រសួងនៅឆ្នាំ២០០៤ រួមមាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(MoSVY) និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(MoLVT)។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | **ការងារនេសាទ, ចំណុចទី៦៖** ហាមឃាត់កុមារអាយុក្រោម១៥ឆ្នាំមិនឲ្យធ្វើការនៅកន្លែងនេសាទ។ | ឆ្នាំ | | |
| | **ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា (MoSALVY) ប្រកាសស្តីពីល័ក្ខខ័ណ្ឌការងារនៅរោងចក្រកាត់ដេរ និងស្បែកជើង,**<br>**មាត្រា៧៖**<br>មិនអនុញ្ញាតឲ្យកុមារអាយុក្រោម១៥ឆ្នាំធ្វើការនៅសហគ្រាស ឬរោងចក្រកាត់ដេរ ផលិតស្បែកជើង ឬធ្វើជាសិប្បករឡើយ និង<br>**មាត្រា៩៖**<br>បុគ្គលដែលល្មើសនឹងបទប្បញ្ញត្តិនៃ*ប្រកាស* ដូចមានចែងនៅក្នុងជំពូកទី XVI នៃច្បាប់ការងារនឹងត្រូវពិន័យ ឬជាប់ពន្ធនាគារ។ | កុមារអាយុក្រោម១៥ឆ្នាំ | | |
| | **ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា (MoSALVY) ប្រកាសស្តីពី** | កុមារអាយុក្រោម១៨ | ប្រសិនបើកុមារដែលធ្វើការនោះមិនត្រូវបានបញ្ជាក់ យ៉ាងត្រឹមត្រូវអំពីអាយុនៅក្នុងឯកសារ | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | **ការ ហាមឃាត់ពលកម្មកុមារដ៏មានគ្រោះថ្នាក់ , ចំណុចទី១៖** និយោជកសហគ្រាស ឬគ្រឹះស្ថានដូចមានចែងនៅក្នុងមាត្រា១នៃច្បាប់ការងារ នឹងត្រូវហាមឃាត់មិនឲ្យប្រើប្រាស់កុមារក្រោមអាយុ១៨ឆ្នាំនៅក្នុងប្រភេទនៃការងារណាមួយដូចមានចែងនៅក្នុងចំណុចទី២នៃ*ប្រកាស* បច្ចុប្បន្ន។ | ឆ្នាំ | ផ្លូវការ ឬអធិការការងារមានហេតុផលជឿជាក់ថាឯកសារផ្លូវការបញ្ជាក់ថា អាយុនោះក្លែងបន្លំ ត្រូវរកគ្រូពេទ្យនៅក្នុងសេវាសាធារណៈមកបំភ្លឺអំពីអាយុរបស់កុមារនោះ។ | |
| | **ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា (MoSALVY) ប្រកាសស្តីពីការកំណត់ប្រភេទការងារស្រាល និងការជួលបុគ្គល ថាកុមារអាយុដែលមានអាយុ១២ឆ្នាំអាចជួលមកធ្វើការ,**<br>**ចំណុចទី១៖**<br>និយោជកសហគ្រាស ឬគ្រឹះស្ថានដូចមានចែងនៅក្នុងមាត្រា១នៃច្បាប់ ការងារ នឹងត្រូវបានអនុញ្ញាតឲ្យជួលកុមារដែល មានអាយុ១២ឆ្នាំឲ្យធ្វើការងារស្រាលៗ ដូចមាន ចែងនៅក្នុង | កុមារអាយុក្រោម១៥ឆ្នាំ | ប្រភេទនៃការងារស្រាលដូចមានចែងនៅក្នុងល័ក្ខខ័ណ្ឌនៃចំណុចទី១ គឺ៖<br>១) ការងារស្រាលនៅក្នុងវិស័យកសិកម្ម ការមើលថៃ ឬឃ្វាលសត្វពាហនៈតូចៗ (ប៉ុន្តែមិនមែនចាប់ ឬសម្លាប់សត្វទាំងនោះទេ) ការដាំដំណាំ ការប្រមូលផលិតផលកសិកម្ម ការបេះផ្លែឈើ (ប៉ុន្តែ មិនឲ្យឡើងដើមឈើនោះទេ) និងការបោសសម្អាត;<br>២) ការបោចស្មៅ និងការជីកដី<br>៣) ការងារដដែលៗសម្រាប់សម្គាល់ទំនិញ | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | ចំណុចទី២នៃ *ប្រកាស* បច្ចុប្បន្ន... កុមារដែលធ្វើការងារជាផ្នែកមួយនៃការបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ខ្លួនអាចត្រូវបានជួលមក ធ្វើការប្រភេទស្រាលដូចមានចែងនៅក្នុងចំណុចទី២នៃ *ប្រកាស* បច្ចុប្បន្ន។<br>**ចំណុចទី២៖**<br>ការងារស្រាលគឺជាប្រភេទនៃការងារដែលមិនបង្កគ្រោះថ្នាក់ដល់សុខភាព ឬការអភិវឌ្ឍផ្លូវកាយ និងផ្លូវចិត្តរបស់កុមារ និងមិនប៉ះពាល់ដល់ការចូលរៀនជាប្រចាំ ការចូលរួមរបស់កុមារនៅក្នុងកម្មវិធីណែនាំ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈដែលត្រូវបានអនុម័តដោយ អាជ្ញាធរមានសមត្ថកិច្ច។<br>**ចំណុចទី៣៖** នៅពេលជួលកុមារអាយុចាប់ពី១២ ដល់១៥ឆ្នាំ និយោជកត្រូវធានាថា ឪពុកម្តាយ ឬអាណាព្យាបាលកុមារយល់ដឹងអំពីល័ក្ខខ័ណ្ឌការងារ រួមមាន រយៈពេលនៃម៉ោងការងារ | | ៤) ការងារនៅក្នុងហាងមួយចំនួន ដូចជា ការលក់ផ្លែឈើ និងបន្លែ ឬតូបលក់កាសែត និងផលិតផលស្រដៀងគ្នា<br>៥) ការទទួល វេចខ្ចប់ ជ្រើសរើស លើក និងប្រមូលទំនិញស្រាលៗ និងឡាំងទទេរ<br>៦) ការបោសសម្អាតស្រាលៗ ការលាងសម្អាត និងការរៀបចំតុ ដូចជា ចាន ស្លាបព្រា សម កាំបិត ជាដើម។<br>៧) ការប្រមូលដោយដៃដែលងាយស្រួល (ប៉ុន្តែមិនឲ្យធ្វើទាហាន ផ្សាដែរ ឬធ្វើការជាមួយផលិតផលស្និតដែលបង្កគ្រោះថ្នាក់។<br>៨) ការងារលាបថ្នាំ ប៉ុន្តែមិនឲ្យបាញ់ថ្នាំ<br>៩) ការងារងាយស្រួល ដូចជា ការដេរប៉ាក់ ការច្រកបាវ ការបត់ប្រអប់កាតុង និងការដុសខាត់ផលិតផលសេរ៉ាមិក និងកញ្ចក់ ការកាត់ចុងក្រណាត់ ឬការប្រមូលមកវិញនូវបំណែក នៃក្រណាត់ផ្សេងទៀត ឬការសម្អាតកំណាកប្រេង | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | ម៉ោងសិក្សា ការប្រឈមនឹងគ្រោះថ្នាក់ និងជំងឺដែលអាចភ្ជាប់ទៅនឹងការងារ និងការវាស់វែងសុខភាព និងសុវត្ថិភាពការងារដែលត្រូវបានធ្វើ ឡើង។ និយោជកត្រូវលើកទឹកចិត្តឲ្យកុមារដែលធ្វើការបានចូលរៀន ប្រសិនបើអាចធ្វើទៅបាន និង<br>**ចំណុចទី៤៖**<br>ម៉ោងធ្វើការប្រចាំថ្ងៃមិនឲ្យលើសពី៤ម៉ោងនៅថ្ងៃសិក្សា និង៧ម៉ោងក្រៅពីម៉ោងសិក្សា។ ម៉ោងធ្វើការសរុបពិប្រាកដមិនត្រូវឲ្យលើសពី១២ម៉ោងក្នុងមួយសប្តាហ៍ ក្នុងអំឡុង សប្តាហ៍ដែលរាប់បញ្ចូលទាំងថ្ងៃចូលរៀន និង៣៥ម៉ោងក្នុងមួយសប្តាហ៍ក្រៅពីថ្ងៃចូលរៀន។ | | នៅលើផលិតផលក្រណាត់ ឬការបិទស្លាកយីហោ និងតម្លៃសម្លៀកបំពាក់។<br>១០) ការគូសសម្គាល់ និងការយកសម្លៀកបំពាក់ទៅបោកអ៊ុត។<br>១១) ការត្រួតពិនិត្យផលិតផល។<br>១២) ការងារផ្ញើសារ ឬលិខិតខាងក្នុង។<br>១៣) ការកាន់លិខិត ឬសារស្រាលៗ រួមមានការបញ្ជូនកាសែត និងឯកសារផ្សេងទៀត។<br>១៤) ការលើកសៀវភៅដាក់ក្នុងបណ្ណាល័យ និង<br>១៥) ការលើក លីសែង យួរ ឬកាន់របស់របរស្រាលៗ។ | |
| ៤. ភាពទទួលខុសត្រូវនៅសាលារៀន | **ច្បាប់អប់រំ ឆ្នាំ២០០៧, មាត្រា២១ គុណភាព និងប្រសិទ្ធភាពនៃការអប់រំ៖**<br>រដ្ឋត្រូវលើកកម្ពស់គុណភាពអប់រំដើម្បីឆ្លើយតប | ស្ថាប័នអប់រំ | | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | ទៅនឹងតម្រូវការអប់រំកម្រិតមូលដ្ឋាន និងវិជ្ជាជីវៈ សម្រាប់អាជីពរបស់ អ្នករៀនសូត្រ ដើម្បីលើកស្ទួយសមត្ថភាព និងជួយឲ្យពួកគេអាចចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងការអភិវឌ្ឍប្រទេសជាតិ។ រដ្ឋត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងការបំពាក់នូវបច្ចេកទេសបង្រៀន និងរៀនសូត្រដ៏សមស្រប និងទំនើបដើម្បីធានាឲ្យបាននូវគុណភាព និងប្រសិទ្ធភាពនៃការអប់រំ។ បទដ្ឋានជាតិអប់រំបទដ្ឋានជាតិបណ្តុះបណ្តាល និង/ឬបទដ្ឋាន សមត្ថភាពជាតិត្រូវកំណត់ដោយក្រសួងទទួលបន្ទុកអប់រំស្របតាមគោលនយោបាយរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ និង<br>**មាត្រា២២ យន្តការវាយតម្លៃដើម្បីធានាឲ្យបាននូវគុណភាពនៃការអប់រំៈ**<br>វិទ្យាស្ថានអប់រំត្រូវបំពេញតាមបទដ្ឋានជាតិអប់រំ បទដ្ឋានជាតិបណ្តុះបណ្តាល និង/ឬបទដ្ឋាន | | | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | សមត្ថភាពជាតិ ដើម្បី លើកកម្ពស់គុណភាពនៃការអប់រំ។ ស្ថាប័នអប់រំ រដ្ឋ ឬឯកជនត្រូវបង្កើតយន្តការវាយតម្លៃផ្ទៃក្នុង ដើម្បីត្រួតពិនិត្យ និងវាយតម្លៃគុណភាពនៃការអប់រំដោយខ្លួនឯង និងផ្តល់អនុសាសន៍អំពីបទបញ្ជាការបន្តធ្វើការត្រួតពិនិត្យ និងវាយតម្លៃ។ យន្តការ វាយតម្លៃផ្ទៃក្នុងនឹងបើកទូលាយឲ្យមានការចូលរួមពីសាធារណជន។<br>ក្រសួងអប់រំត្រូវបង្កើតយន្តការវាយតម្លៃខាងក្រៅដើម្បីអនុវត្ត ឬបំពេញតាមតម្រូវការនៃបទដ្ឋានជាតិអប់រំសម្រាប់ស្ថាប័ន អប់រំ។<br>ក្រសួងទទួលបន្ទុកផ្នែកអប់រំ និងក្រសួង និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យលើការអនុវត្ត ឬការបំពេញតាមតម្រូវការបទដ្ឋានសមត្ថភាពនៃគ្រឹះស្ថានអប់រំស្របតាមគោលនយោបាយរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ ដើម្បីវាយតម្លៃគុណភាពអប់រំ។ ក្រសួង | | | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | ទទួលបន្ទុកផ្នែកអប់រំត្រូវចេញសារាចរណែនាំអំពីនីតិវិធីសម្រាប់ដំណើរការនៃយន្តការត្រួតពិនិត្យ និងវាយតម្លៃ។ | | | |
| | **សារាចរណែនាំលេខ ៤ អយក/សរណន ឆ្នាំ២០០៩៖ តួនាទី និងការទទួលខុសត្រូវរបស់អធិការកិច្ចសាលា។**<br>ដើម្បីលើកស្ទួយឲ្យមានអភិបាលកិច្ចល្អ អធិការកិច្ចសាលាគួរតែ៖<br>• បង្កើតក្រុមគ្រប់គ្រងគ្រូបង្រៀនស្រុក ដើម្បីតាមដានការអនុវត្តនៃគោលនយោបាយសាលាកុមារមេត្រី និងលើកឡើងអំពីគោលនយោបាយរបស់ក្រសួងអប់រំ។<br>• បង្កើតបញ្ជីត្រួតពិនិត្យសម្រាប់អធិការកិច្ចសាលារៀននិងធ្វើរបាយការណ៍ប្រចាំត្រីមាសអំពីគុណភាពនៃការបង្រៀន និងការរៀនសូត្ររបស់សិស្សនៅតាមសាលានីមួយៗ និងធ្វើការពិនិត្យឡើងវិញពាក់កណ្តាលត្រីមាសនូវគុណ | សាលារៀននិងស្ថាប័នអប់រំ | ក្នុងអំឡុងឆ្នាំ២០០៩ គេបានបង្កើតក្រុមគ្រូឧទ្ទេសថ្នាក់ជាតិទទួលបន្ទុកបណ្តុះបណ្តាលសមាជិក DTMT និងដើរតួជាក្រុមអ្នកឯកទេសសម្រាប់ការអនុវត្តសាលាកុមារមេត្រីទូទាំងប្រទេស។ DTMT មានតួនាទីត្រួតពិនិត្យ និងផ្តល់យោបល់នៅពេលចុះទស្សនកិច្ចសាលារៀន ហើយបញ្ជីត្រួតពិនិត្យលម្អិតត្រូវបានបង្កើតឡើងសម្រាប់ទស្សនកិច្ចសាលារៀន។ ការបណ្តុះបណ្តាល និងការគាំទ្រពីអង្គការ VSO និងអង្គការយូនីសេហ្វ បានកសាងសមត្ថភាពរបស់សមាជិក DTMT នៅទូទាំង២៤ខេត្តក្រុង។ | វាអាចឆាប់ពេកមិនអាចមើលឃើញលទ្ធផលណាមួយនោះទេ ពីព្រោះវាជាគំនិតផ្តួចផ្តើមថ្មីមួយ។ |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | ភាពនៃការបង្រៀន និងការរៀនសូត្រ។ | | | |
| | **ការអភិវឌ្ឍសមត្ថភាពសម្រាប់កម្មវិធីអប់រំក្រៅប្រព័ន្ធ(EFA)នៅកម្ពុជាឆ្នាំ២០១០-២០១១** ប្រើប្រាស់មូលនិធិពីម្ចាស់ជំនួយទាំងនេះដើម្បីពង្រឹងការអភិវឌ្ឍគោលនយោបាយអប់រំ និងយន្តការ និងការអប់រំកៅប្រព័ន្ធនៅក្នុងផែនការវិស័យអប់រំ។ | ប្រព័ន្ធសាលារដ្ឋ | កម្មវិធីនេះគួរតែពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងកម្មវិធីអប់រំក្រៅប្រព័ន្ធ និងបង្កើនសមត្ថភាពនៃអ្នកធ្វើផែនការកម្មវិធីអប់រំក្រៅប្រព័ន្ធ ដើម្បីប្រើប្រាស់ និងបង្កើនសមត្ថភាពរបស់អ្នកពាក់ព័ន្ធកម្មវិធីអប់រំក្រៅប្រព័ន្ធ ក្នុងការប្រើប្រាស់ទិន្នន័យដើម្បីគាំទ្រនិងប្រមូលសម្រាប់កម្មវិធីរបស់ពួកគេ។ | មិនទាន់បានវាស់វែង។ |
| ៥. ការតាមដានអវត្តមានសិស្ស | **ប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ ១២៥៨ អយក/ប្រកៈ បទបញ្ជាផ្ទៃក្នុងសម្រាប់ស្ថាប័ន អប់រំបឋមសិក្សារដ្ឋ ឆ្នាំ២០០៩ ជំពូកទី IV,មាត្រា១៩៖** **លិខិតអនុញ្ញាត:** កុមារអវត្តមានទាំងអស់ត្រូវមានលិខិតសុំច្បាប់ជាផ្លូវការ ដោយមានការត្រួតពិនិត្យពីគ្រូបន្ទុកថ្នាក់។ លិខិតសុំច្បាប់នេះត្រូវផ្តល់ឲ្យពីកន្លះថ្ងៃរហូតដល់០១ថ្ងៃ។ ឪពុកម្តាយ ឬអាណាព្យាបាលសិស្សមានសិទ្ធិសុំច្បាប់ | បឋមសិក្សា | ក្រុមកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សាបានអង្កេតថាសាលារៀនដែលមានរដ្ឋបាលរឹងមាំទំនងជាតាមដានសិស្ស និងគ្រួសារទាក់ទងនឹងការអវត្តមានច្រើន។ | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្ដីអត្ថាធិប្បាយ | របាយការណ៍ស្ដីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | ផ្ទាល់មាត់។ គ្រូបង្រៀន ឬនាយកសាលាមានសិទ្ធិអំណាចពេញលេញក្នុងការទទួលយកលិខិតសុំច្បាប់នោះ។ | | | |
| ៦. ការបង់ថ្លៃសាលា | **រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ជំពូក VI: ការអប់រំ វប្បធម៌ សង្គមកិច្ច មាត្រា៦៥៖** រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិប្រជាពលរដ្ឋឲ្យទទួលបានការអប់រំដ៏មានគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់បទបញ្ញាការចាំបាច់នានា ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព និង **មាត្រា៦៨៖** រដ្ឋត្រូវផ្ដល់ការអប់រំថ្នាក់បឋមសិក្សា និងមធ្យមសិក្សាដោយឥតបង់ថ្លៃដល់ប្រជាពលរដ្ឋគ្រប់រូបនៅសាលារដ្ឋ។ ប្រជាពលរដ្ឋត្រូវទទួលបានការអប់រំយ៉ាងតិច០៩ឆ្នាំ។ | ប្រជាពលរដ្ឋ | នៅក្នុងការអនុវត្តជាក់ស្ដែងនៅតាមសាលាជាច្រើន ការបង់ថ្លៃក្រៅផ្លូវការគឺទៅលើការរៀនគួរបន្ថែម ឬការថតចម្លងមេរៀន ឬឯកសារត្រូវបង់លុយទៅឲ្យគ្រូបង្រៀន ដោយសារគ្រូទទួលបានប្រាក់ចំណូលទាប។<br>ការអនុវត្តបែបនេះត្រូវបានគេយល់ឃើញថាជាការបំពេញបន្ថែមដ៏ចាំបាច់មួយ ដើម្បីទ្រទ្រង់ជីវភាពគ្រួសាររបស់ពួកគាត់។ | ការបង់ថ្លៃសាលាក្រៅផ្លូវការអាចធ្វើឲ្យកុមារមកពីគ្រួសារក្រីក្រមិនចូលរៀន ឬមិនបានបញ្ចប់ការសិក្សា។[១២] |

[១២] បទសម្ភាសន៍ជាមួយលោក អ៊ិន សមរិទ្ធី អ្នកសម្របសម្រួលភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល រាជធានីភ្នំពេញ ថ្ងៃទី០៩ កុម្ភៈ ២០១១។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្ដីអត្ថាធិប្បាយ | របាយការណ៍ស្ដីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | **សារាចរណែនាំរបស់ក្រសួងអប់រំលេខ ១០៩៤ អយក/សរណណ ឆ្នាំ២០០៦, មាត្រា១៖** ការហាមប្រមូល ឬរៃអង្គាសមូលនិធិពីសិស្សណាម្នាក់នៅសាលាបឋមសិក្សាឬមធ្យមសិក្សា។ | គ្រូបង្រៀនបឋមសិក្សា និងមធ្យមសិក្សា | ប្រសិនបើសាលារៀន ឬគ្រូបង្រៀនខ្វះសមត្ថភាពក្នុងការបង្កើតសម្ភារៈ ឬសៀវភៅសិក្សា ពួកគាត់ត្រូវពិគ្រោះយោបល់ជាមួយសមាគមមាតាបិតាសិស្ស។ | ការបង់ថ្លៃសាលាក្រៅផ្លូវការអាចធ្វើឲ្យកុមារមកពីគ្រួសារក្រីក្រមិនចូលរៀន ឬមិនបានបញ្ចប់ការសិក្សា។[១៣] |
| | **ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-២០១៣, គោលនយោបាយទី១៖** កាត់បន្ថយរាល់ការចំណាយគ្រប់ប្រភេទរបស់ឪពុកម្ដាយ ដូចជា ការបង់ថ្លៃសិក្សាក្រៅប្រព័ន្ធ និង**សកម្មភាពគោលនយោបាយឆ្នាំ២០១០៖** សារាចរណែនាំអំពី ការគ្រប់គ្រង និងការប្រើប្រាស់ថវិកាប្រតិបត្តិការសាលារៀន និងវិភាគទានពីឪពុកម្ដាយ និងសប្បុរសជននានា។ | សាលារៀន និងគ្រូបង្រៀន | ផែនការនេះមិនត្រូវបានបញ្ជាក់ច្បាស់ពីក្រសួងអប់រំ យុវជន និងកីឡានោះទេ ប្រសិនបើផែនការនេះមិនទាន់បានបង្កើតឡើង។ | |
| | កម្មវិធីអង្គការ ខេប មានជាអាទិ៍ គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាន គម្រោងគំនិតផ្ដួចផ្ដើមសម្រាប់កុមារី គម្រោង MORE, និងគម្រោង | សិស្សក្រីក្រថ្នាក់បឋមសិក្សា | កម្មវិធីនេះមិនមានបង់ថ្លៃសិក្សាជាផ្លូវការនោះទេ ប៉ុន្តែអាចបង់ថ្លៃសម្រាប់មេរៀនបន្ថែម ដែលតម្រូវឲ្យបង់ថ្លៃ។ | មិនទាន់បានវាស់វែង។ |

[១៣] បទសម្ភាសន៍ជាមួយលោក អ៊ិន សមរិទ្ធិ អ្នកសម្របសម្រួលភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល រាជធានីភ្នំពេញ ថ្ងៃទី០៩ កុម្ភៈ ២០១១។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | សរសេរឡើងវិញពីអនាគត ដើម្បីជួយដល់សិស្សក្រីក្របំផុតឲ្យនៅរៀនបន្ត។ | និងមធ្យមសិក្សា (ជាពិសេសកុមារី) | | |
| ៧. ការឧបត្ថម្ភថ្លៃសិក្សា/អាហារូបករណ៍ | **ច្បាប់អប់រំឆ្នាំ២០០៧ មាត្រា៣០ អាហារូបករណ៍ និងការឧបត្ថម្ភ៖** រដ្ឋត្រូវកំណត់គោលនយោបាយស្តីពីការផ្តល់អាហារូបករណ៍ ការឧបត្ថម្ភ និងឥណទានសម្រាប់អ្នកសិក្សា។ រដ្ឋត្រូវលើកទឹកចិត្តឲ្យមានការផ្តល់អាហារូបករណ៍ និងការឧបត្ថម្ភសម្រាប់អ្នកសិក្សា។ | សិស្សថ្នាក់បឋមសិក្សា និងមធ្យមសិក្សា | រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងប្រមូលធនធានបន្ថែមដើម្បីបង្កើនអាហារូបករណ៍សម្រាប់សិស្សក្រក្រី និងសិស្សពូកែដើម្បីធានាថាទទួលបានសេវាអប់រំប្រកបដោយសមធម៌ (សូមមើលកម្មវិធីអង្គការមិនមែនរដ្ឋាភិបាលខាងក្រោម)។ | មិនទាន់បានវាស់វែង។ |
| | **ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-២០១៣,**[១៤] **ការលើកកម្ពស់ឲ្យទទួលបានការអប់រំ៖ គោលនយោបាយទី១៖** បង្កើនចំនួនអាហារូបករណ៍(ប្រាក់ ឬអាហារ) | សិស្សមកពីគ្រួសារក្រីក្រ (ជាពិសេសកុមារី) | | មិនទាន់បានវាស់វែង។ |

[១៤] ក្រសួងអប់រំ យុវជន និងកីឡា ផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ២០០៩-២០១៣ (ខែកញ្ញា ២០១០)។ សូមមើលគេហទំព័រ http://www.nepcambodia.org/userfiles/ESP_2009_2013_Final_en(1).pdf.

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | សម្រាប់សិស្សមកពីគ្រួសារក្រីក្រ ជាពិសេសកុមារី ដើម្បីធានាថា ពួកគេបាន ចូលរៀនសាលាបឋមសិក្សា និងមធ្យមសិក្សា។ ធានាពង្រឹងការគាំទ្រដើម្បីកាត់បន្ថយភាពក្រីក្រ និងធ្វើឲ្យមានសុវត្ថិភាពស្បៀងអាហារប្រសើរឡើង សំដៅទៅលើកម្មវិធីផ្តល់អាហារនៅសាលាបឋមសិក្សា និងកម្មវិធីផ្តល់ប្រាក់លើកទឹកចិត្តដល់សិស្សថ្នាក់ទី៧-៩។ | | | |
| | **គម្រោងគំនិតផ្តួចផ្តើមដើម្បីឲ្យបានការអប់រំឆាប់រហ័ស (មូលនិធិកាតាលិក) ផែនការសកម្មភាពបង្កើនការគាំទ្រវិស័យអប់រំ** (ESSSUAP), **ឆ្នាំ២០០៨-២០១២** ដែលត្រូវបានផ្តល់មូលនិធិដោយធនាគារពិភពលោក កំពុងជួយឲ្យកុមារ បញ្ចប់វដ្តអប់រំបឋមសិក្សាឲ្យបានពេញលេញ។ | សិស្សមកពីគ្រួសារក្រីក្រ និងសិស្សពូកែ | សិស្សថ្នាក់ទី៤ចំនួន៣៤៥៩នាក់មកពីខេត្តបីបានទទួលអាហារូបករណ៍ផ្អែកលើសមិទ្ធិផលសិក្សា ឬផ្អែកលើភាពក្រីក្រនៅក្នុងឆ្នាំ២០០៩-២០១០។ អាហារូបករណ៍ផ្អែកលើសមិទ្ធិផលសិក្សាត្រូវផ្តល់ជូនសិស្សពូកែ បន្ទាប់បញ្ចប់ការប្រឡងដោយជោគជ័យ។ កម្មវិធីអាហារូបករណ៍ផ្អែកលើភាពក្រីក្រជួយឲ្យសិស្សមកពីគ្រួសារក្រីក្រនៅ | នៅភាគខាងកើតនៃខេត្តមណ្ឌលគិរី សិស្សថ្នាក់ទី៤ប្រហែល៤០០នាក់បានទទួល អាហារូបករណ៍ក្នុងចំណោមអាហារូបករណ៍ច្រើនប្រភេទ ដែលបានជួយឲ្យកុមារមកពីក្រុមជនជាតិភាគតិចនៅរៀនបន្ត។[១៦] |

[១៦] Kalyanpur, M., បទបង្ហាញរបស់ FTI ស្តីពីកិច្ចប្រជុំភាពដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល *ការគេស្មើមតិ និងការអប់រំបញ្ចូលគ្នា៖ តួនាទីរបស់ FTI ។ ខែតុលា ឆ្នាំ២០១០* http://www.nepcambodia.org/pages.php?mainid=44&key3=Fifth%20Membership%20Meeting

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | | | រៀនបន្ត។<br><br>ការដាក់បញ្ចូលគម្រោង "សាកល្បង"ដ៏តូចនេះ អនុវត្តទៅតាមកម្មវិធីដែលមានពីមុនមក។ កម្មវិធីអាហារូបករណ៍ថ្មីទាំងនេះផ្តោតទៅលើថ្នាក់ពីមុនមកច្រើនជាងកម្មវិធីមុនៗ។ ហើយការបោះបង់ការសិក្សានៅតែជាបញ្ហាធ្ងន់ធ្ងរមួយ ក្នុងអំឡុងពេលសិក្សា ថ្នាក់បឋមសិក្សា។[១៥] | របាយការណ៍ពីធនាគារពិភពលោកសន្និដ្ឋានថា កម្មវិធីអាហារូបករណ៍មានផលប៉ះពាល់វិជ្ជមានទៅលើការចុះឈ្មោះចូល រៀន និងការចូលរៀន ជាពិសេស កុមារី ពោលគឺកុមារីមកពីគ្រួសារ ក្រីក្របំផុត។[១៧] |
| | អង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន៥៣ បានផ្តល់កម្មវិធីអាហារូបករណ៍ជាច្រើននៅក្នុងឆ្នាំ២០០៩មានជាអាទ៍ អង្គការ Plan, KrY, SCA, Maryknoll, MJP, OEC, PKO, RDA, SCADP, UPWD, SC, ASF, BFD, Hagar, KAPE, CARE, CIDC, HEKS, CCBO, Don Bosco, Damnok Toek Prey Veng, PTEA, VI, WFC, KCDI, RtR, WI, | កុមារនៅសាលារៀន | នៅឆ្នាំ២០០៩ អង្គការមិនមែនរដ្ឋាភិបាលំនួ៥៣ បានផ្តល់អាហារូបករណ៍ជាវត្ថុ ដែលរួមមានសម្ភារៈសិក្សា កង់ សម្លៀកបំពាក់ និងការគាំទ្រក្រៅពីហិរញ្ញវត្ថុផ្សេងទៀតសម្រាប់កុមារ និងយុវជនដែលចូលរៀន។ អង្គការមិនមែនរដ្ឋាភិ | ភាពរីកចម្រើនដែលត្រូវបានលើកឡើងដោយអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះអង្កេតរួមមាន៖ (ក)ការថយចុះនៃអត្រាសិស្សបោះបង់ និង អត្រាត្រួតថ្នាក់ និង(ខ)សិស្ស |

[១៥] Purcell, R., Riddell, A., Taylor, G., Vicheanon, K., ការវាយតម្លៃពាក់កណ្តាលត្រីមាសនៃគំនិតផ្តួចផ្តើមធ្វើឲ្យសម្រេចបានការអប់រំឆាប់រហ័ស ការសិក្សាករណីប្រចាំប្រទេសៈកម្ពុជា, ខែកុម្ភៈ២០១០ http://www.camb-ed.com/fasttrackinitiative/download/FTI_CR_Cambodia%28February2010y%29.pdf accessed 22 February 2011.

[១៧] ធនាគារពិភពលោក៖ *ការនាំកុមារីទៅរៀន៖ ភស្តុតាងពីកម្មវិធីអាហារូបករណ៍* ឆ្នាំ២០០៦។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្ដីអត្ថាធិប្បាយ | របាយការណ៍ស្ដីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | SCD, NH, WP, L.CDI, WVC, COWS, KYA, KAFDOC, WE, DYCFE, KWWA, YRDP, CORDE, APS, WRCD, SDCC, APESCA, REDA, Krousar Thmey, PVT, MVI, CWDCC, Mode, BSDA, KNKS, និង KCTO. | | បាលមួយចំនួនគ្រាន់តែផ្ដល់ជាកញ្ចប់នៃសម្ភារៈសិក្សា នៅពេលចាប់ផ្ដើមឆ្នាំសិក្សា។ អង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀតផ្ដល់មធ្យោបាយធ្វើដំណើរ (កង់) ដើម្បីឲ្យកុមារក្រីក្រដែលរស់នៅឆ្ងាយ អាចធ្វើដំណើរមករៀនបាន។ អង្គការមិនមែនរដ្ឋាភិបាលចំនួន១៩ផ្ដល់អាហារូបករណ៍ជាសាច់ប្រាក់ ដល់កុមារដែលចំណាយពេលទៅលើការសិក្សារបស់ខ្លួន ក្នុងនោះមានអាហារ និងថ្លៃស្នាក់នៅ។អង្គការមិនមែនរដ្ឋាភិបាលចំនួន១១បានផ្ដល់ជំនួយតាមរូបភាពផ្សេងទៀត ដូចជា អាហារ ការស្នាក់នៅ និងឧបត្ថម្ភដល់ថ្នាក់រៀនគួរបន្ថែម។ | អាហារូបករណ៍ជាច្រើនដែលបានប្រឡងជាប់ និងមករៀនទៀងទាត់។ លើសពីនេះទៅទៀត អាហារូបករណ៍ទាំងនេះបានជួយឲ្យកុមារបញ្ចប់បឋមសិក្សា និងបន្តទៅអនុវិទ្យាល័យ។ ការលំបាកមួយចំនួន គឺថាសិស្សមួយចំនួនបានបោះបង់ការសិក្សា បន្ទាប់ពីទទួលបានអាហារូបករណ៍ ហើយអាហារូបករណ៍រយៈពេលខ្លីមិនអាចធានាបាននូវការសិក្សារយៈពេលវែងនោះទេ (ឧ. អាហារូបករណ៍រយៈពេល០២-០៣ឆ្នាំសម្រាប់រយៈពេល០៦ឆ្នាំនៅបឋម សិក្សា)។[១៨] |

[១៨] របាយការណ៍អង្គការមិនមែនរដ្ឋាភិបាលស្ដីពីការអប់រំឆ្នាំ២០០៩ ភាពជាដៃគូអប់រំអង្គការក្រៅរដ្ឋាភិបាល ខែសីហា ២០១០ http://www.nepcambodia.org/userfiles/2009%20Education%20NGO%20Report%20August%2023%202010-%20_Final.pdf ថ្ងៃទី០៩ កុម្ភៈ ២០១១។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| ៨. តម្រូវការឯកសណ្ឋាន | ដើម្បីលើកកម្ពស់អនាម័យ សុខភាពកុមារ និងវិន័យសាលាឲ្យបានល្អ និងដើម្បីលើកកម្ពស់សុវត្ថិភាព និងគុណភាពនៃការអប់រំ **ក្រសួងអប់រំ ប្រកាសលេខ ២៧៨៦ អយក/ប្រក ឆ្នាំ២០០៩, បទបញ្ជាផ្ទៃក្នុងសម្រាប់ការអប់រំទូទៅ ជំពូកទី១ និងទី៣** តម្រូវឲ្យកុមារស្លៀកពាក់ឯកសណ្ឋាន។ **ករណីយកិច្ចរបស់សិស្ស** មាត្រា៧ តម្រូវឲ្យកុមារមានអនាម័យ និងស្លៀកពាក់ឯកសណ្ឋានសាលាឲ្យបានត្រឹមត្រូវ មុនពេលទៅសាលារៀន។ | សិស្សបឋមនិងមធ្យមសិក្សា | កុមារីត្រូវស្លៀកសំពត់ពណ៌ខៀវ និងពាក់អាវពណ៌ស ចំណែកឯកុមារាត្រូវស្លៀកខោពណ៌ខៀវ និងអាវពណ៌ស។ អាវរបស់កុមារា និងកុមារីត្រូវមាន ប៉ាក់ឈ្មោះសាលាថ្នាក់ និងឈ្មោះខ្លួននៅពីលើហោប៉ៅ។ | ជារឿយៗ គ្រួសារក្រីក្រមិនមានលទ្ធភាពទិញឯកសណ្ឋាន និងថ្លៃប៉ាក់ឈ្មោះឱ្យកូននៅលើអាវនោះទេ ដូច្នេះពួកគាត់គ្រាន់តែយកក្រដាសសរសេរឈ្មោះហើយបិទនៅលើហោប៉ៅនោះ។ ការនេះអាចកំណត់បានថា កុមារនោះមកពីគ្រួសារក្រីក្រ និងអាចប៉ះពាល់ដល់ឆន្ទៈក្នុងការនៅរៀនបន្តរបស់កុមារនោះ។ |
| | នៅឆ្នាំ២០០៩ អង្គការមិនមែនរដ្ឋាភិបាលចំនួន ៤៧ក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលចំនួន ៥៣ដែលផ្តល់**អាហារូបករណ៍ជាវត្ថុ** រួមមានសម្លៀកបំពាក់/ឯកសណ្ឋាន ដែលជាផ្នែកមួយនៃអាហារូបករណ៍។[១៩] | សិស្សបឋមនិងមធ្យមសិក្សា | ជាទូទៅអង្គការមិនមែនរដ្ឋាភិបាលបានផ្តល់ឯកសណ្ឋានពីរកំប្លេក្នុងមួយឆ្នាំដល់សិស្សក្រីក្របំផុត។ | |

[១៩] របាយការណ៍អង្គការមិនមែនរដ្ឋាភិបាលស្តីពីការអប់រំឆ្នាំ២០០៩ ភាពជាដៃគូអប់រំអង្គការក្រៅរដ្ឋាភិបាល ខែសីហា ២០១០, http://www.nepcambodia.org/userfiles/2009%20Education%20NGO%20Report%20August%2023%202010-%20Final.pdf accessed 9 February 2011.

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| ៩. ការផ្តល់សម្ភារៈសាលា, សៀវភៅសិក្សា និងសម្ភារៈសិក្សាផ្សេងទៀត | សម្ភារៈ និងឧបករណ៍ទាំងនេះត្រូវបានតម្រូវឲ្យមានដោយ**ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៩-១៣** និងត្រូវបានផ្តល់តាមរយៈដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងថវិការដ្ឋាភិបាល ដើម្បីគុណភាពនៃការរៀនសូត្រ និងបញ្ចប់កាលវិភាគកម្មវិធីសិក្សាប្រចាំឆ្នាំ។ | សាលាបឋមនិងមធ្យមសិក្សា | ក្រសួងអប់រំបានផលិតសៀវភៅសិក្សារៀងរាល់ឆ្នាំ បន្ទាប់មក PoE បានប្រគល់សៀវភៅទាំងនោះទៅឲ្យសាលានីមួយៗ។[២០] ក្រសួងអប់រំបានកែលម្អ និងធ្វើទំនើបកម្មកម្មវិធីសិក្សា និងសៀវភៅសិក្សាជាបណ្តើរៗ និងបានខិតខំប្រឹងប្រែងធ្វើយ៉ាងណាដើម្បីឲ្យសៀវភៅទាំងនោះបានដល់សិស្សប្រហែល៥០%នៅថ្នាក់អប់រំកម្រិតមូលដ្ឋាន និងប្រហែល៣០%នៅកម្រិតអនុវិទ្យាល័យ។[២១] | |
| ១០. ការប្រឡងចូលរៀន | | | | |
| ១១. កូតាឡើងថ្នាក់ | | | | |

[២០] អត្ថបទខ្លីៗពីលោក ពេជ្រ ប៊ុណ្ណា ប្រធាននាយកដ្ឋានបឋមសិក្សា ភ្នំពេញ ថ្ងៃទី១១ កុម្ភៈ ២០១១។
[២១] ផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ២០០៩-២០១៣ ការអនុវត្តវិស័យអប់រំ ឆ្នាំ២០០៦-២០១០។

| *ប្រធានបទគោលនយោបាយឬកម្មវិធី* | *ឯកសារ* | *ក្រុមគោលដៅ* | *ការបរិយាយ/សេចក្តីអត្ថាធិប្បាយ* | *របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា* |
|---|---|---|---|---|
| ១២. ការឡើងថ្នាក់ដោយស្វ័យប្រវត្តិ | **ក្រសួងអប់រំ សារាចរណែនាំលេខ ២៨អយក / សណន, ដំណើរការនៃការអប់រំបឋមសិក្សា និងគ្រឹះស្ថានមតេយ្យសិក្សារដ្ឋ ឆ្នាំ២០១០** មានបំណងត្រួតពិនិត្យការរៀនសូត្ររបស់សិស្ស ដើម្បីលើកទឹកចិត្តឲ្យសិស្សខិតខំរៀនសូត្រ និងធានាឲ្យបាននូវការអប់រំតាមស្តង់ដារ និងឆ្លើយតបទៅនឹងគោលដៅអប់រំ EFA ។ មិនមានការប្រឡងចូលរៀនសាលាបឋមសិក្សានោះទេ។ ប៉ុន្តែសិស្សទាំងឡាយត្រូវប្រឡងជាប់ឆមាស ដើម្បីឡើងថ្នាក់។ | សិស្សបឋមសិក្សា | **មាត្រា៣.១.២ នៃប្រកាស៖** ចាប់ផ្តើមនៅឆ្នាំ២០១០ សិស្សសាលាបឋមសិក្សាត្រូវប្រឡងបញ្ចប់ឆមាសនីមួយៗ។ សិស្សណាដែលប្រឡងធ្លាក់ត្រូវចូលប្រឡងបញ្ចប់ឆ្នាំ មុនពេលចាប់ផ្តើមឆ្នាំសិក្សាថ្មីតាមជម្រើសមុខវិជ្ជារបស់សិស្សនោះ។ ជម្រើសទាំងនោះមាន១០គឺ ភាសាខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា សីលធម៌ និងសិល្បៈ។[២២] | |
| ១៣. ការកំណត់វដ្តនៃការសិក្សា | **ក្រសួងអប់រំ សារាចរណែនាំលេខ ២៨អយក/សណន ឆ្នាំ២០១០** លើកទឹកចិត្តឲ្យឪពុកម្តាយ នាំកូនដែលមានអាយុ០៦ឆ្នាំ ឬយ៉ាងតិច៧០ខែ មកចុះឈ្មោះចូលរៀនថ្នាក់ទី១ឲ្យបានទាន់ពេលវេលា។ | ឪពុកម្តាយកុមារគ្រប់អាយុចូលរៀន | | |

[២២] បទសម្ភាសន៍ជាមួយឯកឧត្តម អ៊ុំ អេង អគ្គនាយករងនៃនាយកដ្ឋានអប់រំ លោកជុំ សុផល នាយករងបឋមសិក្សា លោក អ៊ឹង ង៉ូហុក នាយកមធ្យមសិក្សា នៅនាយកដ្ឋានអប់រំទូទៅ ភ្នំពេញ ថ្ងៃទី០៣ កុម្ភៈ ២០១១។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| ១៤. ការប្រឡងចេញឬបញ្ចប់ឆ្នាំសិក្សា | **ច្បាប់អប់រំឆ្នាំ២០០៧ ជំពូកទី III,រដ្ឋបាល និងការគ្រប់គ្រងការអប់រំ, មាត្រា១៩៖ ការចេញវិញ្ញាបនបត្រ និងសញ្ញាបត្រ៖** វិញ្ញាបនបត្រ និងសញ្ញាបត្រនឹងត្រូវប្រគល់ជូនសិស្សដែលបានបំពេញនូវរាល់តម្រូវការនៃការសិក្សាដែលត្រូវបានកំណត់ដោយគ្រឹះស្ថានអប់រំ។ វិញ្ញាបនបត្រ ឬសញ្ញាបត្រនឹងត្រូវក្រសួងទទួលបន្ទុក ឬគ្រឹះស្ថានអប់រំដែលចេញវិញ្ញាបនបត្រ ឬ សញ្ញាបត្រ ដកហូត ឬមិនប្រគល់ជូន ក្នុងករណីដែល អធិការកិច្ចរកឃើញភាពមិនត្រឹមត្រូវនៃដំណើរការអប់រំរបស់សិស្សនោះ ឬភាពមិនត្រឹមត្រូវនៃ ការសម្រេចចិត្តប្រគល់ជូនវិញ្ញាបនបត្រ ឬសញ្ញាបត្រទៅឲ្យសិស្សនោះ។ | សាលាបឋម និងមធ្យមសិក្សា | សញ្ញាបត្រថ្នាក់ទី១២ត្រូវបានចេញដោយក្រសួងអប់រំនៅថ្នាក់ជាតិ។ សិស្សទាំងឡាយត្រូវប្រឡងជាប់ថ្នាក់ទី១២តាមការកំណត់ និងអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡា។សិស្សដែលឈប់រៀនមុនថ្នាក់ទី១២អាចទទួលចំណារពីការិយាល័យអប់រំខេត្តបញ្ជាក់ពីថ្នាក់ដែលខ្លួនបានរៀនចប់ ពោលគឺ បានប្រឡងជាប់ឆមាសទី២នៅថ្នាក់ដែលខ្លួនបានរៀនចប់នោះ។ | |
| | **ក្រសួងអប់រំ សារាចរណែនាំ លេខ០១ អយក/សណន, ឆ្នាំ២០១០ ការប្រឡងថ្នាក់ជាតិសម្រាប់អក្ខរកម្មថ្នាក់មធ្យមសិក្សា និងក្រោយមធ្យម** | សិស្សថ្នាក់ទី៩និងទី១២ | ការប្រឡងថ្នាក់ទី៩ និងទី១២ត្រូវបានកំណត់ដោយក្រសួងអប់រំ។ គ្រូបង្រៀនត្រូវបានផ្លាស់ប្តូរទៅសាលាផ្សេងទៀតនៅទូទាំងខេត្ត ដើម្បីឃ្លាំ | អង្គការមិនមែនរដ្ឋាភិបាលបានកត់សម្គាល់ថា ជារឿយៗសិស្សដែលប្រឈមនឹងការប្រឡងធ្លាក់ថ្នាក់ទី៩ |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | **សិក្សា។**<br>ការប្រឡងនឹងត្រូវធ្វើឡើងនៅដំណាច់វគ្គនៃថ្នាក់ទី៩ និងទី១២ ដើម្បីត្រួតពិនិត្យលទ្ធផលរៀនសូត្រ និងបង្រៀន និងធានាបាននូវការអប់រំតាមស្តង់ដារ<br>និងធានាឆ្លើយតបទៅនឹងគោលដៅអប់រំ EFA។ | | មើល និងត្រួតពិនិត្យការប្រឡង។ ការប្រឡងថ្នាក់ទី៩ត្រូវបានធ្វើឡើងក្នុងខេត្តនោះតែម្តង ហើយក្រដាសប្រឡងថ្នាក់ទី១២ត្រូវបានបញ្ជូនមកកែនៅរាជធានីភ្នំពេញ។ | បានបោះបង់ការសិក្សា។ ពួកគេសង្ឃឹមថា ការប្រឡងថ្នាក់ទី៩នេះអាចនឹងត្រូវលុបចោល ដើម្បីកាត់បន្ថយអត្រាសិស្សបោះបង់ការសិក្សា។[២៣] |
| ១៥.គោលនយោបាយទាក់ទងនឹងយេនឌ័រ | **គោលនយោបាយសាលាកុមារមេត្រី ឆ្នាំ២០០៧ វិសាលភាពទី៤ ការឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ៖**<br>ដើម្បីលើកកម្ពស់ការយល់ដឹងនៅតាមសាលារៀន គ្រួសារ និងសហគមន៍អំពីតួនាទី និងការទទួលខុសត្រូវក្នុងការផ្តល់ការអប់រំ និងឱកាសអប់រំស្មើគ្នា និងដោយសមធម៌ដល់កុមារា និងកុមារី ដើម្បីឲ្យពួកគេអាចចូលរួមស្មើភាពគ្នានៅរាល់សកម្មភាពនៅសាលារៀន គ្រួសារ | សាលារៀន គ្រួសារ និងសហគមន៍ | សកម្មភាពយេនឌ័រត្រូវបានបញ្ជ្រាបគ្រប់ផ្នែកនៃគោលនយោបាយនេះ។ លក្ខណៈចម្បងមួយគឺការផ្តល់អ្នកប្រឹក្សាយោបល់សម្រាប់កុមារី ពីព្រោះពួកគេអាចរួមចំណែកសំខាន់នៅក្នុងសមធម៌យេនឌ័រដោយផ្តល់ការគាំទ្រដល់កុមារី និងលើកឡើងពីស្ថានភាពរបស់អ្នកគ្រូ និងផ្តល់ឱកាសឲ្យពួកគាត់មានការទទួលស្គាល់ និងការអភិវឌ្ឍវិជ្ជាជីវៈ។[២៤] | គម្រោងប្រឹក្សាយោបល់សម្រាប់កុមារីដែលដំបូងឡើយត្រូវបានរៀបចំដោយអង្គការអប់រំពិភពលោក និងត្រូវបានណែនាំនៅក្នុងអង្គការយូនីសេហ្វបានគាំទ្រដល់សាលារៀននៅឆ្នាំ២០០៧ អាចជាយន្តការដ៏មានប្រសិទ្ធភាពក្នុងការកាត់បន្ថយសិស្សបោះបង់ការសិក្សា យោងតាមរបាយការណ៍ជាច្រើនដែលត្រូវបាន |

[២៣] បទសម្ភាសន៍ជាមួយលោក អ៊ុន សមរិទ្ធិ អ្នកសម្របសម្រួលភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ភ្នំពេញ ថ្ងៃទី០៩ កុម្ភៈ ២០១១។

[២៤] Macro International Inc., ការវាយតម្លៃចុងក្រោយនៃកម្មវិធី OPTIONS នៃអង្គការអប់រំពិភពលោកនៅខេត្តព្រៃវែង ឆ្នាំ២០០៣-២០០៧។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | និងសង្គម។ | | | ពិនិត្យឡើងវិញដោយក្រសួងអប់រំ។ |
| | **ផែនការយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រថ្មីនៅក្នុងការអប់រំរបស់ក្រសួងអប់រំ**(មិនទាន់បានផ្សព្វផ្សាយនៅឡើយ) ព្យាយាមកែលម្អឥរិយាបថ និងតម្លៃសង្គមដែលរារាំងដល់ការអប់រំរបស់កុមារី និងសមភាពយេនឌ័រ។ | សិស្សស្រី គ្រូបង្រៀន និងបុគ្គលិកសាលារៀន | គោលនយោបាយថ្មីនេះរួមមាន ការបណ្តុះបណ្តាលស្ត្រីនៅក្នុងតួនាទីជាអ្នកដឹកនាំ ការអភិវឌ្ឍ *សៀវភៅប្រឹក្សាយោបល់សម្រាប់កុមារី*[២៥] និងការបណ្តុះបណ្តាលការយល់ដឹងអំពីយេនឌ័រ ដល់នាយកសាលា នាយករង បុគ្គលិកថ្នាក់ខេត្ត និងស្រុក និងគ្រូបង្រៀន។ | ស្ថិតិទាំងនេះបង្ហាញថា អត្រាចុះឈ្មោះចូលរៀនសរុប កុមារា និងកុមារីបានកើនឡើង ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ហើយសមិទ្ធផលនានាត្រូវបានបង្កើតឡើងដើម្បីកាត់បន្ថយគម្លាតយេនឌ័រ។[២៦] ដូច្នេះ សៀវភៅប្រឹក្សាយោបល់សម្រាប់កុមារីត្រូវបានរៀបចំឡើង ហើយគម្រោងនេះត្រូវបានដាក់បញ្ចូលទៅក្នុងសាលាកុមារ មេត្រីនៃក្រសួង |

[២៥] ត្រូវបានអភិវឌ្ឍដោយគម្រោងអប់រំពិភពលោក និងត្រូវបានអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡានៅឆ្នាំ២០១០។

[២៦] អត្រាពិតនៃការចូលរៀននៅកម្រិតបឋមសិក្សាពី៨៧% ដល់៩២% នៅចន្លោះឆ្នាំ២០០២ និង២០០៧, អត្រាចុះឈ្មោះចូលរៀនរបស់កុមារីបានកើនឡើងពី៨៥% ដល់៩១%ក្នុងអំឡុង ពេលតែមួយ ក្រសួងកិច្ចការនារី៖ *ចំណែកស្មើគ្នាសម្រាប់ស្ត្រី៖ ការវាយតម្លៃយេនឌ័រនៅកម្ពុជា ឆ្នាំ២០០៨។*

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | | | | អប់រំដោយកំណត់នូវសកម្មភាពស្នូលសម្រាប់អនុវត្តនៅទូទាំងប្រទេស។[២៧] |
| | **គណៈកម្មាធិការអនុសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងមកលើស្ត្រី** ដែលត្រូវបានផ្តល់សច្ចានុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៩២ មាត្រា១០៖ ភាគីទាំងឡាយត្រូវ ចាត់នូវរាល់បទបញ្ញាសមស្របដើម្បីលុបបំបាត់ ការរើសអើងមកលើស្ត្រី ដើម្បីធានាថា ស្ត្រី ទទួលបានសិទ្ធិស្មើនឹងបុរសនៅក្នុងវិស័យអប់រំ និងឈរលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី៖ | ប្រជាពលរដ្ឋ និងស្ថាប័នអប់រំ | ការយកចិត្តទុកដាក់ចំពោះការអនុវត្តអនុសញ្ញានេះត្រូវបានធ្វើឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។[២៨] CEDAW បានដាក់ជូនរបាយការណ៍មួយស្តីពីការអនុវត្តអនុសញ្ញានៅក្នុង រាជរដ្ឋាភិបាលកម្ពុជា (របាយការណ៍ចុងក្រោយ ឆ្នាំ២០០៥) ដែលលើកឡើងពីផ្នែកនានា ដូចជា ការបោះបង់ការសិក្សា និងផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាលដើម្បីរកដំណោះស្រាយ។ | មិនមានភស្តុតាងពិតប្រាកដអំពីសិស្សបោះបង់ការសិក្សា, ភាគច្រើនបង្ហាញពីគម្លាតយេនឌ័រប៉ុណ្ណោះ |

[២៧] សកម្មភាពមួយក្នុងចំណោមសកម្មភាពជាច្រើនដែលគ្រោងធ្វើតាមផែនការការងាររបស់ EBEP សម្រាប់ឆ្នាំ២០១០ រួមមាន ការពង្រឹងសមត្ថភាពនៃក្រុមការងារយេនឌ័រដើម្បីគ្រប់គ្រងសកម្មភាពប្រឹក្សាយោបល់សម្រាប់កុមារី។ លើសពីនេះទៅទៀត ការពង្រីកកម្មវិធីប្រឹក្សាយោបល់សម្រាប់កុមារីនឹងបន្តធ្វើនៅគ្រប់ខេត្តដែលគាំទ្រដោយអង្គការយូនីសេហ្វ ហើយមន្ទីរអប់រំយុវជន និងកីឡាខេត្តនឹងត្រូវបានស្នើសុំជាថ្មីឲ្យធ្វើការវិភាគលើចំនួនកុមារី ដែលនៅបន្តការសិក្សា ដោយសារតែមានការគាំទ្រពីអ្នកប្រឹក្សាយោបល់សម្រាប់កុមារី។*កម្មវិធីពង្រីកការអប់រំកម្រិតមូលដ្ឋាន (EBEP) ដំណាក់កាលទី២៖ របាយពិនិត្យឡើងវិញឆ្នាំ២០០៦-២០១០ សម្រាប់ឆ្នាំ២០០៩,* ខែមេសា ២០១០ អង្គការ SIDA/វិទ្យាស្ថានអន្តរជាតិ សម្រាប់ផែនការអប់រំ/អង្គការយូណេស្កូ http://www.iiep.unesco.org/fileadmin/user_upload/News_And_Events/pdf/2010/SATReviewreport2009.pdf

[២៨] http://cedaw-seasia.org/cambodia_cedaw_implementation.html ថ្ងៃទី២៣ កុម្ភៈ ២០១១។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | (ក)ទទួលបានល័ក្ខខ័ណ្ឌការងារ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការសិក្សាស្មើគ្នា និងឈានដល់ការទទួលសញ្ញាបត្រនៅក្នុងគ្រឹះស្ថានអប់រំគ្រប់ប្រភេទទាំងនៅតំបន់ជនបទ និងទីក្រុង និងត្រូវធានាឲ្យមានសមភាពនេះនៅមត្តេយ្យសិក្សាការអប់រំទាំង បច្ចេកទេស វិជ្ជាជីវៈ និងការអប់រំបច្ចេកទេសជាន់ខ្ពស់ ព្រមទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈគ្រប់ប្រភេទ<br>(ខ)ការទទួលបាន កម្មវិធីសិក្សាដូចគ្នា ការប្រឡងដូចគ្នា បុគ្គលិក បង្រៀនដែលមានលក្ខណៈសម្បត្តិនៃស្តង់ដារ ដូចគ្នា អគារសិក្សា និងឧបករណ៍ដែលមានគុណភាពដូចគ្នា<br>(គ) ការលុបបំបាត់ចោលផ្នត់គំនិតសង្គមអំពីតួនាទីបុរស និងស្ត្រីនៅគ្រប់ជាន់ថ្នាក់ និងគ្រប់ទម្រង់នៃការអប់រំ ដោយលើកទឹកចិត្តឲ្យមានការអប់រំរួមគ្នា និងប្រភេទអប់រំផ្សេងទៀត ដែលនឹងជួយឲ្យសម្រេចបានគោលបំណងនេះ | | ឧត្តមក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីបានរៀបចំរបាយការណ៍ជាប្រចាំស្តីពីសកម្មភាពរបស់ខ្លួនរួមមានការអនុវត្ត CEDAW នៅកម្ពុជា។<br>នៅក្នុងរបាយការណ៍ឆ្នាំ២០១០ ឧត្តមក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីបានធ្វើអត្ថាធិប្បាយអំពីការចាត់បទបញ្ជារបស់ក្រសួងអប់រំ ដើម្បីឲ្យកុមារីមានឱកាសទទួលបានការអប់រំតាមរយៈកសាងសាលារៀន អន្តេវាសិកដ្ឋានសម្រាប់កុមារី ហើយក្រសួងអប់រំ យុវជន និងកីឡា បានបញ្ជ្រាបយេនឌ័រទៅក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កម្រិតកម្មវិធីសិក្សាចំណេះដឹងទូទៅ កម្មវិធីបំប៉នបន្ថែមសម្រាប់មន្ត្រីដឹកនាំគ្រប់ជាន់ថ្នាក់និងកម្មវិធីអប់រំក្រៅប្រព័ន្ធ។<br>ក្នុងការជ្រើសរើសគ្រូបឋមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា កំណត់អាទិភាពសម្រាប់បេក្ខជននានាមកពីតំបន់ងាយរងគ្រោះ និងតំបន់ | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | ជាពិសេស ដោយការកែសម្រួលសៀវភៅសិក្សា និងកម្មវិធីសិក្សា និងការបង្កើតវិធីសាស្រ្តបង្រៀន។ (ឃ) ឱកាសស្មើគ្នាក្នុងការទទួលប្រយោជន៍ពីអាហារូបករណ៍ និងការផ្តល់ជំនួយដល់ការសិក្សាផ្សេងទៀត (ង)ឱកាសស្មើគ្នាក្នុងការទទួលបានកម្មវិធីបន្តការអប់រំ រួមមាន កម្មវិធី អក្ខរកម្មតាមមុខងារសម្រាប់មនុស្សពេញវ័យ ជាពិសេសដើម្បីកាត់បន្ថយគម្លាតនៃការអប់រំរវាង បុរស និងស្រ្តីឲ្យបានឆាប់បំផុតតាមតែអាចធ្វើទៅបាន។ (ច) ការកាត់បន្ថយអត្រាកុមារីបោះបង់ការសិក្សា និងការរៀបចំកម្មវិធីសម្រាប់កុមារី និងស្រ្តីដែលបានឈប់រៀនមុនកាលកំណត់ (ឆ)ឱកាសដូចគ្នាក្នុងការចូលរួមសកម្មនៅក្នុងសកម្មភាពកីឡា និងការអប់រំកាយ និង | | ដាច់ស្រយាល ដោយកាត់បន្ថយរូបមន្តពី១២+២មកនៅត្រឹម៩+២ ហើយក្នុងករណីមានពិន្ទុស្មើគ្នានោះបេក្ខនារីត្រូវបានផ្តល់អាទិភាពមុនគេ[២៩] | |

[២៩] របាយការណ៍សង្ខេបចុងក្រោយស្តីពីសកម្មភាពនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្រ្តី (CNCW) នៅឆ្នាំ២០១០ និងគោលការណ៍ណែនាំសម្រាប់ឆ្នាំ២០១១។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | (ជ) ទទួលបានព័ត៌មានអប់រំច្បាស់លាស់ ដើម្បីជួយធានាឲ្យបាននូវសុខភាព និងសុខុមាលភាពគ្រួសារ រួមមានព័ត៌មាន និងការណែនាំអំពីការធ្វើផែនការគ្រួសារ។ | | | |
| | **អគ្គលេខាធិការដ្ឋានយេនឌ័រ និងអប់រំស្ត្រីនៃក្រសួងអប់រំ, (២០០៦/៧) គណៈកម្មាធិការក្រុមប្រឹក្សាកុមារីៈ**ដើម្បីលើកទឹកចិត្តឲ្យកុមារីបញ្ចប់ការអប់រំរយៈពេល០៩ឆ្នាំ គណៈកម្មាធិការក្រុមប្រឹក្សាកុមារីនឹងត្រូវបង្កើតឡើងនៅក្នុងសាលារៀននៅតំបន់ដាច់ស្រយាល ជាពិសេសនៅកន្លែងដែលគេបានកសាងអន្តេវាសិកដ្ឋានសម្រាប់កុមារី។<br>គណៈកម្មាធិការក្រុមប្រឹក្សាកុមារីនីមួយៗត្រូវតាមដានអវត្តមាន ពិនិត្យមើលគុណភាពនៃការ | កុមារីថ្នាក់ទី១-៩ | | គណៈកម្មាធិការក្រុមប្រឹក្សាកុមារីបានចាប់ផ្តើមនៅឆ្នាំ២០០៧/៨ និងចាប់តាំងពីចំនួនភាគរយនៃកុមារីដែលនៅរៀនបន្តបានកើនឡើង រាជរដ្ឋាភិបាលកម្ពុជាសន្មតថា យុទ្ធសាស្ត្រនេះបានបង្ហាញពីភាពជោគជ័យ។[៣០] |

[៣០] រាជរដ្ឋាភិបាលកម្ពុជា របាយការណ៍ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្តីពីការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រីខ្មែរ និងគ្រួសារ សម្រាប់ឆ្នាំ២០១០ និងគោលដៅសម្រាប់ឆ្នាំ២០១១ ដែលត្រូវបានបង្ហាញកាលពីថ្ងៃទី០៨ កុម្ភៈ ២០១១ ភ្នំពេញ។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | រៀនសូត្រ និងគាំទ្រដល់កុមារីដែលឈានទៅរកភាពពេញវ័យ។ | | | |
| ១៦. ការគាំទ្រសិស្សប្រឈមនឹងការបោះបង់ការសិក្សា និងសិស្សពិការ | **ច្បាប់អប់រំឆ្នាំ២០០៧ មាត្រា៣៨ ការអប់រំពិសេស៖**រដ្ឋលើកទឹកចិត្ត និងលើកស្ទួយឲ្យទទួលបានការអប់រំពិសេសសម្រាប់ជនពិការ និង<br>**មាត្រា៣៩, សិទ្ធិរបស់សិស្សពិការ៖**<br>សិស្សពិការមានសិទ្ធិដូចគ្នានឹងសិស្សមិនពិការ និងមានសិទ្ធិពិសេសផ្សេងៗដូចខាងក្រោម៖<br>• អ្នករៀនសូត្រពិការទាំងពីរភេទមានសិទ្ធិទទួលការសិក្សាជាមួយសិស្សមិនពិការ ប្រសិនបើមានការសម្របសម្រួលគ្រប់គ្រាន់នៅក្នុងដំណើរការសិក្សាសម្រាប់សិស្សពិការ ដើម្បីបំពេញតាមកម្មវិធីអប់រំរបស់ស្ថាប័នអប់រំ។<br>• សិស្សពិការដែលមានតម្រូវការពិសេសមានសិទ្ធិទទួលបានការបង្រៀនបន្ថែមនៅក្នុងកម្មវិធីអប់រំជាប្រចាំ ដែលមិនមែនជាកម្មវិធីអប់រំ | កុមារ និងយុវជនពិការ | រដ្ឋាភិបាលមានផលប៉ះពាល់ផ្ទាល់ទៅលើការអនុវត្តមាត្រា៣៩៖<br>• កែលម្អលទ្ធភាពនៃការទទួលបាននៅក្នុងសំណង់សាលារៀនថ្មី ក្នុងនោះមានដូចជាទីជម្រាល។<br>• អាជ្ញាធរសាលារៀនត្រូវបានគេមើលឃើញថាស្វាគមន៍ចំពោះសិស្សពិការ។<br>• នៅក្នុងក្រសួងអប់រំ គឺនាយកដ្ឋានអប់រំពិសេសដែលផ្តោតទៅលើការគាំទ្រសិស្សពិការ ជនជាតិភាគតិចនិងក្រុមងាយរងគ្រោះ។ | |

| ប្រធានបទ គោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | ពិសេសនោះទេ ហើយ<br>• សិស្សពិការដែលមិនអាចរៀនជាមួយសិស្សមិនពិការ មានសិទ្ធិទទួលបានការអប់រំពិសេស នៅក្នុងថ្នាក់ពិសេសផ្សេងៗគ្នា។ សិស្សពិការទាំងនេះអាចសិក្សានៅសាលាសហគមន៍នៅក្នុងតំបន់ដែលពួកគេរស់នៅ។ | | | |
| | **គោលនយោបាយក្រសួងអប់រំ ស្តីពីការអប់រំសម្រាប់កុមារពិការ ឆ្នាំ២០០៨**<br>មានច្រើនគោលដៅ៖<br>• បង្កើនការយល់ដឹង និងការទទួលស្គាល់ជនពិការនៅក្នុងសហគមន៍ ស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធ។<br>• ផ្តល់អត្តសញ្ញាណកម្ម និងអន្តរាគមន៍តាមរយៈសេវាស្តារនីតិសម្បទា ដូចជា ការព្យាបាលដោយការហាត់ប្រាណ និងសេវាសុខភាព ដូចជា ការចាក់ថ្នាំបង្ការដល់កុមារពិការគ្រប់រូបពីកំណើតរហូតដល់អាយុ០៥ឆ្នាំ។ | កុមារ និងយុវជនពិការ | គោលនយោបាយនេះស្របនឹងវិសាលភាព៦នៃសាលាកុមារមេត្រី៖<br>• កំណត់ និងចុះឈ្មោះចូលរៀនសម្រាប់កុមារពិការ។<br>• អនុវត្តអន្តរាគមន៍លើកដំបូង និងសេវាផ្សេងទៀតសម្រាប់កុមារពិការ។<br>• ផ្តល់ឱកាស និងអនុវត្តកម្មវិធីអប់រំបញ្ចូលគ្នា។<br>• បង្កើនការចុះឈ្មោះចូលរៀនសម្រាប់កុមារីពិការ។<br>• លើកកម្ពស់ចំណេះដឹង និងការយល់ដឹងអំពីពិការភាព និង | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | • ផ្តល់ការអប់រំដែលមានគុណភាព បំណិនជីវិត ឬការបណ្តុះបណ្តាលវិជ្ជាជីវៈដល់កុមារ និងយុវជនពិការប្រកបដោយសមធម៌ និងប្រសិទ្ធភាព និង<br>• បង្កើនអត្រាចុះឈ្មោះចូលរៀន ឡើងថ្នាក់ និងអត្រាគង់វង្សនៅគ្រប់សាលារៀន។<br><br>នៅឆ្នាំ២០០០ ក្រសួងអប់រំបានបង្កើតការិយាល័យអប់រំពិសេសនៅនាយកដ្ឋានអប់រំបឋម ដោយទទួលខុសត្រូវចំពោះការអភិវឌ្ឍវិស័យអប់រំសម្រាប់កុមារពិការ កុមារជនជាតិភាគតិច កុមារក្រីក្រ កុមារី និងកុមារងាយរងគ្រោះ។ | | • គាំទ្រកម្មវិធីពីប្រព័ន្ធអប់រំ។ | |
| | ដោយមានកិច្ចសហការពីក្រុមប្រឹក្សាសកម្មភាពជនពិការ និងផ្តល់មូលនិធិដោយអង្គការយូនីសេហ្វ ឆ្នាំ២០០០-២០០១ ក្រសួងអប់រំបានអនុវត្ត **កម្មវិធីសាកល្បងអប់រំបញ្ចូលគ្នា**សម្រាប់កុមារពិការនៅសាលាកម្រងនៅក្នុងខេត្តស្វាយរៀង។ | កុមារ និងយុវជនពិការ និងគ្រូបង្រៀន | គម្រោងអប់រំបញ្ចូលគ្នាបានពង្រីកដល់ទៅ១៥ខេត្ត ១៥ស្រុក សាលាកម្រង១៤ និងសាលា៨០ ដោយការបណ្តុះបណ្តាលគ្រូបង្រៀនចំនួន៨២៨នាក់ (៣៩១ជាអ្នកគ្រូ)។ លើសពីនេះទៅទៀតមានថ្នាក់បញ្ចូលគ្នាចំនួន៩២នៅ១២ខេត្តសម្រាប់ | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | | | កុមារថ្លង់ និងពិការភ្នែក។ | |
| | ដោយសារតែគោលនយោបាយក្រសួងអប់រំស្តីពីការអប់រំសម្រាប់កុមារពិការ PTTC បានផ្តល់វគ្គសិក្សាពិសេសរយៈពេល១០ថ្ងៃដល់គ្រូបង្រៀន ដែលមានសមត្ថភាព ក្នុងអំឡុងពេលវិស្សមកាលស្តីពីការគាំទ្រដល់កុមារពិការ កុមារជាជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ កុមារមានបញ្ហាសុខភាពផ្លូវចិត្ត កុមារកំព្រា និងកុមារងាយ រងគ្រោះ។ | គ្រូបង្រៀន | អង្គការ DAC និងអង្គការ UNICEF បានជួយដល់ក្រសួងអប់រំក្នុងការអភិវឌ្ឍសៀវភៅសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនអំពីការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ។[៣១] អ្នកពាក់ព័ន្ធគ្រប់រូបដែលបានចូលរួមក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន សម្រាប់ការអប់រំបញ្ចូលគ្នា ត្រូវបានលើកទឹកចិត្តឲ្យប្រើប្រាស់សៀវភៅបណ្តុះបណ្តាលពេលចូល បម្រើការងារនេះ។ | |
| | **គោលនយោបាយគាំពារតាមជម្រើសរបស់ MoSVY ឆ្នាំ២០០៦៖**<br>គោលដៅទូទៅនៃគោលនយោបាយនេះគឺដើម្បីការពារសិទ្ធិរបស់កុមារ និងធានាឲ្យបាននូវការអភិវឌ្ឍផ្លូវកាយ និងផ្លូវចិត្តរយៈពេលវែងសម្រាប់កុមារកំព្រា និងកុមារងាយរងគ្រោះផ្សេងទៀត | កុមារប្រឈមនឹងការបោះបង់ការសិក្សា | យុទ្ធសាស្ត្រអនុវត្តគោលនយោបាយនេះរួមមាន:<br>• ការធ្វើការវាយតម្លៃលើតម្រូវការជាប្រចាំនៃវិស័យនានាដែលប៉ះពាល់ដល់កុមារកំព្រា និងកុមារងាយរងគ្រោះផ្សេងទៀត។<br>• ការអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយផ្តោតលើសិទ្ធិកុមារ ដែលបង្កើត និងធ្វើឲ្យកម្មវិធី និង | មិនទាន់បានវាស់វែង។ |

[៣១] ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល, របាយការណ៍អង្គការមិនមែនរដ្ឋាភិបាលស្តីពីការអប់រំឆ្នាំ២០០៩៖ http://www.nepcambodia.org/userfiles/2009%20Education%20NGO%20Report%20August%2023%202010-%20Final.pdf

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | ក្នុងនោះរួមមាន កុមារដែលគេបោះបង់ចោល កុមារឆ្លង ឬរងគ្រោះដោយមេរោគអេដស៍/ជំងឺអេដស៍ កុមារដែលត្រូវគេរំលោភ ទោះជារំលោភសេពសន្ថវៈ រំលោភលើរាងកាយ ឬផ្លូវចិត្តក្តី កុមារអនាថា កុមារមានទំនាស់ផ្លូវច្បាប់ កុមាររងគ្រោះដោយការកេងប្រវ័ញ្ចផ្លូវភេទ ឬពលកម្មដែលបង្កគ្រោះថ្នាក់ កុមារពិការ កុមារញៀនគ្រឿងញៀន និងកុមារដែលមានរាងកាយមិនពេញលក្ខណៈ។<br><br>គោលនយោបាយនេះរួមមានគោលដៅជាក់លាក់ក្នុងការធានាថា កុមារទាំងនេះទទួលបានសេវាសុខភាព ការអប់រំដោយឥតបង់ថ្លៃ និងការគាំទ្រផ្លូវចិត្តសម្រាប់ការរស់រានមានជីវិត និងការអភិវឌ្ឍរបស់កុមារ។ | | សេវាទាំងនេះមានលក្ខណៈផ្លូវការ ដើម្បីលើកកម្ពស់សុខុមាលភាពរបស់កុមារកំព្រា និងកុមារងាយរងគ្រោះផ្សេងទៀត។<br>• ការបង្កើនលទ្ធភាពរបស់កុមារកំព្រា និងកុមារងាយរងគ្រោះឲ្យទទួលបានសេវាមូលដ្ឋាន និង<br>• ធ្វើការត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំ ដើម្បីធានាថា កម្មវិធីដែលសំដៅចំពោះកុមារកំព្រា និងកុមារងាយរងគ្រោះផ្សេងទៀតបានឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ ហើយការអភិវឌ្ឍកម្មវិធីនេះគឺជាដំណើរការបន្តមួយ។<br><br>ក្រុមការងារ OVC<br>ជាតិពហុវិស័យទទួលភារកិច្ចនេះ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ និងបានអភិវឌ្ឍផែនការសកម្មភាពដើម្បីអនុវត្តគោល នយោបាយនេះ។ អង្គការមិនមែនរដ្ឋាភិបាលជាច្រើនកំពុងធ្វើការជាមួយ OVC ដើម្បីធានាថាកុមារ ទាំងនេះ | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | | | ទទួលបានការអប់រំតាមរយៈយុទ្ធសាស្ត្រ ផ្សេងៗ (ឧ. អាហារូបករណ៍ ការផ្តល់សម្ភារៈ សកម្មភាពបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារ/អាណាព្យាបាល។ | |
| | **គោលនយោបាយអង្គការយូណេស្កូ ស្តីពីការអប់រំបញ្ចូលគ្នា, គំនិតផ្តួចផ្តើមពី Epic Arts/VSO/ MoEYS ឆ្នាំ២០១០៖** ភាពជាដៃគូរវាង Epic Arts និងPTTC/VSO បានគាំទ្រគោលដៅក្នុងការផ្តល់វិធីសាស្ត្រដល់គ្រូបង្រៀនឲ្យយល់ដឹងអំពីការដាក់ បញ្ចូលសិស្សគ្រប់រូបទៅក្នុងបន្ទប់រៀនរបស់ពួកគេ។ ភាពជាដៃគូនេះមានបំណង៖<br>• បង្កើនការយល់ដឹងរបស់សិក្ខាកាមអំពីសិស្សពិការ។<br>• បង្រៀនហ្គេម និងសកម្មភាពផ្សេងៗដល់សិក្ខាកាម ដែលរួមបញ្ចូលសិស្សទាំងអស់។<br>• អនុញ្ញាតឲ្យសិក្ខាកាមពិភាក្សាជាមួយសិស្សពិការដើម្បីឈ្វេងយល់ថាតើការដាក់បញ្ចូលនេះ | សិក្ខាកាមគ្រូបង្រៀន | សាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពត មានសិក្ខាកាម២០០នាក់នៅក្នុងកម្មវិធីសិក្សារយៈពេលពីរឆ្នាំសម្រាប់គ្រូបឋមសិក្សា ដែលនឹងធ្វើការនៅស្រុកជនបទ។<br>Epic Arts បានបណ្តុះបណ្តាលសិស្សឲ្យសិល្បករសម្តែង និងបានសម្តែងនៅតាមសហគមន៍នានា ដើម្បីជួយឲ្យប្រជាពលរដ្ឋយល់ដឹងអំពីពិការភាព និងការដាក់បញ្ចូលគ្នា។<br><br>សិក្ខាកាមគ្រូបង្រៀនត្រូវបានផ្តល់នូវកម្រងសំណួរមុនចូលរៀនអំពីឥរិយាបថរបស់ពួកគេ ចំពោះសិស្សពិការ និងអំពើសម្លុតនានា និងអំពីទំនុកចិត្តរបស់ពួកគេក្នុងការដាក់បញ្ចូលសិស្សទាំងអស់ | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | មានផលប៉ះពាល់អ្វីខ្លះទៅលើពួកគេ។<br>• ផ្តល់បទពិសោធន៍ខ្លះដល់សិក្ខាកាមអំពីអ្វីដែលគេហៅថាពិការនោះ និង<br>• លើកទឹកចិត្តឲ្យសិក្ខាកាមចេះទទួលខុសត្រូវក្នុងការទប់ស្កាត់រាល់អំពើសម្លុតសិស្ស ដោយសារតែសិស្សនោះពិការ ឬប្លែកពីគ្នាឯង។ | | ទៅក្នុងបន្ទប់រៀន។ ពួកគេក៏ត្រូវបានសុំឲ្យកត់ត្រាឲ្យបានច្បាស់លាស់នូវអ្វីដែលអាចធ្វើ ដើម្បីដាក់សិស្សទាំងអស់បញ្ចូលគ្នា។ ក្នុងអំឡុង ពេលធ្វើសកម្មភាពទាំងនេះ មេរៀនដែលត្រូវឆ្លុះបញ្ចាំងត្រូវបានដឹកនាំដោយនាយករងនៃសាលាគរុកោសល្យ និងទីប្រឹក្សាអប់រំរបស់អង្គការ VSO។ សិក្ខាកាមទាំងនេះបានបំពេញកម្រងសំណួរទីពីរ និងត្រូវបានគេស្នើសុំឲ្យប្រៀបធៀបចម្លើយរបស់ពួកគេ។[៣២] | |
| | **អង្គការអប់រំពិភពលោក/អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា– គម្រោង IBEC**<br>ផ្តល់ការប្រឹក្សាយោបល់ដល់កុមារីដែលអវត្តមានពីការសិក្សា ដើម្បីលើកទឹកចិត្តឲ្យពួកគេវិលមករៀនវិញ។ | កុមារីប្រឈមនឹងការបោះបង់ការសិក្សា | | មិនទាន់បានវាស់វែង។ |

[៣២] ការអប់រំបញ្ចូលគ្នានៅក្នុងគម្រោងសកម្មភាព, http://www.inclusive-education-in-action.org/iea/index.php?menuid=25&reporeid=113

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្ដីអត្ថាធិប្បាយ | របាយការណ៍ស្ដីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | **អង្គការ KAPE - គម្រោង MORE** មានបំណងបង្កើនរំញោចផ្នែកវប្បធម៌ឲ្យបានដល់សិស្សជនជាតិចាម ដោយផ្ដល់ជំនួយការបង្រៀនពីរភាសាសម្រាប់ថ្នាក់ទី១ និងទី២ និងការបង្រៀនវប្បធម៌ចម្រុះ។ | សិស្សជនជាតិចាម ថ្នាក់ទី១-២ | | មិនទាន់បានវាស់វែង។ |
| | **មូលនិធិកុមារពិការ** បណ្ដុះបណ្ដាលគ្រូបង្រៀនពិសេស។ | ការអប់រំពិសេស, គ្រូបង្រៀន | | មិនទាន់បានវាស់វែង។ |
| | ដើម្បីធានាឲ្យបាននូវការចូលរៀន និងការបញ្ចប់ការសិក្សាសម្រាប់កុមារប្រឈមនឹងការបោះបង់ អង្គការមិនមែនរដ្ឋាភិបាលបានគាំទ្រ**កម្មវិធីសម្រាប់កុមារប្រឈមនឹងការបោះបង់ការសិក្សា** ដូចខាងក្រោម៖<br><br>បឋមសិក្សា៖<br>អង្គការ វីនរ៉ក់អន្តរជាតិសមាគមអ្នកស្ម័គ្រចិត្ត Shanti និង អង្គការសកម្មភាពសម្រាប់បឋម | កុមារប្រឈមនឹងការបោះបង់ការសិក្សា | ការគាំទ្រកម្មវិធីភាគច្រើនផ្ដោតទៅលើតម្រូវការរបស់កុមារ និងគ្រួសារ ក្នុងការទ្រទ្រង់ការអប់រំរបស់កុមារនោះ។ សេវាផ្សេងៗត្រូវបានផ្ដល់ទៅតាមតម្រូវការរបស់កុមារ និងគ្រួសារនោះ។ | អង្គការសេវាអ្នកស្ម័គ្រចិត្តនៅក្រៅប្រទេស (VSO) ជាអង្គការមិនមែនរដ្ឋាភិបាលមួយដែលផ្ដោតទៅលើកុមារប្រឈមនឹងការបោះបង់ការសិក្សា បានរាយការណ៍ថាអត្រាចុះឈ្មោះចូលរៀន និងឡើងថ្នាក់ ជាពិសេសសម្រាប់ ក្រុមគោលដៅ (កុមារី កុមារពិការ កុមារជនជាតិភាគតិច)បានកើនឡើង។ ជាទូទៅ អត្រាបោះបង់បានធ្លាក់ចុះនៅ |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | សិក្សានៅកម្ពុជា | | | តាមសាលារៀនស្រុក និងខេត្តនានាដែលមានអន្តរាគមន៍ពីអង្គការ VSO ។[៣៣] |
| | អង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀតបានផ្តល់សេវាអប់រំដល់កុមារពិការ។ ឧទាហរណ៍ អង្គការគ្រួសារថ្មី បានបង្កើតសាលាពិសេសសម្រាប់កុមារថ្លង់ និងពិការភ្នែក និងបានបណ្តុះបណ្តាលគ្រូបង្រៀនសាលារដ្ឋ អំពីភាសាកាយវិការ និងអក្សរសម្រាប់មនុស្សពិការភ្នែក ដើម្បីបង្រៀននៅថ្នាក់បញ្ចូលគ្នានៅសាលារដ្ឋ។[៣៤] | កុមារពិការ និងគ្រូបង្រៀន | | |
| ១៧.ប្រក្រតិទិនសាលា | **សារាចរណែនាំរបស់ក្រសួងអប់រំ លេខ ២១៣៨ អយក/សណន, ឆ្នាំ២០០៨ ការអនុវត្តប្រក្រតិទិនសម្រាប់ការអប់រំចំណេះដឹងទូទៅនៅសាលារដ្ឋ** | សាលារដ្ឋ | ក្នុងការអនុវត្តនេះ បុគ្គលិកកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សាទទួលដំណឹង (ពីអ្នកមានវិជ្ជាជីវៈអប់រំនៃអង្គការមិនមែនរដ្ឋាភិ | |

[៣៣] របាយការណ៍អង្គការមិនមែនរដ្ឋាភិបាលស្តីពីការអប់រំឆ្នាំ២០០៩ ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល, ខែសីហា ២០១០, http://www.nepcambodia.org/userfiles/2009%20Education%20NGO%20Report%20August%2023%202010-%20Final.pdf ថ្ងៃទី០៩ កុម្ភៈ២០១១។

[៣៤] ក្រសួងអប់រំ, គោលនយោបាយស្តីពីការអប់រំសម្រាប់កុមារពិការ ខែមីនា ២០០៨, http://nepcambodia.org/pdffiles/Disability%20Policy%20-%20English%2001-03-08.pdf

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | (ឯកសារចម្លងនៃគោលនយោបាយមិនមាននៅក្នុងកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សាទេ) មានបំណងពង្រឹងការអនុវត្តប្រក្រតិទិនសិក្សានៅសាលារៀន ដោយណែនាំប្រក្រតិទិនឲ្យស្រុក កម្រងសាលា និងសាលារៀនមូលដ្ឋានបានស្គាល់ និងការតម្រូវឲ្យចុះទស្សនកិច្ចតាមដានមូលដ្ឋាននៅសាលាដែលមិនបានអនុវត្តតាមប្រក្រតិទិនសិក្សាឲ្យបានត្រឹមត្រូវ ឧទាហរណ៍បិទសាលាគ្មានការអនុញ្ញាត។ | | បាល) និងមើលឃើញថា ក្នុងអំឡុងពេលដាំដុះ និងប្រមូលផល កុមារភាគច្រើនឈប់រៀនទៅជួយគ្រួសារធ្វើការងារនេះ។ កុមារមួយចំនួនវិលមករៀនវិញ បន្ទាប់ពីធ្វើការងារនេះចប់។ | |
| | **កាលវិភាគរៀនដែលអាចផ្លាស់ប្តូរបាន- អង្គការណ៍រ៉េសង្គ្រោះកុមារ (SCN),ឆ្នាំ១៩៩៨ដល់បច្ចុប្បន្ន** ឥឡូវនេះ ផ្នែកមួយនៃសារាចរណែនាំរបស់ក្រសួងអប់រំ ស្ថិតក្រោមវិសាលភាពទី៦នៃគោលនយោបាយសាលាកុមារមេត្រី។ គោលបំណងនេះគឺដើម្បីបង្កើនលទ្ធភាពទទួលបានការអប់រំ ដោយសារតែក្នុងអំឡុងរដូវច្រូតកាត់ ឬនេសាទ កុមារ (និងគ្រូបង្រៀន) | សាលាបឋមសិក្សា | ដើម្បីផ្លាស់ប្តូរកាលវិភាគសាលា ត្រូវមានការព្រមព្រៀងលើកដំបូងពីនាយកសាលា និងគ្រូបង្រៀននៅក្នុងសាលារៀន បន្ទាប់មកសាលារៀន និងអាជ្ញាធរមូលដ្ឋាន និងចុងក្រោយគឺឪពុកម្តាយ/អាណាព្យាបាលសិស្ស។ សាលារៀនជូនដំណឹងទៅនាយកដ្ឋាន ឬមន្ទីរអប់រំ ជូនកាលនាយកដ្ឋានឬមន្ទីរអប់រំស្នើសុំលិខិតព្រមព្រៀងដើម្បីធានាថាសាលារៀននោះបានពិភាក្សាអំពីបញ្ហានេះយ៉ាង | ប្រព័ន្ធនេះបានកាត់បន្ថយចំនួនកុមារដែលត្រូវរៀនត្រួតថ្នាក់ ដែលជាកត្តាប្រឈមនាំទៅរកការបោះបង់ការសិក្សា។ |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | ឧស្សាហ៍អវត្តមានណាស់។ ការធ្វើប្រហុកត្រូវបានចាត់ទុកជាប្រភពចម្បងមួយនៃអាហារសម្រាប់គ្រួសារជនបទ។ ភូមិនេសាទនៅលើទឹក ឬគោកនេសាទត្រីទៅតាមជំនោរនៃទឹកទន្លេ។ | | ច្បាស់លាស់ និងដោយយកចិត្តទុកដាក់ជាមួយសហគមន៍។<br><br>យោងតាមអង្គការ SCN បានឲ្យដឹងថា បច្ចុប្បន្ន មានសាលាចំនួន១២៣ ដែលមានកាលវិភាគរៀនដែលអាចផ្លាស់ប្តូរបាន មានជាអាទិ៍ដូចជា ខេត្តសៀមរាប កំពង់ឆ្នាំង ព្រះវិហារ កំពង់ចាម និងកោះកុង។ | |
| ១៨.និយាមថ្នាក់រៀន/សិស្សរៈផលធៀបគ្រូបង្រៀន | **សារាចរណែនាំរបស់ក្រសួងអប់រំ លេខ០៤ អយក/សណន**ចែងថា ក្នុងករណីដែលសាលាមិនមានបន្ទប់គ្រប់គ្រាន់ (និយាមថ្នាក់រៀនកំណត់ត្រឹម៥០នាក់) នាយកសាលាអាចបង្កើននិយាមនេះ ប៉ុន្តែមិនត្រូវឲ្យលើសពី៥៩នាក់នោះទេ។[៣៩] | សាលាបឋមសិក្សា | កាលពីអតីតកាល សាលាជាច្រើនមានថ្នាក់រៀនច្រើនជាងបន្ទប់រៀន ដែលនាំឲ្យចំនួនសិស្សច្រើនហួសកំណត់ ប៉ុន្តែដោយមានកម្មវិធីកសាងសាលារៀន បញ្ហានេះបានធ្លាក់ចុះបន្តិចម្តងៗ។ បុគ្គលិក SDPP យល់ពីការកំណត់និយាមថ្នាក់រៀនគឺ៤៥នាក់សម្រាប់មធ្យមសិក្សាបឋមភូមិ និង ៤០នាក់សម្រាប់មធ្យមសិក្សាទុតិយភូមិ ប៉ុន្តែគេ | |

[៣៩] បទសម្ភាសន៍ជាមួយលោកស្រីគុយ ផល្លា អនុប្រធាននាយកដ្ឋានផែនការ, ក្រសួងអប់រំ ភ្នំពេញ ថ្ងៃទី០៤ កុម្ភៈ ២០១១។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | | | មិនទាន់បានទទួលសារាចរ ណែនាំផ្លូវការស្តីពីនិយាមថ្នាក់រៀនពីក្រសួងនៅឡើយទេ។ | |
| ១៩.ការទទួលការអប់រំ/ចម្ងាយទៅសាលារៀន | **ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-២០១៣, គោលនយោបាយទី១៖ ការទទួលបានការអប់រំដោយសមធម៌៖** គួរតែមានការកសាងសាលារៀនទូទាំងប្រទេស ដើម្បីឲ្យសាលារៀននៅក្បែរកន្លែងដែលប្រជាពលរដ្ឋរស់នៅ។ (N.B. មិនទាន់មានបញ្ជាក់ពីចំនួនគីឡូម៉ែត្រជាអតិប្បបរមាពីសហគមន៍នៅក្នុងគោលនយោបាយនេះនៅឡើយទេ)។ | សាលាបឋមនិងមធ្យមសិក្សា | ចំនួនសរុបនៃសាលាបឋមសិក្សាអនុវិទ្យាល័យ និងវិទ្យាល័យបានកើនឡើងគួរឲ្យកត់សម្គាល់ពី៨,៦២៨ នៅឆ្នាំ២០០៥/៦ រហូតដល់១០,១១៥ នៅឆ្នាំ២០០៩/១០។ ការកើនឡើងតាមកម្រិតផ្សេងគ្នាគឺមានដូចតទៅ៖ សាលាបឋមសិក្សាកើនឡើងពី៦,២៧៧ នៅឆ្នាំ២០០៥/៦ ដល់ ៦,៦៦៥នៅឆ្នាំ២០០៩/១០, អនុវិទ្យាល័យកើនឡើងពី៩១១នៅឆ្នាំ២០០៥/៦ ដល់១,១៧២នៅឆ្នាំ២០០៩/១០ ហើយវិទ្យាល័យកើនឡើងពី២៥២ នៅឆ្នាំ២០០៥/៦ ដល់៣៨៣នៅឆ្នាំ២០០៩/១០។[៣៦] | |

[៣៦] បទសម្ភាសន៍ជាមួយលោកស្រីគុយ ផល្លា អនុប្រធាននាយកដ្ឋានផែនការ, ក្រសួងអប់រំ ភ្នំពេញ ថ្ងៃទី០៤ កុម្ភៈ ២០១១។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| ២០.ការដឹកជញ្ជូន | **ការផ្តល់កង់របស់អង្គការមិនមែនរដ្ឋាភិបាល** ជាទូទៅគឺជាផ្នែកមួយកម្មវិធីអាហារូបករណ៍។ | កុមារដែលរស់នៅឆ្ងាយពីសាលារៀន | ការផ្តល់កង់ជួយឲ្យកុមារអាចជិះទៅមកពីសាលារៀន ងាយស្រួលក្នុងការធ្វើដំណើរលើចម្ងាយផ្លូវដោយមានសុវត្ថិភាព។ | |
| ២១. ការផ្ទេរសាលា | **ប្រកាសរបស់ក្រសួងអប់រំ លេខ ១២៥៨ អយក/ប្រក ឆ្នាំ២០០៩ មាត្រា៩៖ សារាចរណែនាំស្តីពីការផ្ទេរសាលា** បញ្ជាក់ពីឯកសារដែលតម្រូវឲ្យសិស្សផ្ទេរទៅរៀននៅសាលាមួយទៀត | សិស្សថ្នាក់ទី១-៩ | ឪពុកម្តាយត្រូវបានតម្រូវឲ្យដាក់ជូននូវព្រឹត្តបត្រពិន្ទុ សៀវភៅសរសេរ កំណត់ត្រា លទ្ធផលសិក្សាប្រចាំឆ្នាំ និងសំបុត្រកំណើតរបស់សិស្ស។ | |
| | **សារាចរណែនាំរបស់ក្រសួងអប់រំលេខ ១៥៦០ ឆ្នាំ២០០០៖ សារាចរណែនាំស្តីពីការផ្ទេរសាលារៀន របស់សិស្សមធ្យមសិក្សា** មានកាលបរិច្ឆេទនៃការព្រមព្រៀងផ្ទេរសាលា (អនុញ្ញាតពីរដងក្នុងមួយឆ្នាំនៅខែកញ្ញា និងខែមីនា) ពាក្យសុំផ្ទេរសាលា ការរៀបចំពាក្យសុំផ្ទេរ និងឋានានុក្រមនៃការផ្ទេរ សាលា(រវាងសាលាជនបទ ទីក្រុង និងខេត្ត និងសាលាឧបសម្ព័ន្ធ)។ | សិស្សមធ្យមសិក្សា | នៅក្នុងករណីពិសេស ឬចាំបាច់ ក្រសួងនឹងយល់ព្រមទទួលការផ្ទេរសាលា ប្រសិនបើសិស្សនោះ ត្រូវការផ្ទេរទៅតាមឪពុកម្តាយ/អាណាព្យាបាលរបស់ពួកគេ។ ត្រូវបំពេញពាក្យសុំនេះ ដោយផ្ទៀងផ្ទាត់សេចក្តីលម្អិតពីសៀវភៅគ្រួសារ និងឬសំបុត្រកំណើត។ ពាក្យសុំទាំងនេះត្រូវឆ្លងកាត់នាយកដ្ឋានអប់រំផ្សេងៗ។ | |

| *ប្រធានបទគោលនយោបាយឬកម្មវិធី* | *ឯកសារ* | *ក្រុមគោលដៅ* | *ការបរិយាយ/សេចក្តីអត្ថាធិប្បាយ* | *របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា* |
|---|---|---|---|---|
| **អគារសិក្សា** | | | | |
| ២២. លទ្ធភាពទទួលបានអគារសិក្សាកុមារីមេត្រី | **គំនិតផ្តួចផ្តើមឲ្យសម្រេចបានការអប់រំឆាប់រហ័ស, គម្រោង ESSSUAP, ឆ្នាំ២០០៨-២០១២៖** ៦០%នៃថវិកា (៤២លានដុល្លារសហរដ្ឋអាមេរិក) ត្រូវបានបែងចែកសម្រាប់ការកសាងសាលារៀនថ្មីនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល និងដើម្បីបំពេញបន្ថែមនៅសាលាដែលមានស្រាប់។ | សិស្សសាលា | កម្មវិធីនេះពិតជាមិនបានចាប់ផ្តើមរហូតដល់ឆ្នាំ២០០៩។ មូលនិធិដែលត្រូវបានចំណាយ គិតមកដល់ខែមីនា ឆ្នាំ២០១០ គឺមានតែ១០%នៃទឹកប្រាក់សរុបប៉ុណ្ណោះ។ ទោះបីជាយ៉ាងនោះក្តី ការបន្តរយៈពេលពីរឆ្នាំនៃកាលបរិច្ឆេទបិទត្រូវបានផ្តល់ រហូតដល់ខែមិថុនា ឆ្នាំ២០១២។ | ការអនុវត្តដោយជោគជ័យនៃ គម្រោង ESSSUAP នឹងមានសារៈសំខាន់ណាស់ ដោយសារតែកម្មវិធីនេះកំណត់គោលដៅច្បាស់លាស់ក្នុងការដាក់បញ្ចូល ក្រុមកុមារដែលងាយរងគ្រោះបំផុតទៅក្នុងប្រព័ន្ធអប់រំ។[៣៧] |
| | **CTB – BTC** (កិច្ចសហប្រតិបត្តិការបច្ចេកទេសប៊ែលហ្សិក)- **ការអប់រំកម្រិតមូលដ្ឋាន និងការបណ្តុះបណ្តាលគ្រូបង្រៀន ឆ្នាំ២០០៣-២០១១** គ្រោងនឹងធ្វើឲ្យការទទួលបានការអប់រំប្រសើរឡើងនៅក្នុងតំបន់គោលដៅនានានៅក្នុងខេត្តសៀមរាប ឧត្តរមានជ័យ និងកំពង់ចាម។ | សិស្សសាលា | បន្ទប់រៀនចំនួន៥២២ (គឺមាន១០៦អគារនៅ៨៥ទីតាំង) ត្រូវបានកសាងឡើងក្នុងដំណាក់កាលដំបូង នៃគម្រោង (ពីខែតុលា ២០០៣ ដល់ខែមិថុនា ឆ្នាំ២០០៧)។ ក្នុងអំឡុងដំណាក់កាលសម្របសម្រួល (ខែកក្កដា ២០០៧ដល់បច្ចុប្បន្ន) គេបានកសាងបន្ទប់រៀនចំនួន១១០ទៀត (២៦អគារ)។ | មិនមានរបាយការណ៍ស្តីពីផលប៉ះពាល់ណាមួយទៅលើគម្រោងនេះនោះទេ ប៉ុន្តែ គេសន្មតថា អគារសិក្សាថ្មីនឹងផ្តល់ឱកាសបង្កើនការចូលរៀន និងកាត់បន្ថយការបោះបង់ការសិក្សា។ |

[៣៧] *កម្មវិធីពង្រីកការអប់រំកម្រិតមូលដ្ឋាន (EBEP) ដំណាក់កាលទី២៖ របាយពិនិត្យឡើងវិញឆ្នាំ២០០៦-២០១០ សម្រាប់ឆ្នាំ២០០៩,* ខែសីហា ២០១០ អង្គការ SIDA/វិទ្យាស្ថានអន្តរជាតិសម្រាប់ផែនការអប់រំ/អង្គការយូណេស្កូ http://www.iiep.unesco.org/fileadmin/user_upload/News_And_Events/pdf/2010/SATReviewreport2009.pdf

| *ប្រធានបទគោលនយោបាយឬកម្មវិធី* | *ឯកសារ* | *ក្រុមគោលដៅ* | *ការបរិយាយ/សេចក្តីអត្ថាធិប្បាយ* | *របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា* |
|---|---|---|---|---|
| | **កម្មវិធីសិទ្ធិកុមារ**ដែលផ្តួចផ្តើមដោយអង្គការយូនីសេហ្វ កែលម្អអគារសិក្សា ដោយលើកកម្ពស់ទឹក និងអនាម័យបរិស្ថានតាមរយៈការកសាងអណ្តូង បន្ទប់សាលារៀន និងការសាកល្បងគុណភាពទឹក។ | សហគមន៍ និងសាលារៀន | ការកែលម្អទាំងនេះផ្តល់ប្រយោជន៍ដល់គ្រួសារជាង ៥,០០០ និងកុមារបឋមសិក្សាចំនួន១០,០០០នាក់។[៣៨] | |
| ២៣. សន្តេវាសិកដ្ឋាន/កន្លែងស្នាក់នៅសម្រាប់សិស្ស | **ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៩-២០១៣** មានគំនិតផ្តួចផ្តើមពីរដ្ឋាភិបាលសម្រាប់កិច្ចសហប្រតិបត្តិការជាមួយក្រសួង០៤ (ក្រសួងអប់រំ ក្រសួងយុត្តិធម៌ ក្រសួងកិច្ចការនារី និងក្រសួងវប្បធម៌) ក្នុងការផ្តល់កន្លែងស្នាក់នៅសម្រាប់កុមារី ដើម្បីបញ្ចប់ការអប់រំកម្រិតមូលដ្ឋានយ៉ាងហោចឲ្យបានត្រឹមថ្នាក់ទី៩។ | កុមារីក្រីក្រថ្នាក់ទី១-៩ | កម្មវិធីរដ្ឋាភិបាលបានកសាងអន្តេវាសិកដ្ឋាននៅវិទ្យាល័យទីរួមខេត្តចំនួន០៥នៅខេត្តសៀមរាប កំពង់ធំ កំពង់ឈើទាល(ខេត្តកំពង់ធំ) រតនគិរី និងមណ្ឌលគិរី។ កុមារី៥០%នៅក្នុងសាលាទាំងនេះមកពីជនជាតិភាគតិច។<br><br>លេខាធិការដ្ឋានយេនឌ័របានអនុវត្តក្រុមប្រឹក្សាអប់រំសម្រាប់កុមារីនៅក្នុងសាលានីមួយៗ | |

[៣៨] http://ochaonline.un.org/TrustFund/ProjectProfiles/SethKomaChildrightsinCambodia/tabid/2119/language/en-US/Default.aspx (កម្មវិធីសិទ្ធិកុមារ)។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្ដីអត្ថាធិប្បាយ | របាយការណ៍ស្ដីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | | | ដើម្បីរក្សាភាពសុខដុមរមនាឲ្យប្រសើរនៅក្នុងអន្តេវាសិកដ្ឋាន។[៣៩] | |
| **ការជ្រើសរើស ការបណ្ដុះបណ្ដាល និងឥរិយាបថគ្រូបង្រៀននៅក្នុងបន្ទប់រៀន** | | | | |
| ២៤. ការជ្រើសរើសគ្រូបង្រៀន | **ផែនការមេអភិវឌ្ឍគ្រូបង្រៀន(TDMP)របស់ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០១០-២០១៤** ២០១០[៤០] មានបំណងទប់ស្កាត់កុមារីមិនឲ្យបោះបង់សាលា ដោយឲ្យអ្នកគ្រូមកបង្រៀន (ដែលអាចធ្វើជាអ្នកប្រឹក្សាយោបល់សម្រាប់កុមារី)។ | គ្រូបឋម និងមធ្យមសិក្សា | • ចាប់តាំងពីឆ្នាំ២០០៥ បេក្ខជនផ្នែកបណ្ដុះបណ្ដាលគ្រូបង្រៀនត្រូវតែបានបញ្ចប់ការសិក្សាយ៉ាងហោចថ្នាក់ទី១២។ ទោះជាយ៉ាងនោះក្ដី TDMP យុទ្ធសាស្ត្រ ១.២/៤.១ លើកទឹកចិត្តបេក្ខនារីជាគ្រូបង្រៀន នៅតំបន់ជនបទដាច់ស្រយាលដែលបានបញ្ចប់ការសិក្សាថ្នាក់ទី៩។ ដូច្នេះ បេក្ខជនដែលទទួលបានជោគជ័យប្រហែល៦០%គឺភេទស្រី<br><br>ក្រសួងអប់រំក៏នឹងផ្ដល់ប្រាក់ឧបត្ថម្ភដល់គ្រូបង្រៀនដែលរស់នៅតំបន់ដាច់ស្រយាល | គេរំពឹងថា ការអនុវត្តនេះនឹងជួយកាត់បន្ថយកុមារីបោះបង់ការសិក្សា។ |

[៣៩] បទសម្ភាសន៍ជាមួយលោកជំទាវ ញឹម វ៉ាន់ចាន់កន ប្រធានលេខាធិការដ្ឋានយេនឌ័រ និងអប់រំកុមារី និងអគារធិការរង នៃក្រសួងអប់រំ ថ្ងៃទី០៩ កុម្ភៈ ២០១១។

[៤០] គោលនយោបាយរបស់ក្រសួងអប់រំស្ដីពី "ផែនការមេអភិវឌ្ឍន៍គ្រូបង្រៀន ឆ្នាំ២០១០-២០១៤" ថ្ងៃទី១៦ សីហា ២០១០។

| *ប្រធានបទគោលនយោបាយឬកម្មវិធី* | *ឯកសារ* | *ក្រុមគោលដៅ* | *ការបរិយាយ/សេចក្ដីអត្ថាធិប្បាយ* | *របាយការណ៍ស្ដីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា* |
|---|---|---|---|---|
| | | | និងតំបន់ងាយរងគ្រោះ។ | |
| | **អង្គការអប់រំពិភពលោក/អង្គការ ខេប– គម្រោង IBEC** មានបំណងកាត់បន្ថយកង្វះគ្រូបង្រៀន ដោយជ្រើសរើសសិក្ខាកាមពីតំបន់ដាច់ស្រយាល និងផ្ដល់អាហារូបករណ៍ដល់ពួកគាត់។ | គ្រូបង្រៀនល្អៗមកពីតំបន់ដាច់ស្រយាល | បុគ្គល១២០នាក់មកពីតំបន់ដាច់ស្រយាល និងតំបន់ដែលអាទិភាពខ្ពស់ បានទទួលអាហារូបករណ៍នៅឆ្នាំ២០០៩/១០។ | ដោយសារតែការអភិវឌ្ឍគ្រូបង្រៀនសហគមន៍ទំនងជាបានកាត់បន្ថយចំនួនសិស្សណែនណាន់តាន់តាប់ បានជាយើងអាចរក្សាផលធៀបសិស្ស-គ្រូឲ្យនៅកម្រិតមួយដែលអាចគ្រប់គ្រងបាន និងបានជួយកាត់បន្ថយអត្រាត្រួតថ្នាក់[៤១] គេរំពឹងថាគម្រោង IBEC នឹងអនុវត្តដូចគ្នា។ |
| | **អង្គការខេប - គម្រោងសរសេរឡើងវិញពីអនាគត** បានដោះស្រាយកង្វះខាតគ្រូបង្រៀន ដោយជ្រើសរើសសិក្ខាកាមមកពីតំបន់ដាច់ស្រយាល ដែលរៀនបានថ្នាក់ទី៩ ជាជាងទី១២។ | សិស្សថ្នាក់ទី៩មកពីតំបន់ដាច់ស្រយាល | គម្រោងនេះជ្រើសរើសសិស្សថ្នាក់ទី៩ និងគ្រូបង្រៀនសហគមន៍ក្លាយជាគ្រូរដ្ឋ ដោយផ្ដល់ការបណ្ដុះបណ្ដាលដល់ពួកគាត់ មុនពេលដែលពួកគាត់ប្រឡងចូលធ្វើគ្រូបង្រៀន។ | កម្មវិធីនេះកំពុងបន្ត ហើយវាបានកំណត់នូវកម្រិតទាបនៃជំនាញរបស់សិក្ខាកាមម្នាក់ៗ។[៤២] |
| | **អង្គការ ខេប -កម្មវិធី MORE** | សិក្ខាកាម | សិក្ខាកាមសិស្សជនជាតិចាមភេទស្រីពីរនាក់ | មិនទាន់បានវាស់វែង។[៤៣] |

[៤១] អង្គការអប់រំពិភពលោក របាយការណ៍ប្រចាំឆ្នាំរបស់គម្រោង IBEC ខែតុលា ឆ្នាំ២០១០។

[៤២] របាយការណ៍របស់គម្រោងសរសេរឡើងវិញពីអនាគត, អង្គការ ខេប ឆ្នាំ២០០៩-១០។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | មានគោលដៅបង្កើនចំនួនគ្រូជនជាតិចាមនៅក្នុងតំបន់ជនជាតិ។ | គ្រូបង្រៀនមកពីសហគមន៍ចាម | ទទួលបានការឧបត្ថម្ភក្នុងការសិក្សានៅក្នុងសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ចាប់តាំងពីខែធ្នូ ឆ្នាំ២០០៩។ សិស្សទាំងពីរនេះបានបញ្ចប់ការសិក្សាឆ្នាំទី១ដោយជោគជ័យ និងបានចុះឈ្មោះចូលរៀននៅឆ្នាំទី២ទៀត។ បេក្ខជនបីនាក់បន្ថែមទៀត(ស្រីម្នាក់) បានប្រឡងជាប់នៅសាលាគរុកោសល្យ និងវិក្រឹតការខេត្ត នៅឆ្នាំ២០១០-១១។ | |
| ២៥. ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន | **ច្បាប់អប់រំ ឆ្នាំ២០០៧ មាត្រា២០ ការបណ្តុះបណ្តាលបុគ្គលិកអប់រំ៖** រដ្ឋត្រូវបណ្តុះបណ្តាលបុគ្គលិកអប់រំ មុនពេល និង/ឬក្នុងពេលបម្រើការងារ... ក្រសួងទទួលបន្ទុកផ្នែកអប់រំត្រូវកំណត់ កម្មវិធីមូលដ្ឋានសម្រាប់បណ្តុះបណ្តាលបុគ្គលិក អប់រំ... និង<br>**មាត្រា២១៖** | គ្រូបឋម និងមធ្យមសិក្សា | **ការបណ្តុះបណ្តាលមុនចូលបម្រើការងារ៖** រួមមាន ការបណ្តុះបណ្តាលមុខវិជ្ជាសំខាន់ៗសម្រាប់បង្រៀន ក៏ដូចជាវិធីសាស្ត្រ ចំណេះដឹងទូទៅ និងការបណ្តុះបណ្តាលផ្សេងទៀត រួមមាន សិទ្ធិកុមារ សិទ្ធិស្ត្រី និងវប្បធម៌។<br><br>**ការបណ្តុះបណ្តាលគ្រូបឋមសិក្សា៖** | |

[៩៣] របាយការណ៍ប្រចាំឆ្នាំរបស់គម្រោង MORE, ឆ្នាំទី២នៃការអនុវត្ត, អង្គការ ខេប, ខែមករា ២០១១។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | **គុណភាព និងប្រសិទ្ធភាពនៃការអប់រំ៖** រដ្ឋត្រូវលើកកម្ពស់គុណភាពនៃការអប់រំ... យកចិត្តទុកដាក់ក្នុងផ្តល់នូវបច្ចេកទេសសមស្រប និងទំនើបក្នុងការបង្រៀន និងរៀនសូត្រ ដើម្បីធានាឲ្យបាននូវគុណភាព និងប្រសិទ្ធភាព។ បទដ្ឋានជាតិអប់រំ បទដ្ឋានជាតិបណ្តុះបណ្តាល និង/ឬបទដ្ឋានសមត្ថភាពជាតិនឹងត្រូវបានកំណត់ដោយក្រសួងទទួលបន្ទុកផ្នែកអប់រំស្របតាមគោលនយោបាយរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ។ | | ដោយសារតែកង្វះគ្រូបង្រៀននៅតំបន់ដាច់ស្រយាល ក្រសួងអប់រំសិស្សរៀនចប់ថ្នាក់ទី៩ ចុះឈ្មោះធ្វើគ្រូបឋម នៅសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ជាផ្នែកមួយនៃយុទ្ធសាស្ត្រ៩+២។<br><br>**ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាបឋមភូមិ**<br>o ភាពដែលអាចចូលរួមបាន៖ សញ្ញាបត្រមធ្យមសិក្សាទូទៅ និងការបណ្តុះបណ្តាលមុនចូលបម្រើការងារពីរឆ្នាំនៅឯសាលាគរុកោសល្យមួយក្នុងចំណោមសាលាគរុកោសល្យភូមិភាគចំនួន០៦ រួមមាន រាជធានីភ្នំពេញ ខេត្តបាត់ដំបង ព្រៃវែង តាកែវ កំពង់ចាម និងខេត្តកណ្តាល...<br>o ការបណ្តុះបណ្តាល៖ ការបណ្តុះបណ្តាលអនុវត្តរយៈពេល១៤សប្តាហ៍ (០៦សប្តាហ៍នៅឆ្នាំទី១ និង០៨សប្តាហ៍នៅឆ្នាំទី២) | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | | | o ការបញ្ចប់ការសិក្សា៖ សិស្សបញ្ចប់ការសិក្សានឹងទទួលបានសញ្ញាបត្របណ្តុះបណ្តាលគរុកោសល្យ ដោយឲ្យពួកគាត់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការធ្វើជាគ្រូមធ្យមសិក្សាបឋមភូមិ។<br>**ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ**<br>o ភាពអាចចូលរួមបាន៖ សញ្ញាបត្របរិញ្ញាបត្របន្ទាប់ពីទទួលការបណ្តុះបណ្តាលមុនចូលបម្រើការងារ១ឆ្នាំនៅវិទ្យាស្ថានជាតិអប់រំ (អតីត: សាលាគរុកោសល្យ)<br>o ការបណ្តុះបណ្តាល៖ ការបណ្តុះបណ្តាលអនុវត្តរយៈពេល០៤សប្តាហ៍ត្រូវបានតម្រូវសម្រាប់សិស្សគ្រប់រូប<br>o ការបញ្ចប់ការសិក្សា៖ សិស្សបញ្ចប់ការសិក្សាត្រូវបានប្រគល់សញ្ញាបត្របណ្តុះបណ្តាលគរុកោសល្យ។ បន្ទាប់មក ពួកគេក្លាយជានិយោជិតរបស់រដ្ឋ និងត្រូវចូលបង្រៀននៅ | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | | | តាមសាលាទូទាំងប្រទេស។ សញ្ញាបត្រនោះចេញដោយក្រសួងអប់រំ ហើយនៅពេលទទួល សញ្ញាបត្រនេះមានសុពលភាពអស់មួយជីវិត។<br>**ការបណ្តុះបណ្តាលក្នុងពេលបម្រើការងារ៖** មជ្ឈមណ្ឌលគរុកោសល្យ និងវិក្រឹតការភូមិភាគតែមួយដូចបានរៀបរាប់ខាងលើនេះ ក៏បានផ្តល់នូវ ការបណ្តុះបណ្តាលក្នុងពេលបម្រើការងារដល់គ្រូមធ្យមសិក្សាបឋមភូមិ។ ស្រដៀងគ្នានេះដែរ វិទ្យាស្ថានជាតិអប់រំផ្តដល់ការបណ្តុះបណ្តាលក្នុងពេល បម្រើការងារសម្រាប់គ្រូមធ្យមសិក្សាទុតិយភូមិ។ទោះបីជាការចូលរួមទៀងទាត់នៅក្នុងការបណ្តុះបណ្តាលនេះមិនត្រូវបានតម្រូវសម្រាប់គ្រូដែលចូលបម្រើការងារក៏ដោយ ក៏ការចូលរួមនេះត្រូវ បានគេយកមកពិចារណាសម្រាប់ការអភិវឌ្ឍអាជីពរបស់គ្រូបង្រៀន ដូចជា ការតម្លើងឋានៈ និងប្រាក់បៀវត្សរ៍។ ការបណ្តុះបណ្តាល | |

| *ប្រធានបទគោលនយោបាយឬកម្មវិធី* | *ឯកសារ* | *ក្រុមគោលដៅ* | *ការបរិយាយ/សេចក្តីអត្ថាធិប្បាយ* | *របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា* |
|---|---|---|---|---|
| | | | ក្នុងពេលបម្រើការងារត្រូវធ្វើឡើង ក្នុងអំឡុងពេលវិស្សមកាល និងផ្តោតទៅលើវិធីសាស្ត្រ និងបច្ចេកទេស។ | |
| ២៦. ក្រមសីលធម៌គ្រូបង្រៀន | **រាជរដ្ឋាភិបាលកម្ពុជា *អនុក្រឹត្យ* លេខ ១២៦ អនក្រ/បក ឆ្នាំ២០០៨ ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន** ធ្វើការកែលម្អសីលធម៌ សេចក្តីថ្លៃថ្នូរ និងគុណភាពនៃការបង្រៀនសម្រាប់គ្រូគ្រប់រូបនៅកម្ពុជា។ | បុគ្គលិកសាលារៀន | ០៦ជំពូក និង៣០មាត្រាកំណត់នូវភារកិច្ចទទួលខុសត្រូវលើការអប់រំរបស់គ្រូបង្រៀន តួនាទីនិងការទទួលខុសត្រូវរបស់ឪពុកម្តាយ និងសិស្ស ទំនាក់ទំនងរវាង គ្រូបង្រៀន និងសិស្ស ការងារវិជ្ជាជីវៈរបស់គ្រូបង្រៀន និងការដាក់ទណ្ឌកម្មក្នុងករណីមានការរំលោភបំពាន/ទណ្ឌកម្មរាងកាយលើសិស្ស។ | ក្រមសីលធម៌គ្រូបង្រៀនត្រូវបានចាត់ទុកថា ជាឧបករណ៍មួយដើម្បីកាត់បន្ថយសិស្សបោះបង់ការសិក្សា។ ផ្អែកលើក្រមសីលធម៌នេះ គ្រូបង្រៀនអនុវត្តតាមគោលវិធីដ៏រឹងមាំដើម្បីជំរុញឲ្យសិស្សមករៀន ហើយសិស្សមួយចំនួនដែលខ្លាចគ្រូ បានបោះបង់ការសិក្សា។[៤៤] |
| ២៧. ការទប់ស្កាត់អំពើសម្លុត/បៀតបៀន | **គោលនយោបាយរបស់អង្គការយូណេស្កូស្តីពីការអប់រំបញ្ចូលគ្នា – គំនិតផ្តួចផ្តើមរបស់ Epic Arts/VSO/MoEYS ឆ្នាំ២០១០:** គំនិតផ្តួចផ្តើមគាំទ្រ គោលដៅក្នុងការផ្តល់វិធីសាស្ត្រដល់គ្រូ | | សាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពត មានសិក្ខាកាម២០០នាក់នៅក្នុងកម្មវិធីគ្រូបឋមរយៈពេលពីរឆ្នាំ ដែលនឹងធ្វើការនៅក្នុងស្រុកជនបទ។ ក្នុងចំណោមសកម្មភាពផ្សេងទៀត ពួកគេពិភាក្សា | |

[៤៤] បទសម្ភាសន៍ជាមួយលោក អ៊ុង ង៉ូហុក ប្រធាននាយកដ្ឋានមធ្យមសិក្សា, ថ្ងៃទី១០ កុម្ភៈ ២០១១ ការិយាល័យក្រសួងអប់រំ ភ្នំពេញ។

| ប្រធានបទ គោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
| --- | --- | --- | --- | --- |
| | បង្រៀន អំពីការដាក់បញ្ចូលសិស្សទាំងអស់នៅក្នុងបន្ទប់រៀន។ គោលបំណងមួយក្នុងចំណោមទាំងនេះ គឺដើម្បីលើកទឹកចិត្តឲ្យសិក្ខាកាមមានការទទួល ខុសត្រូវក្នុងការទប់ស្កាត់អំពើសម្លុតសិស្ស ដោយសារពិការភាព ឬខុសប្លែកពីគេឯង។ | | អំពីការទប់ស្កាត់អំពើសម្លុត។ | |
| ២៨.ទណ្ឌកម្មរាងកាយ | **សារាចរណែនាំរបស់ក្រសួងអប់រំលេខ ១២៥៨ អយក/ប្រក ឆ្នាំ២០០៩ មាត្រា១១ សេចក្តីថ្លែងការណ៍អំពីទណ្ឌកម្ម៖** ទណ្ឌកម្មរាងកាយទាំងផ្លូវកាយ និងផ្លូវចិត្ត ឬអំពើហិង្សាលើកុមារត្រូវបាន ហាមឃាត់នៅស្ថាប័នសិក្សា។ ក្នុងករណីដែល សិស្សណាមួយមានឥរិយាបថមិនល្អ ឬមិនគោរពវិន័យសាលា នាយកសាលាត្រូវអនុវត្តចំពោះគណៈកម្មាធិការក្រុមប្រឹក្សាសាលាដើម្បី ណែនាំអំពីរបៀបដោះស្រាយកំហុសឆ្គងរបស់សិស្ស។ | នាយកសាលា មន្ត្រីអប់រំ គ្រូបង្រៀន | នៅក្នុងការអនុវត្តជាក់ស្តែង ទណ្ឌកម្មរាងកាយនៅតែកើតមាននៅសាលារៀននានា ទោះបីជាមិនត្រូវបានគេរាយការណ៍ក៏ដោយ។ កុមារលើកឡើងពីទណ្ឌកម្មរាងកាយ នៅពេលដែលខ្លួនធ្វើខុស។ ក្រុមអប់រំរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សាមិនបានដឹង អំពីទណ្ឌកម្មផ្លូវការ ឬសកម្មភាពប្រឆាំងនឹងគ្រូបង្រៀន ដែលប្រើទណ្ឌកម្មរាងកាយ។ | |
| ២៩.សាលា | **គោលនយោបាយសាលាកុមារមេត្រីរបស់ក្រសួង** | សិស្ស | សាលាកុមារមេត្រីទទួលស្គាល់ និងយកចិត្តទុក | យុទ្ធសាស្ត្រសាលាកុមារមេត្រីមាន |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្ដីអត្ថាធិប្បាយ | របាយការណ៍ស្ដីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| កុមារមេត្រី | **អប់រំ ឆ្នាំ២០០៧**<br>មានទិសដៅជាច្រើន៖<br>• ការអនុវត្តសិទ្ធិកុមារដោយមានការទទួលស្គាល់ជាសាកល។<br>• ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំកម្រិតមូលដ្ឋាន។<br>• ការអនុវត្តដោយជោគជ័យនូវប្រព័ន្ធវិមជ្ឈការ<br>• ការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ចំណុចដៅនៃផែនការជាតិដើម្បីការអប់រំ សម្រាប់ទាំងអស់គ្នា និងទិសដៅនៃផែនការ វិស័យអប់រំសម្រាប់ការអប់រំជាតិ។ | បឋមនិងមធ្យមសិក្សា | ដាក់ចំពោះសមិទ្ធិផលនៃសិទ្ធិមូលដ្ឋានរបស់កុមារធ្វើការជាមួយអ្នកប្ដេជ្ញាចិត្តគ្រប់រូប, ជាពិសេសឪពុកម្ដាយ/អាណាព្យាបាលសិស្ស និងវាយតម្លៃវិភាគទានច្រើនប្រភេទ ដែលអាចធ្វើដើម្បី៖<br>(ក)ធានាថា កុមារគ្រប់រូបទៅសាលារៀន និង<br>(ខ) អភិវឌ្ឍបរិស្ថានរៀនសូត្រប្រកបដោយប្រសិទ្ធភាពសម្រាប់កុមារ។<br>បរិស្ថានរៀនសូត្រទាំងនេះត្រូវបានចាត់ថ្នាក់ដោយសមធម៌ គុណភាព សេរីភាព សាមគ្គីភាព អហិង្សា និងក្ដីកង្វល់អំពីសុខភាពផ្លូវកាយ ផ្លូវចិត្ត និងផ្លូវអារម្មណ៍។<br>លក្ខណៈសម្គាល់សាលារៀនរួមចំណែកក្នុងការអភិវឌ្ឍចំណេះដឹង ជំនាញ ឥរិយាបថ តម្លៃ និងសីលធម៌របស់កុមារ ដើម្បីឲ្យពួកគេអាចរស់នៅជាមួយគ្នាក្នុងភាពសុខដុមរមនា។ សាលាកុមារមេត្រីយកចិត្តទុកដាក់ចំពោះកុមារនៅសាលាមេត្រីគាំទ្រដល់ការអភិវឌ្ឍកុមារ និងសហគមន៍ | ចំនួនដល់ទៅ៥០%នៃសាលារដ្ឋ។ |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | | | សាលាមេត្រី។ | |
| | **អង្គការមិនមែនរដ្ឋាភិបាលដែលអនុវត្តកម្មវិធីសាលាកុមារមេត្រី៖**<br>បឋមសិក្សា៖<br>• អង្គការអូស្ត្រាលីសង្គ្រោះកុមារ<br>• អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា "ខេប"<br>• អង្គការ ឃែរ អន្តរជាតិនៅកម្ពុជា<br>• អង្គការពុទ្ធិកុមារ<br>• អង្គការទស្សនៈពិភពលោក នៅកម្ពុជា<br>• អង្គការសេវាស្ម័គ្រចិត្តនៅក្រៅប្រទេស<br><br>មធ្យមសិក្សា<br>• អង្គការភ្លែន អន្តរជាតិ<br>• អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា "ខេប"<br>• អង្គការ ឃែរ អន្តរជាតិនៅកម្ពុជា | សិស្ស<br>សាលា | កម្មវិធីសាលាកុមារមេត្រីមានវិសាលភាពដូចខាងក្រោម៖<br>១: ការអប់រំបញ្ចូលគ្នា<br>២: បរិស្ថានរៀនសូត្រផ្នែកចិត្តសាស្ត្រ<br>៣: សុខភាព អាហារូបត្ថម្ភ និងសុវត្ថិភាព<br>៤: បរិស្ថានរៀនសូត្ររំញោចយេនឌ័រ<br>៥: ការចូលរួមពីសហគមន៍ និងឪពុកម្តាយ<br>៦: បរិស្ថានសាលារៀនអំណោយផល(អភិបាលកិច្ចសាលា) | ដើម្បីស្វែងរកផលប៉ះពាល់នៃ គោលវិធីសាលាកុមារមេត្រី ការវិភាគប្រៀបធៀបរបស់អង្គការ យូនីសេហ្វ បានគាំទ្រដល់សាលាកុមារមេត្រី ធៀបនឹងសាលាមិនមែនកុមារមេត្រី។ ជាអកុសល ការស្រាវជ្រាវនេះមិនត្រូវបានបញ្ចប់ភ្លាមៗនោះទេ ហើយការស្រាវជ្រាវ ទាក់ទងនឹង គម្រោងការធ្វើគំរូតាង និងវិធី សាស្ត្រប្រមូលទិន្នន័យ។ ការសិក្សានេះពិតជាមិនបានវាស់វែង ផលប៉ះពាល់នៃការអនុវត្តសាលាកុមារមេត្រីនោះទេចំពោះផលប៉ះពាល់លើសូចនាករលទ្ធផលសំខាន់ៗមួយចំនួន (ដូចជា ចំនួនភាគរយនៃកុមារអាយុ០៦ឆ្នាំនៅថ្នាក់ទី១ អត្រាត្រួតថ្នាក់ និងអត្រាបោះបង់ |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | • អង្គការសេវាស្ម័គ្រចិត្តនៅក្រៅប្រទេស | | | សមិទ្ធិផលសិក្សា) ប៉ុន្តែ ការផ្លាស់ប្តូរខ្លះៗ ដែលបានកើត ឡើងនៅក្នុងបរិយាកាសសាលារៀន និងការអនុវត្តនៅសាលាមួយចំនួន។ ទោះបីជាមានការកំណត់យ៉ាងណាក៏ដោយ ក៏របាយការណ៍នេះផ្តល់នូវព័ត៌មានដ៏គួរឲ្យចាប់អារម្មណ៍ និងបង្ហាញថា ការផ្លាស់ប្តូរជាវិជ្ជមានមួយចំនួននឹងត្រូវធ្វើឡើងនៅសាលា កុមារមេត្រីៈ កែលម្អបរិស្ថាន សាលារៀន (ការស្វាគមន៍ចំពោះ កុមារពិការ ការមានធុងចម្រោះទឹក ការប្រើប្រាស់ផែនទីគ្រួសារឲ្យបានជាប់លាប់ជាងនេះ), វិញ្ញោចយេនឌ័រ (ឧ.ការបែងចែកកន្លែងបន្ទោបង់ដាច់ដោយឡែកសម្រាប់កុមារី តំណាងស្មើគ្នា សម្រាប់កុមារីនៅក្នុងក្លឹបសិស្ស) ផ្តោតការយក |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | | | | ចិត្តទុកដាក់ខ្លាំងទៅលើការអនុវត្តបង្រៀន/រៀនសូត្រ (ប៉ុន្តែត្រូវកាត់បន្ថយអវត្តមានគ្រូបង្រៀន) ការចូលរួមប្រសើរឡើងពីកុមារ ឪពុកម្តាយ និងសហគមន៍នៅក្នុងសាលារៀន។[៤៥] |
| ៣០.ភាសាអប់រំ | **ច្បាប់អប់រំឆ្នាំ២០០៧ មាត្រា២៤ ភាសាបង្រៀន និងភាសារៀនសូត្រៈ**<br>ភាសាខ្មែរគឺជាភាសាផ្លូវការមួយ និងជាមុខវិជ្ជាមូលដ្ឋាននៃកម្មវិធីសិក្សានៅសាលារដ្ឋដែលផ្តល់នូវការអប់រំទូទៅ។<br>ភាសាសម្រាប់អ្នករៀនភាសាខ្មែរមកពីក្រុមជនជាតិភាគតិចត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងទទួលបន្ទុកផ្នែកអប់រំ។ | សាលារដ្ឋ | | អ្នករៀនសូត្រដែលមិនចេះភាសាខ្មែរជាភាសាទីមួយ សិស្សប្រឈមនឹងការបោះបង់ការសិក្សានិងមិនមកសាលារៀន ប្រសិនបើរដ្ឋាភិបាលមិនចាត់បទបញ្ជាការគាំទ្រឲ្យមានការអប់រំពីរភាសាទេនោះ។ |
| | **ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-១៣,** | កុមារអាយុ | | មិនទាន់បានវាស់វែង។ |

[៤៥] *កម្មវិធីពង្រីកការអប់រំកម្រិតមូលដ្ឋាន (EBEP) ដំណាក់កាលទី២៖ របាយពិនិត្យឡើងវិញឆ្នាំ២០០៦-២០១០ សម្រាប់ឆ្នាំ២០០៩,* ខែសីហា ២០១០ អង្គការ SIDA/វិទ្យាស្ថានអន្តរជាតិសម្រាប់ផែនការអប់រំ/អង្គការយូណេស្កូ, http://www.iiep.unesco.org/fileadmin/user_upload/News_And_Events/pdf/2010/SATReviewreport2009.pdf

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | **គោល នយោបាយទី១៖** ធានាថាកុមារអាយុ០៦ឆ្នាំគ្រប់រូបបានចូលរៀននៅសាលាបឋមសិក្សា រួមមានក្រុមងាយរងគ្រោះ ដូចជា កុមារពិការ ជនជាតិភាគតិច ។ល។ និង **សកម្មភាពគោលនយោបាយ, ឆ្នាំ២០១០៖** នាយកដ្ឋានអប់រំបឋម បានបង្កើតសារាចរណែនាំស្តីពីការអនុវត្តការអប់រំពីរភាសាសម្រាប់ជនជាតិភាគតិច។ | ០៦ឆ្នាំ | | |
| | ដើម្បីលើកទឹកចិត្តឲ្យកុមារចូលរៀន និងបង្ហាញការគាំទ្រពីថ្នាក់ជាតិ **គោលនយោបាយអប់រំពិសេសស្តីពីការអប់រំពីរភាសាឆ្នាំ២០០៨, ការផ្តល់ការអប់រំស្មើគ្នាដល់កុមារជនជាតិដើមភាគតិច** (គោលនយោបាយដែលមិនមាននៅក្នុងកម្មវិធី | កុមារជនជាតិដើមភាគតិចនៅតំបន់ខ្ពង់រាប | សៀវភៅសិក្សា និងកម្មវិធីសិក្សានៅក្នុងភាសាជនជាតិទាំងអស់មិនទាន់បានបង្កើតនៅឡើយទេ ដូច្នេះ ការអនុវត្តកម្មវិធីអប់រំពីរភាសាមិនទាន់គ្រប់គ្រាន់ និងគ្រប់ជ្រុងជ្រោយនៅឡើយទេ។[៨៦] | |

[៨៦] បទសម្ភាសន៍ជាមួយលោក ញាន សារឿន ការិយាល័យអប់រំពិសេសនៃក្រសួងអប់រំ នាយកដ្ឋានបឋមសិក្សា ថ្ងៃទី១១ កុម្ភៈ ២០១១។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | សាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា) តម្រូវឲ្យមាន៖<br>• ការរៀបចំសាលាសហគមន៍ ដើម្បីអនុវត្តកម្មវិធីសិក្សាអប់រំពីរភាសា។<br>• ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូបង្រៀនអំពីកម្មវិធីអប់រំពីរភាសា។<br>• ការត្រួតពិនិត្យ និងតាមដាន។<br>• ការវាយតម្លៃ និង<br>• ការផ្សព្វផ្សាយព័ត៌មានស្តីពីកម្មវិធីអប់រំពីរភាសាឲ្យបានដល់ឪពុកម្តាយ សហគមន៍ នាយកដ្ឋាន និងក្រសួងពាក់ព័ន្ធ។ | | | |
| | **កម្មវិធីអប់រំពីរភាសារបស់ICC/CARE** មានបំណងជួយឲ្យប្រជាជនជនជាតិដើមភាគតិចចេះអាន និងសរសេរភាសាខ្មែរ បូកនឹងភាសា(ជនជាតិដើមភាគតិច)ផ្ទាល់របស់ពួកគេ។ | សហគមន៍ជនជាតិដើមភាគតិច | អង្គការ CARE បានបង្កើតសាលារៀនគ្រប់គ្រងដោយសហគមន៍ ដែលសិស្សអាចរៀនបានទាំងភាសាផ្ទាល់របស់ពួកគេ និងភាសាខ្មែរ។ ចាប់តាំងពីឆ្នាំ២០០២ គម្រោងអប់រំសហគមន៍ខ្ពង់រាបរបស់អង្គការ CARE បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការតស៊ូមតិដើម្បីឲ្យមានការអប់រំពីរ | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | | | ភាសានៅថ្នាក់ជាតិសម្រាប់កុមារជនជាតិភាគតិច។ គម្រោងអប់រំសហគមន៍ខ្ពង់រាបមានអង្គភាពផលិតកម្មធនធានផ្ទាល់ខ្លួន និងបានសរសេរ និងចងក្រងសៀវភៅសិក្សាពីរភាសាជាង២៥ក្បាល។ | |
| ៣១. កម្មវិធីសិក្សា | **ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៩-១៣។ សកម្មភាពគោលនយោបាយ ឆ្នាំ២០១០៖** នាយកដ្ឋានអប់រំបឋមបានបង្កើតសាវាចរណែនាំស្តីពីការអនុវត្តនូវការបង្កើនការរៀនសូត្រសម្រាប់ក្រុមពិសេស។ | ថ្នាក់បឋមសិក្សា | | មិនទាន់បានវាស់វែង។ |
| ៣២. ការអប់រំវិជ្ជាជីវៈ ឬកម្មវិធីសាលារៀនធ្វើការ | **ច្បាប់អប់រំឆ្នាំ២០០៧ មាត្រា១៩ ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ៖** ការអប់រំ និង បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រួមបញ្ចូលនូវរាល់វិជ្ជាជីវៈ និងជំនាញ ដែលត្រូវបានផ្តល់ដោយស្ថាប័នអប់រំ និង បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរដ្ឋ និងឯកជន សហគ្រាស សហគមន៍ គ្រួសារ ឬក្នុងកិច្ចសហ | ស្ថាប័នរដ្ឋ និងឯកជន | ការអប់រំក្រៅប្រព័ន្ធគឺជាកម្មវិធីអាទិភាពមួយក្នុងចំណោមកម្មវិធីអាទិភាពនានារបស់ក្រសួងអប់រំ ក្នុងការលើកស្ទួយជំនាញអាន សរសេរ និងជំនាញវិជ្ជាជីវៈ ឲ្យបានដល់មនុស្សពេញវ័យ និងកុមារហួសអាយុចូលរៀន។ យោងតាមរបាយការណ៍ឧបសម្ព័ន្ធស្តីពីការអភិវឌ្ឍធនធានមនុស្ស របស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជា | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | ប្រតិបត្តិការរវាងស្ថាប័នអប់រំ និង បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងសហគ្រាស និង/ឬសហគមន៍ និងគ្រួសារនានា។ | | ជាតិ (UNDP) បានឲ្យដឹងថា អត្រាអក្ខរកម្មសម្រាប់មនុស្សពេញវ័យក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាដែលមានអាយុ១៥ឆ្នាំឡើងទៅ មានចំនួន៧៦.៣% ក្នុងឆ្នាំ២០០៧ ដែលបង្ហាញពីតម្រូវការ កម្មវិធីទាំងនេះ។ | |
| | អង្គការមិនមែនរដ្ឋាភិបាលភាគច្រើនផ្តល់កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ រួមមានអង្គការអប់រំពិភពលោក CARE, KAPE, KNKS, KPF, MJP, MVI, RDA, SK, PIO, MODE, ICC, PVT, CIDC, DTP, FESIP, NLF, CCBO, Don Bosco, Damnok, Toek Prey Veng, FDCC, Wattanakpheap, WFC, SCD, WI, L.CDI, WDA, និងអង្គការ Hagar. | | អង្គការមិនមែនរដ្ឋាភិបាលយ៉ាងតិច៤៣បានអនុវត្តសកម្មភាពកម្មវិធីនៅក្នុងការអប់រំក្រៅប្រព័ន្ធ។ អង្គការទាំងនេះកំពុងអនុវត្តសកម្មភាពផ្សេងៗ ក្នុងគោលបំណងដើម្បីកសាងសមត្ថភាពរបស់ក្រុមក្រីក្រ និងក្រុមងាយរងគ្រោះ ក្នុងការលើកកម្ពស់ស្ថានភាពរស់នៅរបស់ពួកគេ។ ភាគច្រើនក្នុងចំណោម អង្គការមិនមែនរដ្ឋាភិបាលទាំងនេះផ្តល់ការ បណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញកុំព្យូទ័រ ដើម្បីឲ្យប្រាកដថា ក្រុមគោលដៅរបស់ពួកគេរៀនបានជំនាញច្បាស់លាស់ ដែល | មិនមានព័ត៌មានណាមួយបង្ហាញថា កម្មវិធីអប់រំក្រៅប្រព័ន្ធទាំងនេះ មានឥទ្ធិពលយ៉ាងណាទៅលើ ស្ថានភាពរស់នៅនៃអ្នកទទួលផលរបស់ខ្លួន។ ប៉ុន្តែ ផ្នែករីក ចម្រើនសំខាន់ពីរត្រូវបានកំណត់ ដោយអង្គការមិនមែនរដ្ឋាភិបាល៖ ១)អ្នកចូលរួមអក្ខរកម្មសម្រាប់មនុស្សពេញវ័យបានកែលម្អជំនាញអាន និងសរសេរ និង២)សិស្សអក្ខរកម្មក្មេងៗ |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | | | នឹងជួយឲ្យពួកគេមានជម្រើសប្រកបរបរចិញ្ចឹមជីវិតប្រសើរឡើង។ អង្គការមិនមែនរដ្ឋាភិបាលចំនួន១៦បានអនុវត្តថ្នាក់អក្ខរកម្ម ដើម្បីកែលម្អជំនាញអាន និងសរសេរ សម្រាប់មនុស្សពេញវ័យ និងកុមារហួសអាយុចូលរៀន។ | ត្រូវបានដាក់បញ្ចូលជាថ្មីទៅក្នុងសាលារដ្ឋ។[៤៧] |
| **សេវាទ្រទ្រង់សាលារៀន** | | | | |
| ៣៣. ការបង្រៀនគួរបំប៉នបន្ថែម/មុខវិជ្ជាទាក់ទង | អង្គការមិនមែនរដ្ឋាភិបាលជាច្រើន រួមមាន អង្គការខេប អង្គការណ៍រ៉េសង្គ្រោះកុមារ មូលនិធិកុមារពិការ អង្គការកម្ពុជាមានចីរភាព និងអង្គការ ពុទ្ធិកុមារ បានផ្តល់**កម្មវិធីបំប៉នបន្ថែម**។ SC ក៏បានផ្តល់មុខវិជ្ជាសំខាន់ៗ ដូចគ្នា គណិតវិទ្យា ភាសាខ្មែរ និងអង់គ្លេស)។ | សិស្សបឋមនិងអនុវិទ្យាល័យ | ឧទាហរណ៍ កម្មវិធីបំប៉នបន្ថែមរបស់អង្គការ ខេប សម្រាប់កុមារដែលមានតម្រូវការរៀនសូត្រពិសេស ដែលឧបត្ថម្ភដល់ក្រុមរៀនសូត្រតាមភូមិ សម្រាប់កុមារដែលប្រឈមនឹងការប្រឡងធ្លាក់ និងបោះបង់ការសិក្សា។ | |
| | **ផែនការយុទ្ធសាស្ត្រវិស័យអប់រំរួមមានកម្មវិធីចុះឈ្មោះចូលរៀនជាថ្មី** | សិស្សបោះបង់ថ្នាក់ | កម្មវិធីទាំងនេះនឹងពង្រឹង ពង្រីកមជ្ឈមណ្ឌលរៀនសូត្រនៅសហគមន៍ បណ្ណាល័យ និងកន្លែង | ចន្លោះឆ្នាំ២០០៥ និង២០០៨ កុមារ ៦៨០០០នាក់បានមកចូលរៀនជាថ្មី |

[៤៧] របាយការណ៍អង្គការមិនមែនរដ្ឋាភិបាលស្តីពីការអប់រំឆ្នាំ២០០៩, ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ខែសីហា ២០១០, http://www.nepcambodia.org/userfiles/2009%20Education%20NGO%20Report%20August%2023%202010-%20Final.pdf ថ្ងៃទី០៩ កុម្ភៈ ២០១១។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | មានបំណងផ្តល់ឲ្យសិស្សថ្នាក់បឋមសិក្សានូវលទ្ធភាពនៃការចូលរៀនជាថ្មីនៅថ្នាក់ទី៣ និងទី៦។ | បឋមសិក្សា | អានសៀវភៅ និងបង្កើនសមត្ថភាពបុគ្គលិក NFE។ | នៅសាលាបឋមសិក្សាប្រកបដោយជោគជ័យ ក្នុងនោះ៦១.៦% គឺជាកុមារី។[៤៨] |
| ៣៤. ការផ្តល់អាហារ | **កម្មវិធីស្បៀងអាហារពិភពលោក –កម្មវិធីផ្តល់អាហារតាមសាលារៀន**(SFP) **និងកម្មវិធីរបបអាហារយកទៅផ្ទះ:**(THR)**ឆ្នាំ២០០៩។** ធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិចំនួន៥ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន១០[៤៩] កម្មវិធីទាំងនេះមានបំណងបង្កើនភាពរឹងមាំ និងសមត្ថភាពលៃលកដោះស្រាយរបស់គ្រួសារ | សិស្សបឋមសិក្សា | កម្មវិធីផ្តល់អាហារតាមសាលារៀនរួមមាន អាហារពេលព្រឹកព្រលឹមសម្រាប់សិស្សថ្នាក់ទី១-៦គ្រប់រូបនៅតាមសាលាគោលដៅ។ កម្មវិធីរបបអាហារយកទៅផ្ទះផ្តល់ទៅឲ្យកុមារថ្នាក់ទី៤-៦ ពីព្រោះកុមាទាំងនេះគឺជាកុមារដែលងាយប្រឈមបំផុតទៅនឹងការបោះបង់ការសិក្សា ឬការចូលរៀនមិនទៀងទាត់។ | ការផ្តល់អាហារនៅតាមសាលារៀនពិតជាអាចកាត់បន្ថយអត្រាបោះបង់ជាពិសេស សម្រាប់ថ្នាក់ទី២ដល់ទី៤ ដែលមានអានុភាពចម្បងមកលើកុមារា និងកុមារី ចន្លោះ១.៨% និង២.៧%។ អត្រាបោះបង់សម្រាប់កុមារីមាននិន្នាការស្រដៀងគ្នា ប៉ុន្តែសំខាន់ |

[៤៨] ក្រសួងអប់រំ យុវជន និងកីឡា *របាយការណ៍ពាក់កណ្តាលត្រីមាសនៃផែនការយុទ្ធសាស្ត្រអប់រំ និងការអនុវត្តកម្មវិធីទ្រទ្រង់វិស័យអប់រំឆ្នាំ២០០៦-២០១០*http://www.moeys.gov.kh/DownLoads/Publications/MTR_Report_finalDraft120109_en.pdf

[៤៩] កម្មវិធីស្បៀងអាហារពិភពលោកមានបំណងសហការជិតស្និទ្ធជាមួយអាជ្ញាធរពីថ្នាក់ជាតិនៅក្រសួងអប់រំ រហូតដល់រដ្ឋបាលអប់រំថ្នាក់ខេត្ត និងស្រុក។ គោលបំណងនៃកិច្ចសហប្រតិបត្តិការនេះគឺដើម្បីពង្រឹងសមត្ថភាពថ្នាក់ជាតិ តាមរយៈការបណ្តុះបណ្តាលបុគ្គលិកថ្នាក់ខេត្ត និងស្រុកនៅក្នុងការគ្រប់គ្រងកម្មវិធីផ្តល់អាហារនៅសាលារៀន និងការកាន់កាប់កម្មវិធីសាលាកុមារមេត្រីតាមរយៈការចូលរួមដោយផ្ទាល់ក្នុងការគ្រប់គ្រង និងការអនុវត្តកម្មវិធីនេះ (ការជ្រើសរើសសាលា ការគ្រប់គ្រងសម្ភារៈប្រើប្រាស់ និងការត្រួតពិនិត្យ)។ ឯកសារយោង៖កម្មវធីផ្តល់អាហារនៅសាលារៀនរបស់កម្មវិធីស្បៀងអាហារពិភពលោកនៅកម្ពុជា ឆ្នាំ២០០០-២០១០៖ ការវាយតម្លៃផលប៉ះពាល់លើវិធីសាស្ត្រចម្រុះ, ខែវិច្ឆិកា ២០១០' DARA/WFP.

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្ដីអត្ថាធិប្បាយ | របាយការណ៍ស្ដីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | ងាយរងគ្រោះតាមរយៈអន្តរាគមន៍ជំនួយស្បៀងអាហារដែលកំណត់គោលដៅ។ | | កុមារសរុបចំនួន៨៨២,៩៨១នាក់ដែលទទួលផលប្រយោជន៍ពីកម្មវិធីទាំងនេះនៅឆ្នាំ២០០៩ ថយចុះពី៦១០,០០០នាក់ ដោយសារតែកង្វះមូលនិធិ, ទំនិញ និងអាហារឡើងថ្លៃ។ | តែនៅថ្នាក់ទី៤ និងទី៥ប៉ុណ្ណោះ នៅក្នុងករណីទាំងពីរនេះមានការកត់សម្គាល់ច្រើនជាងនិន្នាការទូទៅ។ នេះគឺជាសូចនាករដ៏សំខាន់មួយ ហើយលទ្ធផលនេះ បង្ហាញថាការផ្ដល់អាហារនៅសាលារៀនមានឥទ្ធិពលវិជ្ជមានទៅលើសិស្ស និងឆន្ទៈ(និងសមត្ថភាព)របស់ឪពុកម្ដាយសិស្សក្នុងការរៀនបន្ត។[៥០] |
| ៣៥. ការគាំពារសុខភាពកុមារ | **ច្បាប់អប់រំឆ្នាំ២០០៧ មាត្រា៨១ សិទ្ធិរបស់អ្នករៀនសូត្រ និងបុគ្គលិកអប់រំក្នុងការទទួលបានការពិនិត្យសុខភាព៖** អ្នករៀនសូត្រ និងបុគ្គលិកអប់រំនៅក្នុងស្ថាប័នអប់រំដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវមានសិទ្ធិទទួលបានការពិនិត្យសុខភាព។ សារាចរណែនាំអំពីការពិនិត្យសុខភាពត្រូវ | សិស្ស គ្រូបង្រៀន បុគ្គលិកសាលា | ការពិនិត្យសុខភាពនៅសាលារៀនភាគច្រើនឧបត្ថម្ភដោយអង្គការមិនមែនរដ្ឋាភិបាល។ | |

[៥០] កម្មវិធីផ្ដល់អាហារដល់សាលារៀនរបស់កម្មវិធីស្បៀងអាហារពិភពលោក ឆ្នាំ២០០០-២០១០៖ ការវាយតម្លៃផលប៉ះពាល់លើវិធីសាស្ត្រចម្រុះ, ខែវិច្ឆិកា ២០១០ ពី http://documents.wfp.org/stellent/groups/public/documents/reports/wfp230142.pdf

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | កំណត់ នៅក្នុងប្រកាសរួម ដោយក្រសួងទទួលបន្ទុកផ្នែកអប់រំ និងក្រសួងសុខាភិបាល។ | | | |
| | **គោលនយោបាយសុខភាពនៅសាលារៀនរបស់ក្រសួងអប់រំយុវជននិងកីឡា ឆ្នាំ២០០៦** មានគោលដៅដូចតទៅ៖<br>(ក) ធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់សិស្ស និងសិក្ខាកាមគ្រូបង្រៀនមុនចូលបម្រើការងារនៅកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យ និងបុគ្គលិកអប់រំនៅក្នុងស្ថាប័នអប់រំ និងឯកជនទាំងអស់ និងសហគមន៍នានា។<br>(ខ) ពង្រឹងសមត្ថភាព និងជំនាញចាំបាច់របស់សិស្ស និងសិក្ខាកាមគ្រូបង្រៀនមុនចូលបម្រើការងារនៅកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យ និងបុគ្គលិកអប់រំនៅក្នុងស្ថាប័នអប់រំរដ្ឋ និងឯកជនទាំងអស់ និងសហគមន៍ នៅក្នុងការទប់ស្កាត់គ្រោះថ្នាក់ដោយចៃដន្យ និងជំងឺផ្សេងៗក្នុងជីវិតប្រចាំថ្ងៃ។ | សិស្ស គ្រូបង្រៀន នៅក្នុងស្ថាប័នអប់រំរដ្ឋ និងឯកជន | គោលនយោបាយសុខភាពនៅសាលារៀនមានតម្រូវការច្រើនដូចខាងក្រោម៖<br>• ផ្តល់សេវាបម្រើសុខភាពតាមរយៈកិច្ចសហការជាមួយសេវាសុខភាពសាធារណៈ។<br>• ពង្រឹងការផ្តល់ថ្នាំវ៉ាក់សាំងដល់សិស្ស។<br>• ពង្រឹងអន្តរាគមន៍ទាន់ពេលវេលាទៅលើការបង្ការជំងឺឆ្លង និងជំនួយបន្ទាន់។<br>• លើកទឹកចិត្តដល់ការបង្កើតក្លឹបសុខភាពនៅសារធារណៈ និងស្ថាប័នអប់រំឯកជន។<br>• ពង្រឹងការគ្រប់គ្រងលើសំពាធផ្លូវចិត្តនិងផ្តល់សេវាប្រឹក្សាដល់សិស្ស។<br>• ធ្វើឲ្យប្រសើរឡើងនូវការផ្តល់អាហាររូបត្ថម្ភដល់សិស្ស តាមរយៈកម្មវិធីផ្តល់អាហារតាមសាលា និងលើកទឹកចិត្តសិស្សឲ្យចេះជ្រើសរើសអាហារមានសុខភាព និងសុវត្ថិភាព។ | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
| --- | --- | --- | --- | --- |
| | (គ) លើកទឹកចិត្ត និងផ្តល់ឱកាសដល់អ្នកដែលពាក់ព័ន្ធទាំងអស់ ជាពិសេសសហគមន៍ ដើម្បីឲ្យមានការចូលរួមកាន់តែច្រើនឡើងក្នុងការលើកកម្ពស់សុខភាពនៅសាលារៀន<br>(ឃ) បង្កើនការយកចិត្តទុកដាក់ទៅលើភាពដែលអាចទទួលបានសេវាអប់រំសុខភាពស្មើគ្នាសម្រាប់អ្នកពាក់ព័ន្ធគ្រប់រូប។ | | • កែលម្អ និងបង្កើនកម្មវិធីសុខភាពមាត់ធ្មេញ។<br><br>សមាសភាពរងនៃអាហារូបត្ថម្ភ និងសុខភាពនៅសាលារៀន របស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានសុខាភិបាលនៅសាលា ដែលមានការគាំទ្របច្ចេកទេសពីនាយកដ្ឋានមួយចំនួនរបស់ក្រសួងសុខាភិបាល។ ទាក់ទងនឹងសេវាអាហារូបត្ថម្ភ និងសុខភាពមានកម្មវិធីជាច្រើន ដែលកម្មវិធីនីមួយៗមានដៃគូអនុវត្តផ្សេងៗគ្នា ដែលរួមបញ្ចូលគ្នាជាកម្មវិធីអាហារូបត្ថម្ភ និងសុខភាពនៅសាលារៀនថ្នាក់ជាតិ។<br>• កម្មវិធីកម្ចាត់ដង្កូវព្រូនថ្នាក់ជាតិត្រូវបានសម្របសម្រួលដោយមជ្ឈមណ្ឌលជាតិជំងឺគ្រុនចាញ់។<br>• កុមារីក្នុងកម្រិតអនុវិទ្យាល័យដែលមានអាយុលើសពី១៥ឆ្នាំទាំងអស់ត្រូវបានកំណត់ជាអ្នក | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | | | ទទួលផលពីកម្មវិធីថ្នាក់ជាតិក្នុងការផ្តល់ឱសថដែលមានជាតិដែកដល់កុមារីស្ថិតក្នុងវ័យបន្តពូជ។ ឱសថដែលមានជាតិដែកនេះត្រូវបានផ្តល់ដោយកម្មវិធីអាហារូបត្ថម្ភថ្នាក់ជាតិ និងត្រូវបានផ្តល់បន្តដោយគ្រូបង្រៀនក្នុងខេត្តចំនួន១០ ។<br>• នាយកដ្ឋានឱសថបង្ការសម្របសម្រួលដោយផ្ទាល់លើកម្មវិធី២ជាមួយសាលារៀនៈ (១) កម្មវិធីលើកកម្ពស់សុខភាពមាត់ធ្មេញដែលគាំទ្រដោយវិស័យឯកជន និង (២) កម្មវិធីសុវត្ថិភាពផ្លូវថ្នល់ដែលសហការជាមួយក្រុមសមត្ថកិច្ចចរាចរណ៍។ កម្មវិធីទាំងពីរនេះត្រូវបានអនុវត្តទូលំទូលាយនៅរាជធានីភ្នំពេញ និងទីប្រជុំជននានា។<br>• នាយកដ្ឋានលើកកម្ពស់សុខភាពធ្វើការជាមួយសាលាក្នុងខេត្តបួនដើម្បីលើកកម្ពស់អាហារដែលមានអនាម័យ និងសុវត្ថិភាពដែលផ្តល់ | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្ដីអត្ថាធិប្បាយ | របាយការណ៍ស្ដីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | | | តាមរយៈអាជីវករលក់អាហារ។[៥១] | |
| ៣៦. ថ្នាក់រៀន/រោងជាង បំណិនជីវិត | **គោលនយោបាយសាលាកុមារមេត្រីឆ្នាំ២០០៧ វិសាលភាពទី៣ សុខភាព សុវត្ថិភាព និងការការពារដល់កុមារ :** ដើម្បីធានាថាកុមារទាំងអស់ដែលកំពុងទទួលការអប់រំត្រូវបានយកចិត្តទុកដាក់ និងគាំទ្រពីបុគ្គល និងស្ថាប័នពាក់ព័ន្ធទាំងអស់ដើម្បីធ្វើឲ្យពួកគេមានសុខភាពល្អ សុវត្ថិភាព និងការពារពួកគេពីអំពើហិង្សាក្នុងសាលា គ្រួសារ និងសហគមន៍។<br>អង្គការក្រៅរដ្ឋាភិបាលជាច្រើនគាំទ្រគោលនយោបាយនេះ (ដូចជា SCA, MJP, OEC, UPWD, Nomad, ICC,MODE, COES, KYA, CDRCP, VFC, PNKS, KAFDOC, REDA, SCD) | សិស្សកម្រិតបឋមសិក្សា និងអនុវិទ្យាល័យ | គោលនយោបាយនេះធានាបាននូវសុវត្ថិភាពអាហារសុវត្ថិភាព ទឹកស្អាត និងល័ក្ខខ័ណ្ឌអនាម័យក្នុងសាលា ការគ្រប់គ្រងលើការលក់អាហារក្នុងសាលា ការគាំពារសុខភាពកុមារ និងបរិស្ថានសាលាមានសុវត្ថិភាព។ | |

[៥១] ក្រសួងអប់រំ យុវជន និងកីឡា, របាយការណ៍សង្ខេបស្ដីពីការពង្រឹងវិស័យអប់រំឆ្លើយតបទៅនឹងកម្មវិធីសុខភាព អាហារូបត្ថម្ភ និងកម្មវិធីមេរោគអេដស៍/ជំងឺអេដស៍នៅសាលារៀន http://www.moeys.gov.kh/Includes/Contents/Icha/Summary%20Report%20on%20Strengtening%20the%20education%20sector%20response.pdf ថ្ងៃទី២៤ កុម្ភៈ ២០១១។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | ដែលស្ថិតក្នុងខេត្តកំពង់ចាម បាត់ដំបង រតនគិរី ភ្នំពេញ មណ្ឌលគិរី កំពង់ធំ សៀមរាប កំពត ក្រចេះ និងស្វាយរៀង។[៥២] | | | |
| | **គោលនយោបាយអភិវឌ្ឍន៍កម្មវិធីសិក្សារបស់ក្រសួងអប់រំយុវជន និងកីឡា ២០០៥-២០០៩** (មិនប្រាកដថាតើគោលនយោបាយនេះត្រូវបានកែសម្រួល ហើយមកទល់ពេលនេះនៅតែមានសុពលភាពឬយ៉ាងណានោះទេ) **ជំពូកទី៤** ស្នើឲ្យដាក់បញ្ចូលនូវបំណិនជីវិតទៅក្នុងមុខវិជ្ជានីមួយៗ រយៈពេលពី ២ ទៅ ៥ ម៉ោងក្នុងមួយសប្តាហ៍។<br>**៤.២** មូលដ្ឋានគ្រឹះនៃបំណិនជីវិតទាំងអស់មានជាអាទ៍ អក្សរសាស្ត្រខ្មែរ និងគណិតវិទ្យា ហើយការបង្រៀនមុខវិជ្ជាទាំងនេះជាគោលដៅ | សាលារដ្ឋ | បំណិនជីវិតមូលដ្ឋានត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាសម្រាប់ការអប់រំកម្រិតបឋមសិក្សា និងអនុវិទ្យាល័យ EEQP/ADB បានបង្កើតសេចក្តីណែនាំមួយអំពីបំណិនជីវិតដែលមានប្រហែល ២០០ ប្រធានបទរួមមានសុខភាព សង្គម និងវិជ្ជាជីវៈ ដែលត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំយុវជន និងកីឡា។<br>សៀវភៅណែនាំមួយនឹងត្រូវបានបង្កើតឡើងសម្រាប់ប្រធានបទទាំងនេះ។ | |

[៥២] របាយការណ៍អង្គការមិនមែនរដ្ឋាភិបាលស្តីពីការអប់រំឆ្នាំ២០០៩, ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល, ខែសីហា ២០១០, http://www.nepcambodia.org/userfiles/2009%20Education%20NGO%20Report%20August%2023%202010-%20Final.pdf ថ្ងៃទី០៩ កុម្ភៈ ២០១១។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | សំខាន់សម្រាប់ការអប់រំកម្រិតបឋមសិក្សាក្នុងរយៈពេលបីឆ្នាំដំបូងនៃការសិក្សា។<br>**៩.៤** ដើម្បីរក្សាភាពស៊ីសង្វាក់គ្នានឹងគោលនយោបាយ EFA សាលានានាត្រូវបានរំពឹងថានឹងបង្កើតភាពជាដៃគូជាមួយឪពុកម្តាយសហគមន៍មូលដ្ឋានរបស់ពួកគេ អង្គការសហគមន៍និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្តល់កម្មវិធីបំណិនជីវិតមូលដ្ឋានបន្ថែមដែលនឹងផ្តល់ឲ្យសិស្សនូវជំនាញឯកទេសរួមមានទីកន្លែងនិងការបណ្តុះ បណ្តាលវិជ្ជាជីវៈមូលដ្ឋាន។ | | | |
| | កម្មវិធីអង្គការមិនមែនរដ្ឋាភិបាលជាច្រើន (ឧទាហរណ៍ AFESIP, CARE, Khmer Ahimsa, RAO, APESCA, BSDA, WE, Hagar, and KAPE) ផ្តល់**សកម្មភាពបំណិនជីវិត**ដើម្បីធ្វើលើកកម្ពស់ការងារអប់រំដោយប្រើការផ្តល់អំណាចជាគោលការណ៍គោល និងអាចឲ្យសិស្សជ្រើសរើសនូវអ្វីដែលពួកគេចង់រៀន។ | យុវជន | ប្រធានបទអាចរួមមាន ការជួសជុលយានជំនិះ ជំនាញកសិកម្ម ដេរប៉ាក់ ការចំអិនអាហារ ការដាំផ្សិត ជំនាញកុំព្យូទ័រ ។ល។ | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| ៣៧.សកម្មភាពកម្មវិធីសិក្សាបន្ថែម | អង្គការមិនមែនរដ្ឋាភិបាលជាច្រើនបានបង្កើត **ក្លឹបយុវជន និងកុមារ** (ឧ. អង្គការសង្គ្រោះកុមារ អង្គការទស្សនៈពិភពលោក អង្គការវីនរ៉ក់ និង អង្គការមូលនិធិកុមារកម្ពុជា) ដើម្បីឲ្យកុមារនៅក្រៅសាលាបានបន្តការសិក្សា និងផ្តល់អំណាចដល់ពួកគេជាមួយនឹងជំនួយបន្តិចបន្តួចដើម្បីកែលម្អសាលារៀន និងសហគមន៍របស់ពួកគេ។ | សិស្សពីថ្នាក់ទី១ ដល់១២ | អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការជាមួយយុវជនបង្ហាត់ជំនាញដល់កុមារ នៅពេលដែលពួកគេចូលរួមជាអ្នកស្ម័គ្រចិត្តក្នុងសហគមន៍របស់ពួកគេ។ ក្នុងឆ្នាំ២០០៦ អង្គការ និងក្លឹបដែលដឹកនាំដោយយុវជន និងកុមារត្រូវបានកំណត់នៅទូទាំង ២៤ខេត្តក្រុងនៃប្រទេសកម្ពុជា។ ចាប់តាំងពីពេលនោះមក អង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀតបានគាំទ្រដល់កុមារ និងយុវជនដើម្បីបង្កើតក្លឹបថ្មីៗ។ សកម្មភាពនៃសមាគមទាំងនេះរួមមានវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ ការថែទាំតាមផ្ទះ (សម្រាប់អ្នកមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍) ការគាំពារសុខភាពនៅកម្រិតបឋមសិក្សា និងការលើកកម្ពស់សិទ្ធិកុមារ ការត្រួតពិនិត្យតាមដានរាល់សកម្មភាពរំលោភបំពានលើកុមារ ការកសាងសម្ថភាពដល់សមាជិកក្លឹប និងការរៀបចំថ្នាក់អក្ខរកម្ម។ | |

| *ប្រធានបទគោលនយោបាយឬកម្មវិធី* | *ឯកសារ* | *ក្រុមគោលដៅ* | *ការបរិយាយ/សេចក្តីអត្ថាធិប្បាយ* | *របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា* |
|---|---|---|---|---|
| ៣៨. ការចូលរួមរបស់សហគមន៍ | **ច្បាប់បោះឆ្នោតឆ្នាំ២០០៧ ជំពូក៣៦ សិទ្ធិ និងភារកិច្ចទទួលខុសត្រូវលើការអប់រំរបស់ឪពុកម្តាយ និងសហគមន៍** បញ្ជាក់ច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់សមាគមមាតាបិតាសិស្ស៖<br><br>• ឧបត្ថមដល់ការសាងសង់សាលារៀន និងការថែទាំ<br>• វៃអង្គាសថវិកា<br>• សុវត្ថិភាពសម្ភារៈនៅសាលារៀន<br>• ផ្តល់ថវិកាដល់គ្រូបង្រៀនក្រីក្រ<br>• ធ្វើយុទ្ធនាការចុះឈ្មោះចូលរៀន<br>• លើកទឹកចិត្តកុមារដែលមានអាយុ០៦ឆ្នាំ ឲ្យចុះឈ្មោះចូលរៀនទាន់ពេលវេលា<br>• តាមដានការសិក្សារបស់សិស្ស<br>• លើកកម្ពស់ការយល់ដឹងក្នុងសហគមន៍អំពីតម្លៃនៃការអប់រំ និង | សាលារៀនកម្រិតបឋមសិក្សា និងអនុវិទ្យាល័យ និងសហគមន៍ | ផ្នែកនេះសំដៅលើសាលារៀនដែលគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាលដែលមានសមាគមមាតាបិតាសិស្សដ៏សកម្ម។ សកម្មភាពនានាផ្តោតលើការរៃអង្គាសថវិកាដើម្បីអភិវឌ្ឍសាងសង់សាលារៀន។<br>សមាជិកភាពជាទូទៅរួមមានមន្ត្រីមូលដ្ឋាន និងសមាជិកសហគមន៍ដ៏សកម្ម។ | |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | • ពង្រឹងទំនាក់ទំនងរវាងសាលារៀន និងសហគមន៍។[៥៣] | | | |
| | **គោលនយោបាយសាលាកុមារមេត្រីឆ្នាំ២០០៧ វិសាលភាពទី៥ ការចូលរួមរបស់សិស្ស គ្រួសារ និងសហគមន៍ក្នុងការគ្រប់គ្រងសាលារៀនមូលដ្ឋានរបស់ពួកគេ។** ការចូលរួមមានដូចខាងក្រោម :<br>• ប្រមូលការងារ និងស្នាដៃរបស់សិស្ស ដើម្បីយកមកតាំងពិព័រណ៍សហគមន៍<br>• រៀបចំសកម្មភាពសង្គម ឬសកម្មភាពប្រមូលផ្តុំដើម្បីឲ្យសហគមន៍មានចំណាប់អារម្មណ៍លើសាលារៀន<br>• ការបង្កើតក្រុមប្រឹក្សាសិស្ស និង<br>• ការបង្កើតយុទ្ធសាស្រ្តដែលសាលារៀនអាច | សិស្ស<br>គ្រួសារ<br>សហគមន៍ | ការចូលរួមរបស់សហគមន៍ទំនងជាសកម្មជាងគេនៅក្នុងសាលារៀនដែលគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល | |

[៥៣] បទសម្ភាសន៍ជាមួយលោក ពេជ្រ ប៊ុណ្ណា ប្រធាននាយកដ្ឋានអប់រំបឋមនៃក្រសួងអប់រំ យុវជន និងកីឡា, ភ្នំពេញ ថ្ងៃទី១១ កុម្ភៈ ២០១១។

| ប្រធានបទ គោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | ជួយដល់គ្រួសា និងសហគមន៍ | | | |
| | **យុទ្ធនាការសម្រាប់ការអប់រំជាសកល** កម្មវិធីនេះត្រូវបានរួមគ្នាគាំទ្រដោយក្រសួងអប់រំ យុវជន និងកីឡា និងភាពជាដៃគូអប់រំនៃអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា(NEP Cambodia) មានជាអាទិ៍អង្គការ (GCE Cambodia, Aide et Action, VSO, World Vision, RAO, DAC, Hagar, Plan, Dycfec និង UNESCO) ធ្វើការដើម្បីផ្តល់ព័ត៌មានដល់សហគមន៍អំពីសិទ្ធិ និង EFA របស់ពួកគេ កាត់បន្ថយហានិភ័យនៃសុខមាលភាពកុមារ និងដើម្បីលើកកម្ពស់ការផ្លាស់ប្តូរជាវិជ្ជមានក្នុងសហគមន៍ កាត់បន្ថយសិស្សស្រីបោះបង់ការសិក្សា និងដើម្បីលើកកម្ពស់សម្លេងរបស់កុមារី និងស្ត្រី។ | សហគមន៍ កុមារគ្រប់អាយុចូលរៀន | GCE បានចាប់ផ្តើមនៅទូទាំងពិភពលោកក្នុងឆ្នាំ១៩៩៩ ប្រទេសកម្ពុជាបានចូលជាសមាជិកក្នុងឆ្នាំ២០០៧ ដោយធ្វើការឆ្ពោះទៅរក EFA ២០១៥។<br><br>GCE រៀបចំព្រឹត្តិការណ៍យុទ្ធនាការប្រចាំឆ្នាំ។ សម្រាប់ឆ្នាំ២០១០ យុទ្ធនាការនេះផ្តោតលើហិរញ្ញវត្ថុអប់រំ និងសិក្ខាសាលាតាមបណ្តាខេត្តជាច្រើន ដែលផ្តល់ព័ត៌មានអំពីហិរញ្ញវត្ថុសាធារណៈដល់អ្នកពាក់ព័ន្ធ។ ក្នុងឆ្នាំ២០១១ GCE នឹងផ្តោតលើការអប់រំរបស់កុមារី និងស្ត្រី។ សកម្មភាពក្នុងព្រឹត្តិការណ៍នេះនឹងប្រព្រឹត្តទៅក្នុងគោលបំណងលើកកម្ពស់ EFA ។ | នៅឆ្នាំ២០០៩ ប្រជាពលរដ្ឋ៥០០០នាក់ បានចូលរួមក្នុងព្រឹត្តិការណ៍ GCE នៅកម្ពុជា។ |
| **ទម្លាប់អនុវត្តតាមវប្បធម៌** | | | | |
| ៣៩. អាយុរៀបការ | **ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ** | ពលរដ្ឋ | ជាទ្រឹស្តី និងយោងទៅលើច្បាប់ អាពាហ៍ពិពាហ៍ | ដោយសារវាជាការអនុវត្តទូទៅដើម្បី |

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| | ត្រូវបានអនុម័តដោយរដ្ឋសភានៃកម្ពុជានៅថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ១៩៨៩[៥៤] មានគោលដៅការពារ និងធានាសមភាពប្តីប្រពន្ធក្នុងអាពាហ៍ពិពាហ៍។ **ជំពូក៥** និយាយថាអាពាហ៍ពិពាហ៍មួយត្រូវបានអនុញ្ញាតសម្រាប់បុរសដែលមានអាយុចាប់ពី២០ឆ្នាំឡើង និងស្ត្រីដែលមានអាយុចាប់ពី១៨ឆ្នាំឡើង។ ក្នុងករណីពិសេសពេលដែលបុរសមានអាយុក្រោម២០ឆ្នាំនិង/ឬ ស្ត្រីអាយុក្រោម១៨ឆ្នាំ អាពាហ៍ពិពាហ៍អាចត្រូវបានអនុញ្ញាត ក្នុងករណីមានការព្រមព្រៀងពីឪពុកម្តាយ ឬអាណាព្យាបាល ប្រសិនបើស្ត្រីនោះមានផ្ទៃពោះ។[៥៥] | | គួតែមិនមានផលប៉ះពាល់ដល់ការបោះបង់ការសិក្សានោះទេ ដរាបណាសិស្សនោះមិនលើសអាយុ ឬមានផ្ទៃពោះ។ ទោះបីជាយ៉ាងណានៅពេលក្មេងស្រីដល់វ័យរៀបការ ជាទូទៅពួកគេស្ថិតក្នុងថ្នាក់ទី៨ ឬទី៩ ហើយឪពុកម្តាយតែងតែរៀបចំឲ្យពួកគេរៀបអាពាហ៍ពិពាហ៍។ | រៀបចំអាពាហ៍ពិពាហ៍សម្រាប់ក្មេងស្រីនោះពិតជាមានផលប៉ះពាល់ដល់ការបោះបង់ការសិក្សា បើទោះបីជាមិនមានទិន្នន័យជាក់លាក់ណាមួយបង្ហាញពីផលប៉ះពាល់នេះក៏ដោយ។ |
| ៩០. ការមានផ្ទៃពោះ | **កម្មវិធីសិទ្ធិកុមារ**ធានាបាននូវសិទ្ធិរបស់កុមារ | ស្ត្រីក្នុងវ័យ | កម្មវិធីនេះបាននាំទៅដល់ការបង្កើតគណៈកម្មាធិ | CCWCs ទើបតែបង្កើតនាពេលថ្មីៗ |

---

[៥៤] ដកស្រង់ចេញពីសៀវភៅច្បាប់កម្ពុជា, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, គម្រោង *UNDP, CMB96-005* គេហទំព័រ *http://bno.com.kh/Cambodia%20Laws/100_LAW_Marriage%20and%20Family%20Law,%20Eng.pdf* *ថ្ងៃទី១៥ កុម្ភៈ ឆ្នាំ២០១១។*

[៥៥] *http://bno.com.kh/Cambodia%20Laws/100_LAW_Marriage%20and%20Family%20Law,%20Eng.pdf*

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
| --- | --- | --- | --- | --- |
| | និងការគាំទ្រដល់ម្តាយ។ | បន្តពូជជាពិសេសជាមួយគ្រួសារដែលងាយរងគ្រោះ កុមារស្ថិតក្នុងតម្រូវការការការពារពិសេស និងអ្នកដែលរស់នៅជាមួយមេរោគ | ការឃុំសង្កាត់សម្រាប់ស្ត្រី និងកុមារ (CCWC) ចំនួន១៣០ ។ សមាជិករបស់ពួកគេត្រូវបានបណ្តុះបណ្តាលលើបញ្ហាកុមារ ស្ត្រី និងសង្គម។[៥៦]<br><br>មិនមានគោលនយោបាយហាមឃាត់ក្មេងស្រីមិនឲ្យចូលរៀនឡើងវិញបន្ទាប់ពីសម្រាលកូន ប៉ុន្តែក្នុងការអនុវត្តពួកគេមានទំនោរក្នុងការបោះបង់ការសិក្សា។ ច្បាប់ស្រីរបស់ប្រទេសកម្ពុជាបានបង្រៀនតាមផ្ទះទូទាំងប្រទេសអំពីតួនាទីយេនឌ័រ និងច្បាប់ស្រី។<br><br>កម្មវិធីទប់ស្កាត់សិស្សបោះបង់ការសិក្សា (SDPP) មិនទាន់ដឹងអំពីកម្មវិធីណាមួយដើម្បីលើកទឹកចិត្តក្មេងស្រីឲ្យត្រលប់ចូលរៀនវិញទេ ហើយពួកគេទំនងជាមិនត្រឡប់មករៀនវិញនៅថ្នាក់បឋម | ហើយគេមិនទាន់ដឹងថាស្ថាប័ននេះនឹងមានប្រសិទ្ធភាពកម្រិតណាក្នុងការគាំទ្រសិស្សស្រីនៅឡើយទេ។ |

[៥៦] http://ochaonline.un.org/TrustFund/ProjectProfiles/SethKomaChildrightsinCambodia/tabid/2119/language/en-US/Default.aspx (កម្មវិធី សិទ្ធិកុមារ)។

| *ប្រធានបទគោលនយោបាយឬកម្មវិធី* | *ឯកសារ* | *ក្រុមគោលដៅ* | *ការបរិយាយ/សេចក្តីអត្ថាធិប្បាយ* | *របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា* |
|---|---|---|---|---|
| | | អេដស៍/ជំងឺអេដស៍ | សិក្សា និងអនុវិទ្យាល័យនោះទេ ប៉ុន្តែពួកគេអាចនឹងចូលរៀនក្នុងកម្មវិធីអក្ខរកម្ម។ | |
| ៩១. ពិធីតាមប្រពៃណី/ការរៀបចំពិធីតាមប្រពៃណី | ការអនុវត្តជាធម្មតាក្នុងប្រទេសកម្ពុជាគឺគ្រួសារក្រីក្រតែងតែសម្រេចចិត្តឲ្យកូនៗរបស់ពួកគេឈប់រៀនដើម្បីជួយរកចំណូលផ្គត់ផ្គង់គ្រួសារ។ នេះជាករណីពិសេសសម្រាប់ក្មេងស្រីៗ។ **ច្បាប់ស្រី**[៥៧] បានរឹតត្បិតឥរិយាបថក្មេងស្រីឲ្យបោះបង់ការសិក្សាដើម្បីគាំទ្រដល់គ្រួសារ ដោយសារតែគេគិតថាវាមិនសំខាន់ក្នុងការឲ្យក្មេងស្រីទទួលបានការអប់រំ។ | សិស្សនៅក្រៅសាលាជាពិសេសសិស្សស្រី | អង្គការក្រៅរដ្ឋាភិបាលនានាតែងតែធ្វើ**យុទ្ធនាការចុះឈ្មោះចូលរៀន និងការធ្វើផែនទីសាលារៀន** ដើម្បីកំណត់ទីតាំងកុមារនៅក្រៅសាលា ដោយការប្រើចរិការពីកម្មវិធីមួយចំនួនដូចជាសាលាកុមារមេត្រីជាដើម។ | វិសមភាពនៃការចុះឈ្មោះចូលរៀន និងការបញ្ចប់ថ្នាក់កំពុងមានការថយចុះ ដូចច្នេះគេអាចសន្មតថាសកម្មភាពមួយចំនួនដូចជាការឆ្លើយតបយេនឌ័រ យុទ្ធនាការចុះឈ្មោះចូលរៀន និងការធ្វើផែនទីសាលារៀនបានជួយដោះស្រាយទំនាមទំលាប់វប្បធម៌។[៥៨] |
| *ផ្សេងៗ* | | | | |
| ៩២. ជំនាញប្រកបរបរចិញ្ចឹមជីវិត | អង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានគាំទ្រ **គម្រោងប្រកបរបរចិញ្ចឹមជីវិត** | ឪពុកម្តាយ | | |

[៥៧] ការបកប្រែច្បាប់ស្រី http://carpediemilia.over-blog.com/article-21656482-6.html

[៥៨] *និន្នាការការងារ និងសង្គមនៅកម្ពុជា ឆ្នាំ២០១០* វិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ/អង្គការពលកម្មអន្តរជាតិ ខែកញ្ញា ២០១០។

| ប្រធានបទគោលនយោបាយឬកម្មវិធី | ឯកសារ | ក្រុមគោលដៅ | ការបរិយាយ/សេចក្តីអត្ថាធិប្បាយ | របាយការណ៍ស្តីពីផលប៉ះពាល់លើសិស្សបោះបង់ការសិក្សា |
|---|---|---|---|---|
| សម្រាប់ឪពុកម្តាយ | ដើម្បីជួយឪពុកម្តាយរកប្រាក់ចំណូលបន្ថែម ដូច្នេះពួកគេមិនបញ្ជូនកូនឲ្យទៅធ្វើការជំនួសការបញ្ជូនកូនទៅរៀននោះទេ។ | | | |

# ឯកសារយោង


Filmer, D. Schady, N. (March 2006). *Getting Girls Into School: Evidence from a Scholarship Program in Cambodia*. World Bank.Available at http://siteresources.worldbank.org/INTPUBSERV/Resources/477250-1186007634742/ Filmer&SchadyGettingGirlsSchool.pdf

Final Summary Report on Activities of the Cambodian National Council for Women (CNCW) in 2010 and Directives for 2011.

International Labor Organization (ILO), UNICEF and the World Bank. (2006). C*hildren's Work in Cambodia: A Challenge for Growth and Poverty Reduction.* Report No. 38005.

Interview with H.E. Nhim Vanchancorn, President of Gender and Girls Education Secretariat and Deputy of the Inspectors Department, MoEYS, 9 February 2011.

Interview with Mr. In Samrithy, NEP Coordinator, Phnom Penh, 9 February 2011.

Interview with Mr. Pech Bunna, Chief of MoEYS Primary Education Department, Phnom Penh, 11 February 2011.

Interview with Ms. Kuy Phalla, Deputy Director of EMIS/Planning Department, MoEYS, Phnom Penh, 4 February 2011.

Interview with Nhean Sarouen, MoEYS Special Education Office, Primary Education Department, Phnom Penh, 11 February 2011.

Interviews with H.E. Ou Eng, General Deputy Director of Education Department; Chum Sophal, Deputy Director of Primary Education; and Ung Ngohok, Director of Secondary Education, at General Education Department, Phnom Penh, 3 February 2011.

Interviews with Mr. Ung Ngohok, Director of Secondary Education Department, MoEYS, Phnom Penh, 4 February 2011 and 10 February 2011.

Kalyanpur, M. (28 October, 2010). *Advocacy and Inclusive Education: The Role of FTI.* A presentation by MOEYS to NEP meeting.Available at http://www.nepcambodia.org/pages.php?mainid=44&key3=Fifth%20Membership%20Meeting.

Kampuchean Action for Primary Education. (January 2011). *Minority Outreach in Education (MORE) Annual Report, Year 2 of Implementation*.

Kampuchean Action for Primary Education. (2010). *Rewrite the Future project report 2009-10*.

Macro International, Inc. (2007). *Independent Final Evaluation of OPTIONS: Combating Child Trafficking and Commercial Sexual Exploitation Through Education in Cambodia*. Available at http://www.dol.gov/ilab/projects/asia/Cambodia_OPTIONS_feval.pdf.

Ministry of Education, Youth and Sport (Kingdom of Cambodia).(December 2005).*Education Strategic Plan 2006-2010*. Available at http://planipolis.iiep.unesco.org/upload/Cambodia/Cambodia%20Education%20Strategic%20Plan%202006-2010.pdf.

Ministry of Education, Youth and Sport (September 2010).*Education Strategic Plan 2009-2013*. Available at http://www.nepcambodia.org/userfiles/ESP_2009_2013_Final_en(1).pdf.

Ministry of Education, Youth and Sport (January 2009). *Mid-term Review Report of the Education Strategic Plan and Education Sector Support Program 2006-2010 implementation.* http://www.moeys.gov.kh/DownLoads/Publications/MTR_Report_finalDraft120109_en.pdf.

Ministry of Education, Youth and Sport (March 2008).*Policy on Education for Children with Disabilities*.Available at http://nepcambodia.org/pdffiles/Disability%20Policy%20-%20English%2001-03-08.pdf.

Ministry of Education, Youth and Sport (No date provided). *Summary Report on Strengthening the Education Sector Response to School Health, Nutrition, and HIV&AIDS Programs*.A workshop report, available at http://www.moeys.gov.kh/Includes/Contents/Icha/Summary%20Report%20on%20Strengtening%20the%20education%20sector%20response.pdf.

Ministry of Education, Youth and Sport.(16 August 2010).*Teacher Development Master Plan 2010-2014*.

Ministry of Women's Affairs (Kingdom of Cambodia). (2008). *A Fair Share for Women,Cambodia Gender Assessment*.

National Institute of Statistics/Ministry of Planning/International Labor Organization. (September 2010). *Labor and Social Trends in Cambodia 2010*.

NGO Education Partnership. (August 2010). *2009 Education NGO Report*.Available at http://www.nepcambodia.org/userfiles/2009%20Education%20NGO%20Report%20August%2023%202010-%20Final.pdf.

Partnership Against Domestic Violence Cambodia. (1 August, 2008). *Chbab Srey, Code of Conduct of Cambodian Women*. A translation, available at http://carpediemilia.over-blog.com/article-21656482-6.html.

Purcell, R., Riddell, A., Taylor, G., Vicheanon, K. (February 2010). *Mid-term Evaluation of the EFA Fast Track Initiative; Country Case Study: Cambodia*. Available at http://www.camb-ed.com/fasttrackinitiative/download/FTI_CR_Cambodia%28February2010y%29.pdf.

Royal Government of Cambodia, *National and Subnational Reports on Committee for Upholding Social Morality, Khmer Women and Family Values, for the year 2010 and objectives for 2011*, presented 8 February 2011, Phnom Penh.

UNDP Project CMB96-005 website.*The Compendium of Cambodian Laws, Council for the Development of Cambodia*.Available at*http://bno.com.kh/Cambodia%20Laws/100_LAW_Marriage%20and%20Family%20Law,%20Eng.pdf*.

UNESCO/European Agency for Development in Special Needs Education. (No date provided). *Theory Into Practice for Trainee Teachers in Cambodia*. A report of the Inclusive Education in Action project, available at http://www.inclusive-education-in-action.org/iea/index.php?menuid=25&reporeid=113.

UNESCO International Institute for Educational Planning/Sida Advisory Team. (April 2010). *Expanded Basic Education Program (EBEP) Phase II: 2006-2010 Review report of year 2009*.http://www.iiep.unesco.org/fileadmin/user_upload/News_And_Events/pdf/2010/SATReviewreport2009.pdf.

United Nations.(2007). *"Seth Koma"- Survival and Development of Children in Rural Cambodia*.Available at http://ochaonline.un.org/TrustFund/ProjectProfiles/SethKomaChildrightsinCambodia/tabid/2119/language/en-US/Default.aspx.

World Education. (October 2010). *Improved Basic Education in Cambodia Annual Report*.

World Food Program. (November 2010). *WFP Cambodia School Feeding 2000-2010: A Mixed Method Impact Evaluation*. Available at http://documents.wfp.org/stellent/groups/public/documents/reports/wfp230142.pdf.